ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

# ផែនការសកម្មភាព និងថវិកា

# ឆ្នាំ២០០៧

មិនា ២០០៧

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មាធិការជាតិដឹកនាំការងារកំណែទំរង់**

**វិមជ្ឈការ និងវិសហមជ្ឈការ**

# ផែនការសកម្មភាព និងថវិកា

# ឆ្នាំ ២០០៧

**មិនា ២០០៧**

# អារម្ភកថា

គណៈកម្មាធិការជាតិដឹកនាំការងារកំណែទំរង់វិមជ្ឈការ និងវិសហាមជ្ឈការ (គជវវ) ត្រូវបានបង្កើតឡើង ជាផ្លូវការ នៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៦ ដោយព្រះរាជក្រឹត្យ លេខ ០៦០៨/៣៩៥។ គជវវ បានទទួលយកនូវសមត្ថកិច្ច និងតួនាទីនានារបស់ គណៈកម្មាធិការជាតិគាំទ្រឃុំ-សង្កាត់ (គឃស) គណៈកម្មាធិការអន្តរក្រសួងសំរាប់ការព្រាងច្បាប់គ្រប់គ្រងខេត្តក្រុង ស្រុកខណ្ឌ និងគណៈកម្មាធិការដឹកនាំការងារកម្មវិធីសិលា (ពីត្រឹមថ្ងៃទី ០១ មករា ២០០៧)។ ក្នុងរូបភាពនេះហើយ ដែលអាជ្ញាធរជាតិឯកភាពមួយបានកើតឡើង ដើម្បីគ្រប់គ្រង និងដឹកនាំរួមលើ ការតាក់តែងគោលនយោបាយ និងលិខិតបទដ្ឋានច្បាប់នានា ការរៀបចំកម្មវិធីជាតិ វិមជ្ឈការ និងវិសហាមជ្ឈការ ការរៀបចំកម្មវិធីប្រើប្រាស់ធនធានក្នុងនិងក្រៅប្រទេស ការរៀបចំផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំ និងការសំរបសំរួលអនុវត្តន៍ ផែនការសកម្មភាពប្រចាំឆ្នាំ និងការគ្រប់គ្រងប្រតិបត្តិការទូទៅ លើគំរោង និង កម្មវិធីជំនួយនានា ដែលបានចុះ អនុសារណៈ ផ្ទាល់ជមួយ គជវវ។

សេចក្តីព្រាងនៃច្បាប់គ្រប់គ្រងខេត្តក្រុង-ស្រុកខណ្ឌ ដែលមានកំណត់ពីតួនាទីនិងអំណាចនៃថ្នាក់រដ្ឋបាលក្រោមជាតិ រំពឹងថានឹងត្រូវរៀបចំរួចរាល់ នៅក្នុងឆ្នាំ២០០៧។ សេចក្តីព្រាងច្បាប់នេះ ត្រូវបានលើកមកពិភាក្សាយ៉ាងទូលំទូលាយ ក្នុងមជ្ឈដ្ឋានរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានា នឹងត្រូវផ្តល់សច្ចាបន័ដោយរដ្ឋសភាជាតិ។ ដើម្បីធានាបាននូវភាពមិនដាច់រយៈនៃកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងដំណើការកែទំរង់វិមជ្ឈការ និងវិសហាមជ្ឈការ អាណត្តិការងារនិងភារៈកិច្ច គជវវ ផ្ទាល់ ក៏ដូចជាលេខាធិការដ្ឋាន និងក្រុមគាំទ្រកម្មវិធីរបស់ខ្លួន ត្រូវបានកំណត់យ៉ាងល្អិតល្អន់ និងច្បាស់លាស់។ នៅថ្នាក់ក្រោមជាតិ អណត្តិការងារនៃរចនាសម្ពន្ធ័ និងប្រពន្ធ័នានា ត្រូវបានរក្សាទុកដដែលសិន សំរាប់ទទួលអនុវត្តផែនការសកម្មភាពនិងថវិកា គជវវ ២០០៧ ដូចបានរៀបរាប់ក្នុងឯកសារ នេះស្រាប់។ នៅក្រោយពេលដែលច្បាប់គ្រប់គ្រងខេត្តក្រុង-ស្រុកខណ្ឌត្រូវបានអនុមត័រួច កំណែទំរង់រចនាសម្ពន្ធ័គ្រប់គ្រងថ្នាក់ក្រោមជាតិ នឹងត្រូវបានធ្វើឡើងជាបណ្តើរៗតាមរយៈសេចក្តីណែនាំថ្មីៗ ដែលនឹងត្រូវដាក់ចេញព្រមជាមួយនូវ យុទ្ធសាស្ត្រដ៏រលូន និងវគ្គបណ្តុះបណ្តាលដ៏ទូលាយមួយពីថ្នាក់ជាតិ។

ធនធានសរុបដែលត្រូវបានកៀងគរសំរាប់ឆ្នាំ២០០៧ ក្នុងក្របខណ្ឌ គជវវ មានចំនួន ៥៩លានដុល្លារ ដែលក្នុងនោះ ៥៣លានដុល្លារ នឹងត្រូវទទួលជាសាច់ប្រាក់ ហើយ៦លានដុល្លារ ទៀត នឹងត្រូវទទួលក្នុងរូបភាពជាសេវាអភិវឌ្ឍន៍ គោលនយោបាយ ការរៀបចំតាក់តែងកម្មវិធីនិងគំរោងការនានា និងសេវាទីប្រឹក្សាបច្ចេកទេស នៅថ្នាក់ខេត្ត និងថ្នាក់ជាតិ។ ក្នុងចំនួននេះ ថវិកាផ្តល់ដោយរាជរដ្ឋាភិបាលកម្ពុជាផ្ទាល់មានចំនួនជិត២២លានដុល្លារ ស្មើនឹងជាង មួយភាគបី នៃមូលនិធិសរុប រីឯចំនួនដែលនៅសល់ជិត៣៧លានដុល្លារ គឺជាថវិកាគាំទ្រដោយទីភ្នាក់ងារដៃគូអភិវឌ្ឍន៍ ចំនួន១៤។ ផែនការសកម្មភាពនិងថវិកាឆ្នាំ២០០៧របស់ គជវវ គឺជាការបង្ហាញជាទ្រង់ទ្រាយសង្ខេប នូវធនធាន

សរុបពីគ្រប់ប្រភពទាំងអស់ ការវិភាជន៍រួមជូនទៅស្ថាប័នប្រតិបត្តិការនានា និងផែនការប្រើប្រាស់ ធនធានទាំងនេះ ក្នុងការគាំទ្រកំណែទំរង់វិមជ្ឈការ និងវិសហមជ្ឈការ នៅថ្នាក់ឃុំសង្កាត់ ខេត្តក្រុង និងថ្នាក់ជាតិ ក្រោមក្របខណ្ឌ័រួមនៃ គជវវ ។ ផែនការសកម្មភាពនិងថវិកានេះ គឺជាលទ្ធផលនៃដំណើរការរៀបចំផែនការ និងកម្មវិធីរយៈពេល ៥ខែ ចាប់ពីខែសីហា២០០៦ ដល់ខែកុម្ភៈ២០០៧ ដែលមានការចូលរួមពិភាក្សាល្អិតល្អន់ពីបណ្តា ស្ថាប័នពាក់ព័ន្ធគ្រប់ជាន់ថ្នាក់ រួមមានក្រសួងនានា ខេត្តក្រុង ស្រុកខណ្ឌ័ ឃុំសង្កាត់ និងភាគីម្ចាស់ជំនួយនានា ក្រោមកិច្ចសម្របសម្រួល របស់អគ្គលេខាធិការដ្ឋាននៃ គជវវ ។

ផែនការសកម្មភាពនិងថវិកា ឆ្នាំ២០០៧ ជាការឆ្លុះបញ្ចាំងនូវការឆ្លើយតបរបស់ប្រភពមូលនិធិនានា ក្នុងការគាំទ្រមូលនិធិឃុំសង្កាត់តាមរយៈ គជវវ ការផ្តល់ហិរញ្ញប្បទានបន្ថែមសំរាប់ឃុំគោលដៅមួយចំនួនតាមគំរោងដៃគូនានា ការផ្តល់មូលនិធិពង្រឹងតួនាទីស្រុកខណ្ឌ័ដល់ស្រុកចំនួន១៣៥ ការគាំទ្រធនធានដល់ខេត្តក្រុងទាំង២៤ក្នុងការគាំទ្រវិនិយោគនិងអភិបាលកិច្ច ការគាំទ្រថវិកាដល់ក្រសួងស្ថាប័នចំនួន១៤ សំរាប់ការរៀបចំគោលនយោបាយ ចាត់ចែងគំរោងការនិងពង្រឹងសមត្ថភាព ព្រមទាំងការគាំទ្រធនធានដល់អគ្គលេខាធិការដ្ឋាន គជវវ ក្នុងការផ្តល់សេវាគ្រប់គ្រងទូទៅ លើកិច្ចអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំនេះផងដែរ ។ ដោយយោងតាមការវិភាជន៍ ដែលបានអនុមត័រួចនេះ ថវិកានានានឹងត្រូវបានផ្តល់ និងអនុវត្ត តាមរយៈអនុសារណៈកិច្ចព្រមព្រៀងផ្សេងៗ ដែលមានភ្ជាប់នូវផែនការការងារនិងថវិកាលំអិត ។ ហេតុនេះហើយ ផែនការសកម្មភាពនិងថវិកា គជវវ គ្រាន់តែបង្ហាញនូវទិដ្ឋភាពរួម ក្នុងក៏រិតយុទ្ធសាស្ត្ររបស់កម្មវិធីការងារឆ្នាំ២០០៧ប៉ុណ្ណោះ រីឯទិដ្ឋភាពលំអិតនៃសកម្មភាពនិងថវិកាមានបង្ហាញដោយឡែកៗ នៅក្នុងផែនការថវិការបស់គំរោងដៃគូទាំង១៤ កិច្ចសន្យាទាំង២៦ជាមួយក្រសួងនានាថ្នាក់ជាតិ ផែនការសកម្មភាពប្រចាំឆ្នាំជិត១០០របស់ខេត្តក្រុងនានា កិច្ចសន្យាចំនួន៥៣០ជាមួយមន្ទីរជំនាញនានានៅថ្នាក់ខេត្ត និងផែនការថវិកាប្រចាំឆ្នាំរបស់ឃុំសង្កាត់ទាំង១.៦២១ ។

ការអនុវត្តយ៉ាងស៊ីសង្វាក់គ្នា នូវលិខិតបទដ្ឋាន ប្រពន្ធ័ការងារ សេចក្តីណែនាំ និងនិតិវិធីនានា ព្រមជាមួយគ្នានូវការអភិវឌ្ឍន៍សមត្ថភាពទាំងឡាយ នៅក្នុងខេត្តក្រុងទាំង២៤ ស្រុកខណ្ឌ័ទាំង១៨៥ និងឃុំសង្កាត់ទាំង១.៦២១ ក៏ដូចជាការពិភាក្សានិងសំរបសំរួលតាមខ្សែបណ្តោយនិងខ្សែទទឹង ក្នុងការរៀបចំនិងអនុវត្តសកម្មភាពនានា បានជួយរួមចំណែកយ៉ាងធំធេងដល់រាជរដ្ឋាភិបាលក្នុងការឈានទៅមុខថែមទៀត លើវណសិរ្សកែទំរង់វិមជ្ឈការ និងវិសហមជ្ឈការ ។ ក្នុងខណៈដែលមានវឌ្ឍនភាពគួរជាទីពេញចិត្តក្នុងការកសាងបានជារចនាសម្ពន្ធ័និងប្រពន្ធ័ការងារដែលប្រកបប្រសិទ្ធិភាពមាំមួនហើយក្តី ក៏មានការទទួលស្គាល់ផងដែរនូវកិច្ចការចំបងមួយចំនួនដែលនៅមិនទាន់ត្រូវបានបញ្ចប់ ក្នុងបរិបទ ច្បាប់គ្រប់គ្រងខេត្តក្រុង ស្រុកខណ្ឌ័ ដូចជា ការធ្វើសមាណកម្មនិងជំរុញប្រសិទ្ធភាពនៃកំរងលិខិតបទដ្ឋានវិមជ្ឈការ ការរៀបចំដាក់ចេញនូវមធ្យោបាយបង្កើតប្រភពចំណូលផ្ទាល់របស់ឃុំ ការធ្វើ

ស្ថាបនីយកម្មប្រពន្ធ័គ្រប់គ្រងថ្នាក់ខេត្តក្រុង ស្រុកខណ្ឌផ្អែកតាមក្របខណ្ឌច្បាប់ និងការកំណត់ជាក់លាក់នូវទស្សនៈវិស័យនិងក្របខណ្ឌរយៈពេលវែង សំរាប់គាំទ្រអភិបាលកិច្ចមូលដ្ឋាននៅកម្ពុជា។

អភិបាលកិច្ចល្អ ត្រូវបានចាត់ជាកត្តាស្នូល នៃយុទ្ធសាស្រ្តចតុកោណរបស់រាជរដ្ឋាភិបាល ហើយនៅក្នុងឆ្នាំ២០០៧ ថវិកាប្រមាណជា១០លានដុល្លារ ឬ១៧%នៃធនធានសរុបប្រចាំឆ្នាំរបស់ គជវវ ត្រូវបានវភាជន៏សំរាប់គាំទ្រជាពិសេសដល់ ការពង្រឹងអភិបាលកិច្ចល្អ នៅថ្នាក់ក្រោមជាតិ។ ថវិកាវិភាជន៏ទៅឱ្យ ក្រសួងចំនួន១៤នៅថ្នាក់ជាតិ និងខេត្តក្រុងទាំង២៤ រួមជាមួយសេវាប្រឹក្សាបច្ចេកទេសដែលផ្តល់បន្ថែមសំរាប់ស្ថាបន័ទាំងនោះ នឹងជួយគាំទ្រយ៉ាងទូលំទូលាយ ដល់សកម្មភាពនានា ដែលទាក់ទិនទៅនឹងការពង្រឹងបែបបទនិតិវិធីនិងប្រពន្ធ័ការងារ ការផ្តល់វគ្គបណ្តុះបណ្តាលនៅគ្រប់ជាន់ថ្នាក់ ការធ្វើសមាហរណកម្មប្រពន្ធ័ពត៌មាននានាដែលបំរើឱ្យការគ្រប់គ្រងនៅថ្នាក់ជាតិ ពង្រឹងការត្រួតពិនិត្យ វាយតំលៃ ចាត់ចែង រាយការ និងសវនកម្ម ព្រមទាំងជំរុញភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍន៏នៅគ្រប់ថ្នាក់។

ផ្សារភ្ជាប់ជាមួយនឹងដំណើរការពង្រឹងអភិបាលកិច្ច ចាំបាច់ត្រូវធានាឱ្យមានធនធានវិនិយោគ នៅថ្នាក់ខេត្ត និងឃុំគ្រប់គ្រាន់ ដើម្បីឱ្យគោលការណ៏អភិបាលកិច្ច និងការអនុវត្តជាក់ស្តែង អាចបំលែងបានទៅជាផលចំណេញ ជួយដល់ប្រជាពលរដ្ឋ និងការកាត់បន្ថយភាពក្រីក្រ។ ក្នុងឆ្នាំ២០០៧នេះដែរ ថវិកាប្រមាណជា៧៥% ឬ ៤៧.៣លានដុល្លារ ត្រូវបានវិភាជន៏សំរាប់គាំទ្រដល់ការវិនិយោគនិងការផ្តល់សេវានានា ដែលទទួលអនុវត្តដោយ ក្រសួងជំនាញ និងស្ថាបន័នៅថ្នាក់ជាតិ មន្ទីរជំនាញនៅថ្នាក់ខេត្តក្រុង អាជ្ញាធរស្រុកខណ្ឌ ក្រុមប្រឹក្សាឃុំសង្កាត់ និងអ្នកទទួលការឯកជននានា។ សកម្មភាពអភិវឌ្ឍន៏ទាំងឡាយនេះ ត្រូវបានរៀបចំឡើងដោយផ្អែកតាមការប្រឹក្សាយោបល់ យ៉ាងស៊ីជំរៅ រវាងក្រុមប្រឹក្សាឃុំសង្កាត់ មន្ទីរជំនាញនានា ទីភ្នាក់ងារអភិវឌ្ឍន៏ជាតិ និងអន្តរជាតិ និងក្រសួងជំនាញនានានៅថ្នាក់ជាតិ ដោយអនុលោមតាមយុទ្ធសាស្រ្តជាតិកាត់បន្ថយភាពក្រីក្រ និងដំណើរការកសាងផែនការតាមបែបសមាហរណកម្ម។

គជវវ មានឆន្ទៈមុតមាំក្នុងការពង្រឹងនិងអភិវឌ្ឍន៏បន្តទៅទៀត នូវបណ្តាញនៃភាពជាដៃគូ ទាំងរវាងស្ថាបន័ក្នុងរដ្ឋាភិបាល និង ជាមួយដៃគូអភិវឌ្ឍន៏នានា ដែលត្រូវបានកសាងឡើងក្នុងបណ្តាឆ្នាំកន្លងទៅ ដើម្បីគាំទ្រកំណែទំរង់វិមជ្ឈការ និងវិសហមជ្ឈការ។ បណ្តាញភាពជាដៃគូទាំងនេះ កើតចេញមកពីដំណើរការសុខដុមនីយកម្ម នៃការគ្រប់គ្រង និងចាត់ចែងធនធាន ដែលបានមកពីក្រៅប្រទេស ហើយក៏បានជួយជំរុញការធ្វើសុខដុមនីយកម្ម ឱ្យឈានមកដល់កំរិតលេចធ្លោមួយ។ ធនធានទាំងឡាយដែលមានបង្ហាញ ក្នុងផែនការសកម្មភាពនិងថវិកា គជវវ ២០០៧នេះ បានមកពីការរួបរួមចូលគ្នានូវថវិកា ផ្តល់ដោយ រាជរដាភិបាលកម្ពុជា ធនាគារពិភពលោក ធនាគារអភិវឌ្ឍន៏អាស៊ី មូលនិធិអភិវឌ្ឍន៏កសិកម្មអ៊ីហ្វាត សហគមន៏អ៊ឺរ៉ុប រដ្ឋាភិបាលស៊ុយអែត ចក្រភពអង់គ្លេស

ដាណើម៉ាក់ កាណាដា អាល្លឺម៉ង់ និងថវិកាបានមកពីបណ្តាញសហប្រជាជាតិដូចជា យូអិនឌីភី យូនីសេហ្វ និងយូអិនអេហ្វភីអេ ជាដើម ព្រមទាំងពីដៃគូអង្គការក្រៅរដ្ឋាភិបាលនានាផងដែរ។ ក្រៅពីធនធានទាំងឡាយនេះ មានថវិកាប្រមាណជា ២ឬ៣លានដុល្លា ផ្សេងទៀតមិនត្រូវបានរៀបរាប់លំអិតក្នុងឯកសារផែនការនេះទេ តែជាក់ស្តែងត្រូវបានវិភាជន៍ទៅ គាំទ្រឃុំសង្កាត់នានាក្នុងឆ្នាំ២០០៧ តាមរយៈមន្ទីរជំនាញថ្នាក់ខេត្ត និងអង្គការមិនមែនរដ្ឋាភិបាលនានា ក្នុងដំណើរការសមាហរណកម្មផែនការថ្នាក់ស្រុក ដែលប្រព្រឹត្តទៅមួយឆ្នាំម្តង នៅតាមខេត្តក្រុងនានា។

ក្នុងនាទីជាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គណៈកម្មាធិការជាតិ ដឹកនាំការងារកំណែទំរង់វិមជ្ឈការ និងវិសហមជ្ឈការ ខ្ញុំសូមសំដែងការកោតសរសើរចំពោះ សមាជិកគជវវ ក្រុមការងារគជវវ អគ្គលេខាធិការដ្ឋានគជវវ និងក្រុមគាំទ្រគំរោងគជវវ ក៏ដូចជាអភិបាលខេត្តក្រុងទាំង២៤ ដែលទទួលដឹកនាំការអនុវត្តផែនការសកម្មភាព គជវវ នៅថ្នាក់ខេត្តក្រុង ក្នុងនាទីជាប្រធានគណៈកម្មាធិការអភិវឌ្ឍន៏ខេត្តក្រុង ព្រមទាំងមន្ត្រីរាជការស៊ីវិលរាប់ពាន់នាក់ ដែលចូលរួមគាំទ្រសកម្មភាពនានានៅថ្នាក់ខេត្តក្រុង ស្រុកខណ្ឌ។ ខ្ញុំក៏សូមសរសើរផងដែរ ចំពោះក្រុមប្រឹក្សាឃុំសង្កាត់ទាំង១,៦២១ ដែលបានធ្វើការយ៉ាងមមាញឹក ដើម្បីចាត់ចែង និងអភិវឌ្ឍន៏មូលដ្ឋានជនបទ ហើយជាពិសេស ចំពោះពលរដ្ឋកម្ពុជាទាំងបុរសស្ត្រីតំបន់ជនបទ ដែលបានបំពេញតួនាទីជាមូលដ្ឋានគ្រឹះ សំរាប់ការកសាងរាល់សមិទ្ធិផលនានាក្នុងទូទាំងប្រទេស។

ភ្នំពេញ ......មិនា ២០០៧

**ស ខេង**

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ប្រធាន គជវវ

# មាតិកាអត្ថបទ

**អារម្ភកថា**..........i
**មាតិកាអត្ថបទ**..........i
**បញ្ជីតារាង**.......... vii

**១. រចនាសម្ព័ន្ធថវិកា នៃផែនការសកម្មភាពនិងថវិកា គជមអ**..........1
១.១ ឃុំ សង្កាត់..........1
១.២ ស្រុក ខណ្ឌ..........**Error! Bookmark not defined.**
១.៣ ខេត្ត ក្រុង..........**Error! Bookmark not defined.**
១.៤ ថ្នាក់ជាតិ..........**Error! Bookmark not defined.**

**២. វិសាលភាព និងភាពជាដៃគូ នៃផែនការសកម្មភាពនិងថវិកា គជមអ ២០០៧**..........3

**៣. ធនធានដែលមាន និងការចាត់កម្មវិធី ឆ្នាំ២០០៧**..........**Error! Bookmark not defined.**

**៤. រាជរដ្ឋាភិបាល ម្ចាស់ជំនួយ និងដៃគូអភិវឌ្ឍន៍ ២០០៧**..........**Error! Bookmark not defined.**

៤.១ រាជរដ្ឋាភិបាលកម្ពុជា..........**Error! Bookmark not defined.**
៤.២ គំរោងគាំទ្រការអភិវឌ្ឍន៍ប្រជាធិបតេយ្យតាមរយៈវិមជ្ឈការ និងវិសហមជ្ឈការ (PSDD)**Error! Bookmark not defined.**
៤.៣ ធនាគារពិភពលោក: គំរោងវិនិយោគជនបទ និងអភិបាលកិច្ចមូលដ្ឋាន (RILGP) .. **Error! Bookmark not defined.**
៤.៤ មូលនិធិអន្តរជាតិសំរាប់អភិវឌ្ឍន៍វិស័យកសិកម្ម (IFAD)..........**Error! Bookmark not defined.**
៤.៥ ធនាគារអភិវឌ្ឍន៍អាស៊ី (ADB)..........**Error! Bookmark not defined.**
៤.៦ ប្រទេសដាណឺម៉ាក់ និងអង់គ្លេស: គំរោងគ្រប់គ្រងធនធានធម្មជាតិ និងជីវភាពរស់នៅ (NRML)..........18
៤.៧ សហគមន៍អឺរ៉ុប..........21
៤.៨ មូលនិធិសហប្រជាជាតិដើម្បីកុមារ: គំរោងសិទ្ធិកុមារ (UNICEF)..........24
៤.៩ រដ្ឋាភិបាល កាណាដា..........26
៤.១០ សហរដ្ឋអាមេរិកនិងអង្គការផែក: កម្មវិធីរដ្ឋបាលមូលដ្ឋាន និងកំណែទំរង់ (LAAR)..........28
៤.១១ រដ្ឋាភិបាលអាល្លឺម៉ង់..........30
៤.១២ មូលនិធិសហប្រជាជាតិដើម្បីប្រជាជន..........31
៤.១៣ អង្គការមិនមែនរដ្ឋាភិបាល..........32

**៥. កិច្ចព្រមព្រៀងហិរញ្ញវត្ថុ និងរំហូរថវិកា..............ERROR! BOOKMARK NOT DEFINED.**

**៦. ការចាត់កម្មវិធីតាមរយៈសមាហរណកម្មថ្នាក់ស្រុក.ERROR! BOOKMARK NOT DEFINED.**

**៧. ការចាត់កម្មវិធីថវិកាតាមខេត្តក្រុង ឆ្នាំ២០០៧ ...ERROR! BOOKMARK NOT DEFINED.**

**៨. ការវិភាគថវិកាតាមសមាសភាគនិមួយៗ.............ERROR! BOOKMARK NOT DEFINED.**

៨.១ មូលនិធិឃុំ សង្កាត់....................................................................**Error! Bookmark not defined.**

៨.២ ឃុំ សង្កាត់គោលដៅ .................................................................**Error! Bookmark not defined.**

៨.៣ កិច្ចពង្រឹងតួនាទីស្រុក.................................................................**Error! Bookmark not defined.**

៨.៤ ការវិនិយោគនៅថ្នាក់ខេត្ត...........................................................**Error! Bookmark not defined.**

៨.៥ ការគាំទ្រកម្មវិធីនៅថ្នាក់ខេត្ត.....................................................**Error! Bookmark not defined.**

៨.៦ សេវាក្រសួងថ្នាក់ជាតិ..................................................................**Error! Bookmark not defined.**

៨.៧ ការគាំទ្រកម្មវិធីនៅថ្នាក់ជាតិៈ លេខាធិការដ្ឋាន និងក្រុមគាំទ្រកម្មវិធីនៃ គជវវ........... **Error! Bookmark not defined.**

៨.៨ កិច្ចសហប្រតិបត្តិការបច្ចេកទេស.......................................................................................39

**៩. ផែនការសកម្មភាព គជវវ ២០០៧**.........................................................................43

# បញ្ជីតារាង


| | |
|---|---|
| តារាងទី១: | **ធនធានសរុបឆ្នាំ២០០៧** |
| ដ្យាក្រាមទី១: | **2007 Donor Coverage and Partnerships** |
| តារាងទី២: | **2007 Programming of Resources** |
| តារាងទី៣: | **2007 Programming of Resources** |
| តារាងទី៤: | **2007 Royal Government of Cambodia** |
| តារាងទី៥: | **2007 PSDD Resources** |
| តារាងទី៦: | **PSDD Budget Contribution to the 2007 NCDD AWPB** |
| តារាងទី៧: | **2007 World Bank/RILG Resources** |
| តារាងទី៨: | **2007 IFAD Resources** |
| តារាងទី៩: | **2007 ADB Resources** |
| តារាងទី១០: | **2007 Danida/DfID NRM&L Resources** |
| តារាងទី១១: | **2007 EC-UNDP Resources** |
| តារាងទី១២: | **2007 UNICEF Resources** |
| តារាងទី១៣: | **2007 Canada Resources** |
| តារាងទី១៤: | **2007 USAID/PACT Resources** |
| តារាងទី១៥: | **2007 Germany/GTZ Resources** |
| តារាងទី១៦: | **2007 UNFPA Resources** |
| ដ្យាក្រាមទី២: | **Fund Flow Arrangements** |
| តារាងទី១៧: | **2007 Estimated Contracts** |
| តារាងទី១៨: | **Summary Result of 2006 District Integration Workshops** |
| តារាងទី១៩: | **Provincial/Municipal 2007 AWPB Tables** |
| តារាងទី២០: | **National Level Summary Totals** |
| តារាងទី២១: | **2007 C/S Fund and Adjusted Proportions** |
| តារាងទី២២: | **2007 CS Fund Allocations by Component** |
| តារាងទី២៣: | **2007 CS Fund Administration Allocation** |
| តារាងទី២៤: | **CS Fund Development Allocations - 2004-2007** |
| តារាងទី២៥: | **2007 CS Targeted Allocations** |
| តារាងទី២៦: | **2007 C/S Development Allocations** |
| តារាងទី២៧: | **2007 Allocations to District/Khan Initiative** |
| តារាងទី២៨: | **2007 Provincial Investment Resources** |

តារាងទី២៩: **2007 Provincial Investment Allocations by Sector/Sub-Sector**

តារាងទី៣០: **2007 Provincial Program Support Financing**

តារាងទី៣១: **2007 ExCom Unit Budgets**

តារាងទី៣២: **2007 ExCom Staffing and Analysis**

តារាងទ៣៣: **2007 National Ministry Services Donors**

តារាងទី៣៤: **2007 National Ministry Support Services**

តារាងទី៣៥: **2007 NCDD Program Support Team Resources**

តារាងទី៣៦: **2007 NCDD Program Support Team Budget**

តារាងទី៣៧: **2007 External Technical Cooperation Donors**

តារាងទី៣៨: **Breakdown of Technical Assistance by Category**

តារាងទី៣៩: **Summary of 2007 Work Plan and Budget Agreements**

## ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី ១ 2007 Annual Calendar

ឧបសម្ព័ន្ធទី ២ 2007 NCDD Indicative Work Plan

ឧបសម្ព័ន្ធទី ៣ 2007 NCDD Program Support Team Consultancy Plan

ឧបសម្ព័ន្ធទី ៤ 2007 Commune/Sangkat Fund Allocations

# បញ្ជីពាក្យកាត់

| | |
|---|---|
| ADMAC | អភិវឌ្ឍន៍កសិកម្មនៅក្នុងតំបន់រងគ្រោះដោយសារគ្រាប់មីននៃប្រទេសកម្ពុជា |
| AWPB | ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ |
| CAR | ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល |
| CAU | ផ្នែកគ្រប់គ្រងកិច្ចសន្យា (នៃគណៈកម្មាធិប្រតិបត្តិនៃគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត) |
| CBRD | អភិវឌ្ឍជនបទនៅសហគមន៍មូលដ្ឋាន |
| CCDP | គំរោងអភិវឌ្ឍន៍របស់ក្រុមប្រឹក្សាឃុំ |
| CIP | កម្មវិធីវិនិយោគឃុំ សង្កាត់ |
| CS | ឃុំ សង្កាត់ |
| DDLG | អភិបាលកិច្ចមូលដ្ឋាន និង អភិវឌ្ឍន៍លទ្ធិប្រជាធិបតេយ្យ |
| DIW | សិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុក |
| DoLA | នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន |
| DOP | មន្ទីរផែនការ |
| DSP | កម្មវិធីវិសហមជ្ឈការតាមវិស័យ |
| ExCom | គណៈកម្មាធិការប្រតិបត្តិ (នៃគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត) |
| FU | ផ្នែកហិរញ្ញវត្ថុ (នៃគណៈកម្មាធិប្រតិបត្តិនៃគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត) |
| GTZ | ទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសអាឡឺម៉ង់ |
| IFAD | មូលនិធិអន្តរជាតិ ដើម្បីអភិវឌ្ឍន៍កសិកម្ម |
| LAU | ផ្នែករដ្ឋបាលមូលដ្ឋាន |
| M&E | តាមដានត្រួតពិនិត្យ និងវាយតំលៃ |
| MLMUPC | ក្រសួងរៀបចំដែនដី និងនគរូបនីយកម្ម |
| MoI | ក្រសួងមហាផ្ទៃ |
| MRD | ក្រសួងអភិវឌ្ឍន៍ជនបទ |
| NCDD | គណៈកម្មាធិការជាតិដឹកនាំការងារកំណែទំរង់វិមជ្ឈការ និងវិសហមជ្ឈការ (គជវវ) |
| NCDDS | លេខាធិការដ្ឋានគណៈកម្មាធិការជាតិដឹកនាំការងារកំណែទំរង់វិមជ្ឈការ និងវិសហមជ្ឈការ |
| NCDD/PST | ក្រុមគាំទ្រកម្មវិធីនៃគណៈកម្មាធិការជាតិដឹកនាំការងារកំណែទំរង់វិមជ្ឈការ និងវិសហមជ្ឈការ |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |
| NREM | គំរោងគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន |
| NRML | គំរោងទ្រទ្រង់ជីវភាព និងគ្រប់គ្រងធនធានធម្មជាតិ |
| PIF | មូលនិធិវិនិយោគខេត្ត |
| PRDC | គណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត (គអជខ) |
| PSDD | គំរោងអភិវឌ្ឍន៍លទ្ធិប្រជាធិបតេយ្យតាមរយៈវិមជ្ឈការ និងវិសហមជ្ឈការ |
| PSU | អង្គភាពគាំទ្រគំរោង |
| RGC | ព្រះរាជាណាចក្រកម្ពុជា |
| RILG | គំរោងអភិបាលកិច្ចមូលដ្ឋាន និងវិនិយោគជនបទ |

| | |
|---|---|
| RPRP | គំរោងកាត់បន្ថយភាពក្រីក្រនៅជនបទ |
| RULIP | គំរោងកែលំអជីវភាពនៅជនបទ |
| SIDA | ទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៏អន្តរជាតិប្រទេសស៊ុយអែត |
| TSSL | គំរោងនិរន្តរភាពជីវភាពជុំវិញទន្លេសាប |
| TSU | ផ្នែកគាំទ្របច្ចេកទេស |
| UNDP | កម្មវិធីអភិវឌ្ឍន៏អង្គការសហប្រជាជាតិ |
| UNICEF | មូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ |

# ផែនការសកម្មភាព និងថវិកា គជវវ ២០០៧

## ១. រចនាសម្ព័ន្ធថវិកា នៃផែនការសកម្មភាពនិងថវិកា គជវវ

ដោយផ្តោតតាមការចាត់កម្មវិធីលើធនធាន ដែលបានមកពីគ្រប់ប្រភព រចនាសម្ពន្ធ័ថវិកានៃ ផែនការសកម្មភាព និងថវិកា គជវវ ២០០៧ ត្រូវបានចែកចេញជាប្រភេទនានាដូចខាងក្រោមៈ

### ១.១ ឃុំ សង្កាត់

**មូលនិធិឃុំ សង្កាត់:** មូលនិធិឃុំសង្កាត់ ដែលបង្កើតឡើងដោយ អនុក្រឹត្យមួយនៃរាជរដ្ឋាភិបាលកម្ពុជា កាលពីខែកុម្ភៈឆ្នាំ២០០២ ត្រូវបានគាំទ្រមូលធនដោយហិរញ្ញប្បទានពីថវិកាជាតិ និងការរួមចំណែកពីមូលនិធិនានាពីខាងក្រៅ។ មូលនិធិនេះត្រូវបានវិភាជន៍ជារៀងរាល់ឆ្នាំតាមរូបមន្តប្រកបដោយតំលាភាព ផ្ទេរទៅចូលគណនី ឃុំសង្កាត់ ដែលស្ថិតក្នុងរតនាគារខេត្តក្រុង បន្ទាប់មកត្រូវចាត់ចែងប្រើប្រាស់ដោយក្រុមប្រឹក្សាឃុំសង្កាត់ ទៅលើការវិនិយោគអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ចមូលដ្ឋាន និងគាំទ្រកិច្ចការរដ្ឋបាលឃុំសង្កាត់ ដោយផ្អែកតាមកម្មវិធីវិនិយោគ ឃុំសង្កាត់ និងសេចក្តីណែនាំនានាដែលពាក់ពន្ធ័នឹងមូលនិធិនេះផ្ទាល់។ នៅថ្នាក់ជាតិ មូលនិធិឃុំសង្កាត់ ត្រូវបានចាត់ចែង សំរបសំរួល ដោយនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រោមការត្រួតពិនិត្យរួមនៃ គជវវ។

**មូលនិធិឃុំគោលដៅ:** នៅក្នុងក្របខណ្ឌ គជវវ ប្រភេទមូលនិធិនេះ សំដៅលើធនធាននានាដែលត្រូវបានវិភាជន៍បន្ថែម ទៅឱ្យឃុំគោលដៅមួយចំនួន ក្រៅពីថវិកាដែលវិភាជន៍តាមរយៈមូលនិធិឃុំសង្កាត់រួចហើយ។ ថវិកាទាំងនេះ រួមមានភាគខ្លះមិនកំណត់លក្ខ័ខណ្ឌ និងខ្លះទៀតភ្ជាប់ជាមួយទិសដៅអភិវឌ្ឍន៍ជាក់លាក់ ដោយមានចែងនៅក្នុង អនុសារណៈព្រមព្រៀងជាមួយម្ចាស់ជំនួយ ហើយស្របគ្នាជាមួយអាទិភាពរបស់ឃុំសង្កាត់។

### ១.២ ស្រុក ខណ្ឌ

**មូលនិធិពង្រឹងតួនាទីស្រុកខណ្ឌ:** ដោយផ្អែកតាមសេចក្តីណែនាំដាក់ចេញកាលពីឆ្នាំ២០០៦ ដោយក្រសួងមហាផ្ទៃ ថវិកាប្រភេទនេះ សំដៅលើធនធានដែលវិភាជន៍ឱ្យទៅគណៈកម្មាធិការអភិវឌ្ឍន៍ស្រុកខណ្ឌ ដែលមានមេឃុំចៅសង្កាត់ និងប្រធានការិយាល័យជុំវិញស្រុក ជាសមាជិក និងមានអភិបាលស្រុកខណ្ឌជាប្រធាន។ ធនធាននឹងត្រូវបានចាត់ចែងដោយ គណៈកម្មាធិការអភិវឌ្ឍន៍ស្រុកខណ្ឌ ដើម្បីគាំទ្រសេវា និងការវិនិយោគជាអាទិភាពនានា ដែលមានលក្ខណៈ អន្តរៈឃុំហើយត្រូវបានរកឃើញតាមរយៈដំណើរការផែនការមូលដ្ឋាន។ ការវិនិយោគទាំងនេះ ត្រូវបានដាក់បញ្ចូល ទៅក្នុងផែនការសកម្មភាពស្រុក ដែលមានចុះអនុសារណៈព្រមព្រៀងជាមួយ គអជខ និងត្រូវអនុវត្តតាមការចុះ កិច្ចសន្យាបន្តជាមួយ គណៈកម្មការអន្តរឃុំ ការិយាល័យជំនាញថ្នាក់ស្រុក អង្គការក្រៅ រដ្ឋាភិបាល ក្រុមហ៊ុនឯកជន ឬ ជាមួយបណ្តាមន្ទីរជំនាញថ្នាក់ខេត្ត ក្នុងករណីដែលមិនអាចរកភាគីផ្តល់សេវា នៅក្នុង ស្រុកបាន។

## ១.៣ ខេត្ត ក្រុង

**មូលនិធិវិនិយោគខេត្ត:** មូលនិធិនេះត្រូវបានចាត់ជាកញ្ចប់ថវិកាដាច់ៗគ្នា វិភាជន៍ឱ្យទៅអាជ្ញាធរខេត្តក្រុងនិមួយៗ ដែល ទទួលចាត់កម្មវិធី និងវិភាជន៍បន្តតាមរយៈការចុះអនុកិច្ចសន្យា ទៅឱ្យបណ្តាមន្ទីរជំនាញជុំវិញខេត្ត ហើយ មន្ទីរទាំងនោះ ចាត់ចែងផ្តល់ជាសេវា និងការវិនិយោគផ្សេងៗ ឆ្លើយតបតាមអាទិភាពនានាដែលលើកឡើងដោយ ក្រុមប្រឹក្សាឃុំ សង្កាត់ និងសាម៉ីមន្ទីរផ្ទាល់ និងដោយអនុលោមតាមគោលនយោបាយជាតិដែលទាក់ទងនឹង វិសយ័ និមួយៗផងដែរ។

**កម្មវិធីវិសហមជ្ឈការវិសយ័នៅថ្នាក់ជាតិ:** មូលនិធិនេះរួមមានធនធានដែលចាត់កម្មវិធីតាមរយៈអនុសារណៈនៃ កិច្ច ព្រមព្រៀង រវាងក្រសួងនានានៅថ្នាក់ជាតិផ្ទាល់ ជាមួយដៃគូម្ចាស់ជំនួយ ដែលមានកំណត់ជាស្រេច នូវ យុទ្ធសាស្រ្តនានា ហើយដោយធ្វើប្រតិភូកម្មបន្តទៅឱ្យថ្នាក់ខេត្ត នូវការទទួលខុសត្រូវធ្វើផែនការលំអិត និងអនុវត្ត មូលនិធិនេះ ក្រោម ការសម្របសម្រួលទូទៅពីក្រសួងសាម៉ី។

**មូលនិធិគាំទ្រកម្មវិធីថ្នាក់ខេត្ត:** ការគាំទ្រកម្មវិធីតាមខេត្តក្រុងនានា ត្រូវបានកំណត់ជាកញ្ចប់ធនធានដោយឡែក វិភាជន៍ទៅឱ្យខេត្តក្រុង ដើម្បីបង្កលក្ខណៈឱ្យគណៈកម្មាធិការប្រតិបត្តិខេត្តក្រុង អាចគ្រប់គ្រង និងចាត់ចែង ប្រកប ដោយប្រសិទ្ធិភាព នូវការអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំ អនុវត្តភារកិច្ចផ្សេងៗដែលថ្នាក់ជាតិប្រគល់ឱ្យ ក្នុងការ គាំទ្រដំណើការវិមជ្ឈការវិសហមជ្ឈការ។ ភារកិច្ចទាំងនោះមានដូចជា ការគាំទ្រនិងពង្រឹងសមត្ថភាព ក្រុមប្រឹក្សានិង ស្មៀនឃុំសង្កាត់ ចាត់ចែងត្រួតពិនិត្យវាយតំលៃនិងរាយការ លើអនុកិច្ចសន្យារបស់មន្ទីរនានា គ្រប់គ្រងហិរញ្ញវត្ថុ និង ដឹកនាំកិច្ចប្រតិបត្តការទូទៅនៅថ្នាក់ខេត្ត។

**កិច្ចសហប្រតិបត្តិការបច្ចេកទេសនៅថ្នាក់ខេត្ត:** ធនធាននេះ រួមមានសេវាទីប្រឹក្សាបច្ចេកទេស សម្រាប់គាំទ្រ កិច្ចពង្រឹងសមត្ថភាពគ្រប់គ្រង និងសមត្ថភាពអនុវត្តតួនាទីផ្សេងៗទៀតដូចមានរៀបរាប់ខាងលើ ជួយបង្កើន តម្លាភាព និង គណនេយ្យភាព និងជួយអភិវឌ្ឍន៍បណ្តាញភាពជាដៃគូដើម្បីគាំទ្រអភិបាលកិច្ចនិងកិច្ចអភិវឌ្ឍន៍។ ធនធាននេះត្រូវបាន ចែកជាពីរប្រភេទគឺ ជំនួយបច្ចេកទេសជាតិ និងអន្តរជាតិ។

## ១.៤ ថ្នាក់ជាតិ

**សេវាក្រសួងថ្នាក់ជាតិ:** នេះគឺជាធនធានដែលបានវិភាជន៍ឱ្យក្រសួងនានានៅថ្នាក់ជាតិ ផ្អែកតាមផែនការសកម្មភាព និងថវិកា ដែលផ្តោតលើការគាំទ្រដំណើរការតាក់តែងគោលនយោបាយ លិខិតបទដ្ឋាន និងយុទ្ធសាស្រ្តផ្សេងៗ

ពង្រឹង សមត្ថភាពអាជ្ញាធរថ្នាក់ខេត្ត ព្រមទាំងពង្រឹងដល់តួនាទីថ្នាក់ជាតិ ក្នុងកិច្ចការតំរង់ទិស សម្របសម្រួល ត្រួតពិនិត្យ វាយតំលៃ និងសវនកម្ម។

**គាំទ្រកម្មវិធីថ្នាក់ជាតិៈ** រួមមានធនធាននានា ដែលត្រូវបានវិភាជន៍សំរាប់គាំទ្រ គជវវ ផ្ទាល់ ជាពិសេសគាំទ្រដល់ អគ្គលេខាធិការដ្ឋាន និងក្រុមគាំទ្រកម្មវិធី ក្នុងការចាត់ចែងសម្របសម្រួលកម្មវិធី ត្រួតពិនត្យវាយតំលៃនិងរៀបចំរបាយការ គ្រប់គ្រងហិរញ្ញវត្ថុ គាំទ្រប្រតិបត្តិការ និងការតាក់តែងគោលនយោបាយ និងកម្មវិធី។

**កិច្ចសហប្រតិបត្តិការបច្ចេកទេសថ្នាក់ជាតិៈ** រួមមានសេវាទីប្រឹក្សាបច្ចេកទេសនានា ដែលផ្តល់ឱ្យទៅក្រសួងមួយចំនួន និង គជវវ សំរាប់ជួយគាំទ្រដល់ការងារ អភិបាលកិច្ច អភិវឌ្ឍន៍ ដឹកនាំកម្មវិធី តាក់តែងគោលនយោបាយ និងពង្រឹង ពង្រីកបណ្តាញដៃគូអភិវឌ្ឍន៍នៅថ្នាក់ជាតិ។ ធនធាននេះបែងចែកជា សេវាទីប្រឹក្សាជាតិ អន្តរជាតិ និងសេវាសិក្សានិង ពិគ្រោះយោបល់។

## ២. ទិសាលភាពគ្របដណ្តប់និងបណ្តាញដៃគូ នៃផែនការសកម្មភាព គជវវ ២០០៧

ផែនការសកម្មភាព និងថវិកា គជវវ ២០០៧ ជាការឆ្លុះបញ្ចាំងរួមគ្នា នូវមូលនិធិឃុំសង្កាត់នៃរាជរដ្ឋាភិបាលកម្ពុជា និងគំរោងអភិវឌ្ឍន៍ជាដៃគូចំនួន១៦ ផ្សេងទៀត ដែលកំពុងគាំទ្រទិសដៅអភិបាលកិច្ចនិង អភិវឌ្ឍន៍មូលដ្ឋាន នៃក្របខណ្ឌវិមជ្ឈការ និងវិសហមជ្ឈការ។ ថ្វីបើគំរោងទាំងអស់នោះ មិនត្រូវបានរៀបចំឡើងរួមគ្នាក្នុងទិដ្ឋភាពជាក្របខណ្ឌរួមតែមួយ ហើយត្រូវគ្រប់គ្រងដោយស្ថាប័នថ្នាក់ជាតិផ្សេងៗគ្នាក្តី ក៏ការអនុវត្តនៅថ្នាក់ក្រោមជាតិមានភាព ចុះសម្រុងគ្នាក៏រិតខ្ពស់ ទាំងលើការធ្វើផែនការ និងអនុវត្ត។ ប្រការនេះត្រូវបានបញ្ជាក់ឱ្យឃើញកាន់តែច្បាស់ តាមរយៈ ថវិកាប្រមាណ ៩៣% នៃធនធានសរុបរបស់ គជវវ ដែលផ្ទេរទៅថ្នាក់ក្រោមជាតិ សុទ្ធតែត្រូវបានគ្រប់គ្រងដោយ គណៈកម្មាធិការប្រតិបត្តិខេត្តក្រុង ដោយអនុលោមតាម និតិវិធី និងប្រពន្ធ័ការងារដែលកំណត់ដោយ គជវវ។ នៅ ទំព័របន្ទាប់នេះ មានបង្ហាញនូវ ដ្យាក្រាមស្តីពី សេវាគ្របដណ្តប់ និងបណ្តាដៃគូអភិវឌ្ឍន៍ នៅថ្នាក់ខេត្ត ដែលស្ថិតក្រោម ក្របខណ្ឌផែនការសកម្មភាព និងថវិកា គជវវ ២០០៧។ ដូចមានបង្ហាញក្នុង តារាងស្រាប់ ក្នុងខេត្តក្រុង និមួយៗ មាន ដៃគូអភិវឌ្ឍន៍ចូលរួមសហការ ជាមធ្យម ចំនួន៥ភាគី។

## ៣. ធនធានឆ្នាំ២០០៧ៈ លទ្ធភាព និង ការរៀបចំបែងចែក

ដោយរួមបញ្ចូលទាំងថវិកាសម្រាប់មូលនិធិឃុំសង្កាត់ផងនោះ ធនធានសរុបប្រមាណ៥៩លានដុល្លា ត្រូវបានកៀងគរ ពីថវិកាជាតិ និងដៃគូអភិវឌ្ឍន៍នានា ព្រមទាំងបានដាក់បញ្ចូលទៅក្នុង ផែនការសកម្មភាព និងថវិកានៃ គជវវ ប្រចាំឆ្នាំ២០០៧។ **តារាងទី១ (ចំនួនសរុបថវិកាដែលមានក្នុងឆ្នាំ២០០៧)** បានបង្ហាញធនធានដែលមានទៅតាម ប្រភពនិមួយៗ គិតជាដុល្លាអាមេរិក ។

| តារាងទី១: ចំនួនសរុបថវិការដែលមានក្នុងឆ្នាំ២០០៧ | | | |
|---|---|---|---|
| **ល.រ** | **ប្រភពធនធាន** | **ចំនួន** | **%** |
| **1** | រាជរដ្ឋាភិបាលកម្ពុជា | **22,079,850** | **37.3%** |
| **2** | **PSDD** | **9,961,905** | **16.8%** |
| **3** | **WB/RILG** | **6,396,724** | **10.8%** |
| 4.1 | IFAD/RPRP | 3,975,852 | 6.7% |
| 4.2 | IFAD/CBRD | 1,137,218 | 1.9% |
| 4.3 | IFAD/RULIP | 1,192,157 | 2.0% |
| **4** | **IFAD TOTAL** | **6,305,227** | **10.7%** |
| 5.1 | ADB/CCDP2 | 2,710,000 | 4.6% |
| 5.2 | ADB/TSSL | 2,845,012 | 4.8% |
| **5** | **ADB TOTAL** | **5,555,012** | **9.4%** |
| **6** | **DANIDA/DFID NRM&L** | **5,399,894** | **9.1%** |
| 7.1 | EC/UNDP:DDLG | 2,888,983 | 4.9% |
| 7.2 | EC/UNDP:EFMP | 1,136,650 | 1.9% |
| **7** | **EC/UNDP TOTAL** | **4,025,633** | **6.8%** |
| **8** | **UNICEF/SK** | **2,816,457** | **4.8%** |
| **9** | **CANADA (ADMAC&IFSN)** | **1,196,975** | **2.0%** |
| **10** | **USAID/PACT:LAAR** | **265,000** | **0.4%** |
| **11** | **GERMANY** | **600,000** | **1.0%** |
| **12** | **UNFPA** | **175,501** | **0.3%** |
| **13** | **NGO/GRET** | **69,000** | **0.1%** |
| | **សរុប** | **$59,164,178** | **100.0%** |

## តំបន់គ្របដណ្តប់របស់ម្ចាស់ជំនួយ និងដៃគូនៅថ្នាក់ខេត្តដែលស្ថិតនៅក្រោមក្របខ័ណ្ឌផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ គជវវ តាមខេត្តនិមួយៗ

| ល.រ | ខេត្ត/ក្រុង | RGC | PSDD | WB | IFAD | | | ADB | | DAN/UK | EC-UNDP | | UNICEF | CIDA | US | GTZ | UNFPA | # |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | CBRD | RPRP | RULIP | CCDP | TSLI | NRML | DDLG | EFMP | SK | | LAAR | | | |
| ០១ | បន្ទាយមានជ័យ | | | | | | | | | | | | | | | | | ៥ |
| ០២ | បាត់ដំបង | | | | | | | | | | | | | | | | | ៨ |
| ០៣ | កំពង់ចាម | | | | | | | | | | | | | | | | | ៧ |
| ០៤ | កំពង់ឆ្នាំង | | | | | | | | | | | | | | | | | ៥ |
| ០៥ | កំពង់ស្ពឺ | | | | | | | | | | | | | | | | | ៥ |
| ០៦ | កំពង់ធំ | | | | | | | | | | | | | | | | | ៧ |
| ០៧ | កំពត | | | | | | | | | | | | | | | | | ៤ |
| ០៨ | កណ្តាល | | | | | | | | | | | | | | | | | ៥ |
| ០៩ | កោះកុង | | | | | | | | | | | | | | | | | ៤ |
| ១០ | ក្រចេះ | | | | | | | | | | | | | | | | | ៦ |
| ១១ | មណ្ឌលគីរី | | | | | | | | | | | | | | | | | ៣ |
| ១២ | ភ្នំពេញ | | | | | | | | | | | | | | | | | ៣ |
| ១៣ | ព្រះវិហារ | | | | | | | | | | | | | | | | | ៤ |
| ១៤ | ព្រៃវែង | | | | | | | | | | | | | | | | | ៧ |
| ១៥ | ពោធិសាត់ | | | | | | | | | | | | | | | | | ៦ |
| ១៦ | រតនះគីរី | | | | | | | | | | | | | | | | | ៥ |
| ១៧ | សៀមរៀប | | | | | | | | | | | | | | | | | ៦ |
| ១៨ | ក្រុងព្រះសីហនុ | | | | | | | | | | | | | | | | | ៤ |
| ១៩ | ស្ទឹងត្រែង | | | | | | | | | | | | | | | | | ៣ |
| ២០ | ស្វាយរៀង | | | | | | | | | | | | | | | | | ៧ |

| | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២១ | តាកែវ | | | | | | | | | | | | | | | | | ៦ |
| ២២ | ឧត្តរមានជ័យ | | | | | | | | | | | | | | | | | ៤ |
| ២៣ | ក្រុងកែប | | | | | | | | | | | | | | | | | ៣ |
| ២៤ | ក្រុងប៉ៃលិន | | | | | | | | | | | | | | | | | ៤ |
| | **សរុបខេត្ត/ក្រុង** | **២៤** | **២៤** | **១៤** | **២** | **២** | **៣** | **N/A** | **៦** | **១០** | **១០** | **១** | **៦** | **៣** | **៨** | **២** | **៥** | |

ផ្អែកតាមរចនាសម្ព័ន្ធថវិកា គជវវ ដូចដែលបានពិពណ៌នានៅក្នុងផ្នែកទី២ខាងលើ **តារាងទី២: ការរៀបចំបែងចែកធនធានឆ្នាំ២០០៧** បានឆ្លុះបញ្ចាំងអំពីការរៀបចំបែងចែកធនធានតាមទីងសមាសភាគថវិកានិមួយៗ របស់ថ្នាក់ជាតិ ខេត្តក្រុង ស្រុកខ័ណ្ឌ និងឃុំសង្កាត់ ។

| **តារាងទី២: ការរៀបចំបែងចែកធនធានឆ្នាំ២០០៧** | | |
|---|---|---|
| **សមាសភាព** | **ចំនួន** | **%** |
| មូលនិធិឃុំ សង្កាត់ | 21,841,463 | 37% |
| ឃុំ សង្កាត់គោលដៅ | 6,142,592 | 10% |
| **សរុបសម្រាប់ឃុំ សង្កាត់** | **27,984,055** | **47%** |
| ស្រុក ខ័ណ្ឌ | **3,817,895** | **6%** |
| មូលនិធិវិនិយោគខេត្ត ក្រុង | 4,704,930 | 8% |
| កម្មវិធីវិស័យជាតិ | 6,780,531 | 11% |
| គាំទ្រកម្មវិធីខេត្ត ក្រុង | 4,802,559 | 8% |
| ជំនួយបច្ចេកទេសថ្នាក់ខេត្ត ក្រុង | 2,563,122 | 4% |
| **សរុបសម្រាប់ខេត្ត ក្រុង** | **18,851,142** | **32%** |
| សេវាកម្មក្រសួងថ្នាក់ជាតិ | 3,219,163 | 5% |
| គាំទ្រកម្មវិធីថ្នាក់ជាតិ | 912,960 | 2% |
| ចំនួយបច្ចេកទេសថ្នាក់ជាតិ | 2,839,611 | 5% |
| ទីប្រឹក្សា/ការសិក្សាផ្សេងៗ | 1,539,352 | 3% |
| **សរុបសម្រាប់ថ្នាក់ជាតិ** | **8,511,086** | **14%** |
| **សរុប** | **$59,164,178** | **100%** |

បង្ហាញក្នុងទិដ្ឋភាពមួយផ្សេងទៀត **តារាងទី៣: ការរៀបចំបែងចែកធនធានឆ្នាំ២០០៧** បានឆ្លុះបញ្ចាំង អំពីការបែងចែកធនធានទៅតាមផ្នែកវិនិយោគ គាំទ្រកម្មវិធី និងផ្នែកសហប្រតិបត្តិការបច្ចេកទេស ។

| **តារាងទី៣: ការរៀបចំបែងចែកធនធានឆ្នាំ២០០៧** | | |
|---|---|---|
| **សមាសភាព** | **ចំនួន** | **%** |
| មូលនិធិឃុំ សង្កាត់ | 21,841,463 | 37% |
| ឃុំ សង្កាត់គោលដៅ | 6,142,592 | 10% |
| ស្រុក | 3,817,895 | 6% |
| មូលនិធិវិនិយោគខេត្ត ក្រុង | 4,704,930 | 8% |
| កម្មវិធីវិស័យថ្នាក់ជាតិ | 6,780,531 | 11% |
| សេវាកម្មក្រសួងថ្នាក់ជាតិ | 3,219,163 | 5% |
| **សរុបវិនិយោគ** | **46,506,574** | **75%** |
| គាំទ្រកម្មវិធីខេត្ត ក្រុង | 4,802,559 | 8% |

| | | |
|---|---|---|
| គាំទ្រកម្មវិធីថ្នាក់ជាតិ | 912,960 | 2% |
| **សរុបលើការគាំទ្រកម្មវិធី** | **5,715,519** | **10%** |
| សហប្រតិបត្តិការបច្ចេកទេស-ខេត្ត ក្រុង | 2,563,122 | 4% |
| សហប្រតិបត្តិការបច្ចេកទេស-ថ្នាក់ជាតិ | 2,839,611 | 5% |
| ការសិក្សា/ទីប្រឹក្សា | 1,539,352 | 3% |
| **សរុបសហប្រតិបត្តិការបច្ចេកទេស** | **6,942,085** | **12%** |
| **សរុប** | **$59,164,178** | **100%** |

ក្នុងការវិភាគថវិកា នៃផែនការសកម្មភាពនិងថវិកាឆ្នាំ២០០៧ របស់ គជវវ ដោយប្រៀបធៀបទៅនឹង ផែនការសកម្មភាពនិងថវិកាឆ្នាំ២០០៦ របស់កម្មវិធីសិលានោះ មានកំណត់សំគាល់ដូចខាងក្រោមៈ

- **សរុបសង្ខេបៈ** ការធនធានសរុបនៃផែនការសកម្មភាពនិងថវិកា គជវវ ២០០៧ កើនឡើង៣០% ស្មើនឹង ១៣លានដុល្លា ធៀបទៅនឹងធនធានសរុបនៃផែនការសកម្មភាពនិងថវិកា២០០៦ របស់កម្មវិធីសិលា។ ការកើននេះគឺដោយសារ កំណើននៃមូលនិធិវិនិយោគឃុំសង្កាត់សរុប និង ដោយសារការដាក់បញ្ចូលនូវគំរោងដៃគូម្ចាស់ជំនួយមួយចំនួនទៀត ដែលបានចុះហត្ថលេខាដោយផ្ទាល់ជាមួយក្រសួងមហាផ្ទៃ រួមគ្នាជាមួយគំរោងនានា ដែលធ្លាប់បានអនុវត្តដោយកម្មវិធីសិលា កន្លងមក ក្នុងក្របខ័ណ្ឌផែនការ សកម្មភាពនិងថវិកាប្រចាំឆ្នាំតែមួយ ។
- **មូលនិធិឃុំ សង្កាត់ៈ** មូលនិធិឃុំ សង្កាត់ឆ្នាំ២០០៧ បានកើនឡើងចំនួន ១៥% បើប្រៀបធៀបនៅនឹងឆ្នាំ២០០៦ ដោយសារកំណើនថវិកាប្រមាណ៤លានដុល្លា ដែលបានពីការចូលរួមរបស់រាជរដ្ឋាភិបាលកម្ពុជា។
- **ឃុំគោលដៅៈ** ការវិភាជន៍ថវិកាបន្ថែមចំពោះឃុំគោលដៅ ដែលស្ថិតនៅក្រោមគំរោងរបស់ម្ចាស់ជំនួយជាក់លាក់ គឺបានកើនឡើងចំនួន ២,៧លានដុល្លា បើប្រៀបធៀបទៅនឹងឆ្នាំ២០០៦ ពោលគឺកើនឡើងជាង ៨០%។ កំណើននេះ ភាគច្រើនគឺដោយសារការពង្រីកតំបន់គោលដៅរបស់ គំរោង Danida/UK NRML និងដោយសារការដាក់រួមបញ្ចូលនូវ គំរោងពីររបស់ ADB គឺគំរោង CCDP2 និង TSSL ។
- **សរុបធនធានឃុំៈ** ការដាក់រួមបញ្ចូលគ្នានូវផ្នែកទាំងពីរខាងលើ បង្ហាញថា ធនធានសរុបដែលបានវិភាជដល់ ក្រុមប្រឹក្សា ឃុំសង្កាត់ បានកើនឡើងចំនួន ៥,៦ លានដុល្លា ធៀបទៅនឹងឆ្នាំ២០០៦។
- **ស្រុក ខណ្ឌៈ** ដោយមានការពង្រីក កម្មវិធីពង្រឹងតួនាទីស្រុក ពី២៤ ទៅ១៣៨ ស្រុកគោលដៅនោះថវិកាបន្ថែម ចំនួន៣,៣លានដុល្លា ត្រូវបានវិភាជសំរាប់ស្រុកទាំងនោះ ហើយបានធ្វើឱ្យធនធានស្រុកកើនឡើង ៦ដង ធៀបទៅនឹងឆ្នាំ២០០៦។
- **ការវិនិយោគខេត្តៈ** តាមការដាក់បញ្ចូលគ្នានូវមូលនិធិវិយោគខេត្តទាំងពីរប្រភេទ រួមជាមួយកម្មវិធីវិស័យវិសហមជ្ឈការនោះ ធនធានសរុបសំរាប់វិនិយោគខេត្តបានកើនឡើង ១,១លានដុល្លា ឬ១១% ធៀបទៅ

នឹងឆ្នាំ២០០៦។ ទោះជាយ៉ាងនេះក្តី ការវិភាជន៍ចំពោះមូលនិធិវិនិយោគខេត្ត ដែលចំណុះក្រោមឆន្ទានុសិទ្ធរបស់ខេត្តនោះ ត្រូវបានរក្សាឱ្យ នៅប្រហាក់ប្រហែលឆ្នាំមុនដដែល ។

- **សេវាក្រសួងថ្នាក់ជាតិ:** ការវិភាជន៍ថវិកាចំពោះក្រសួងថ្នាក់ជាតិ នៅក្នុងក្របខ័ណ្ឌផែនការសកម្មភាពនិងថវិកា គជវវ ឆ្នាំ២០០៧ មានការកើនឡើង៣ដង ស្មើនឹង ២លានដុល្លា។ ស្មើតែទាំងមូលនៃកំណើននេះត្រូវបានវិភាជន៍ទៅឱ្យ អង្គភាពគាំទ្រគំរោងនានា នៅថ្នាក់ជាតិ ដោយរក្សាបរិមាណធនធាន ដែលចំណុះក្រោមឆន្ទានុសិទ្ធក្រសួង នៅស្មើរតែដូចមុនដដែល។
- **ការគាំទ្រកម្មវិធីថ្នាក់ខេត្ត:** ជាទូទៅ មានការថយចុះប្រមាណ៥% លើថវិកាវិភាជន៍ឱ្យការគាំទ្រកម្មវិធីថ្នាក់ខេត្ត ដែលប្រហាក់ប្រហែលនឹង២៥០,០០០ដុល្លា។ ដោយមានកំណើនថវិកាចំនួន ១២លានដុល្លាក្នុងហិរញ្ញប្បទានវិនិយោគទៅថ្នាក់ក្រោមជាតិក្នុងឆ្នាំ២០០៧នោះ សមាមាត្រនៃថវិកាគាំទ្រកម្មវិធីខេត្តធៀបទៅនឹង ធនធានវិនិយោគថ្នាក់ក្រោមជាតិ ត្រូវបានបន្ថយពី ១៤%ក្នុងឆ្នាំ២០០៦ មកត្រឹម១០% ក្នុងឆ្នាំ២០០៧ ។

# ៤. រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងម្ចាស់ជំនួយនានា

## ៤.១. រាជរដ្ឋាភិបាលកម្ពុជា

នៅក្នុងតារាងទី៤ បានបង្ហាញថា ធនធានសរុបពីរាជរដ្ឋាភិបាល នៅក្នុងផែនការសកម្មភាពនិងថវិកា គជវវ មានចំនួន២២,១លានដុល្លារ ឬស្មើនឹង ៣៧ភាគរយ នៃធនធានសរុបរបស់នៃផែនការ។ មួយចំណែកធំនៃធនធានតំណាងឱ្យការចូលរួមពីថវិកាជាតិទៅក្នុងមូលនិធិឃុំសង្កាត់ រីឯចំណែកនៅសល់គឺជាថវិកាបដិភាគ លើគម្រោងកម្ចីឥណទានពី IFAD តែប៉ុណ្ណោះ ។

| តារាង ៤: ថវិការាជរដ្ឋាភិបាលកម្ពុជា ២០០៧ | | |
|---|---|---|
| **ប្រភេទ** | **ចំនួន** | **%** |
| **វិនិយោគ** | **21,983,040** | **99.6%** |
| មូលនិធិឃុំ សង្កាត់ | 21,341,463 | 96.7% |
| មូលនិធិឃុំ ផ្សេងទៀត * | 39,533 | 0.2% |
| ខេត្ត * | 602,044 | 2.7% |
| **គាំទ្រកម្មវិធី** * | **96,810** | **0.4%** |
| ថ្នាក់ខេត្ត | 38,353 | 0.2% |
| ថ្នាក់ជាតិ | 58,457 | |
| **សរុប** | **$22,079,850** | **100%** |

*មូលនិធិបដិភាគ IFAD តែប៉ុណ្ណោះ

### ៤.១.១ រាជរដ្ឋាភិបាលៈ មូលនិធិឃុំ សង្កាត់

តាមសេចក្ដីសំរេចរបស់NCSC ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៤ ការវិភាជន៍ថវិកាជាតិទៅក្នុងមូលនិធិឃុំ សង្កាត់ ត្រូវបានកំណត់មិនអោយតិចជាង ២,៥៦ ភាគរយនៃចំណូលក្នុងស្រុក។ ផ្អែកតាមព្យាករណ៍ចំណូលក្នុងស្រុក ការវិភាជន៍មូលនិធិឃុំសង្កាត់ ត្រូវបានកំណត់ ៨៣,៥ពាន់លានរៀល ស្មើនឹង២០.៣៦៥.៨៥៤ដុល្លារ (១ដុល្លារ ស្មើនឹង ៤.១០០រៀល )។ ថវិកាវិភាជន៍បន្ថែមចំនួន ៣.៤៩៤.៨៧២.២០០រៀល (ស្មើនឹង ៨៥២.៤០៨ ដុល្លារ) ត្រូវបានអនុម័តសំរាប់ផ្ដល់ប្រាក់ខែ កើនឡើង ចំពោះប្រធាន និងអនុប្រធានភូមិ ដែលបានជ្រើសរើស ដោយ ក្រុមប្រឹក្សាឃុំសង្កាត់ កាលពីពាក់កណ្ដាលឆ្នាំ២០០៦កន្លងទៅនេះ។ ដូចនេះ ថវិកាបដិភាគសរុបរបស់ រាជរដ្ឋាភិបាល សំរាប់មូលនិធិឃុំ សង្កាត់ឆ្នាំ២០០៧ មានចំនួន៨៦.៩៩៤.៨៧២.០០០រៀល ស្មើនឹង ២១,៣៤លាន ដុល្លារ។ ថវិកានេះបង្ហាញថាមានការកើនឡើង ១៧,៤ពាន់លានរៀល (ស្មើនឹង ៤,២លានដុល្លារ) លើស មូលនិធិឃុំសង្កាត់ ២០០៦។ ដោយមានបដិភាគលើមូលនិធិឃុំសង្កាត់ ពីគម្រោង PSDD សំរាប់ឆ្នាំ ២០០៧នេះ មានចំនួន៥សែនដុល្លារ ធ្វើឱ្យចំនួនសរុបនៃមូលនិធិឃុំសង្កាត់ កើនដល់ ៨៩ពាន់លានរៀល ស្មើនឹង ២១,៧លាន ដុល្លារ (ព័ត៌មានលំអិតអំពីការវិភាជន៍មូលនិធិឃុំ សង្កាត់ សូមមើលផ្នែកទី ៧.១) ។

### ៤.១.២ មូលនិធិបដិភាគរបស់រាជរដ្ឋាភិបាល

ក្រៅពីមូលនិធិឃុំ សង្កាត់ រាជរដ្ឋាភិបាលចូលរួមមូលនិធិបដិភាគអោយកម្មវិធីកម្ចី IFAD សំរាប់៤ខេត្ត មានចំនួន សរុប ៧៤០.០០០ដុល្លារ។ នៅក្នុងតារាងទី៤ខាងលើ បានបង្ហាញនៅក្រោមប្រភេទវិនិយោគនៃមូលនិធិនេះ នូវ មូលនិធិផ្ដល់ឱ្យឃុំគោលដៅ ក្រោមសមាសភាគមូលនិធិអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធឃុំ និងមូលនិធិវិនិយោគ។ មូលនិធិបដិភាគនេះរួមទាំងការចំណាយរបស់គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍន៍ ជនបទខេត្ត ក្រុងនិងក្រុមគាំទ្រកម្មវិធី គជវវ។ មូលនិធិបដិភាគរបស់រាជរដ្ឋាភិបាលភាគច្រើន ដែលផ្ដល់ក្រោមរូបភាពជា អាគារការិយាល័យ ប្រាក់ខែមន្ត្រីរាជការ ចំណាយប្រតិបត្តិការធម្មតា និងការបង់ពន្ធ មិនត្រូវបានគិតបញ្ចូល ទៅក្នុងការគណនា ថវិកានៃ គជវវ ទេ។

### ៤.២. គម្រោងគាំទ្រការអភិវឌ្ឍន៍ប្រជាធិបតេយ្យ តាមរយៈវិមជ្ឈការ និងវិសហមជ្ឈការ (PSDD)

NCDD បានអនុម័តលើ គម្រោងការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ តាមរយៈវិមជ្ឈការ និងវិសហមជ្ឈការ ដែលបានគាំទ្រដោយ ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិប្រទេសអង់គ្លេស ប្រទេសស៊ុយអែត និងកម្មវិធីអភិវឌ្ឍន៍ អង្គការសហប្រជាជាតិ កាលពីថ្ងៃទី២៤ ខែមករា ឆ្នាំ២០០៧ ហើយចាប់ផ្ដើមដំណើរការអនុវត្តពីថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០០៧។ PSDD គឺជាគម្រោងដែលបន្តពីគម្រោង PLG នឹងបន្តផ្ដល់ហិរញ្ញប្បទាន និងការគាំទ្របច្ចេកទេស ដល់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំ គ្រប់គ្រងដោយNCDD តាម បែបប្រតិបត្តិការជាតិ។ ការអនុវត្តគម្រោង គឺស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់ របស់ក្រុមគាំទ្រកម្មវិធី NCDD។

នៅក្នុងតារាងទី៥ ខាងក្រោម បានបង្ហាញពីធនធានថវិកាគម្រោង PSDD ដែលមានចំនួនសរុប ១០.៤លានដុល្លារ សំរាប់ឆ្នាំ ២០០៧ និងបញ្ចូលទៅក្នុងផែនការសកម្មភាព និងថវិកា ដែលអនុម័តដោយ NCDD ។

| **តារាង ៥: ធនធានគម្រោង PSDD ២០០៧** | | |
|---|---|---|
| **ដៃគូអភិវឌ្ឍន៍** | **ចំនួន** | **%** |
| ប្រទេសអង់គ្លេស/DfID | 5,200,000 | 50% |
| ប្រទេសស៊ុយអែត/Sida | 4,000,000 | 38% |
| អង្គការ UNDP | 1,200,000 | 12% |
| **សរុប** | **$10,400,000** | **100%** |

នៅក្នុងតារាងទី៦ បានបង្ហាញពីធនធានបដិភាគរបស់គម្រោង PSDD នៅក្នុងផែនការសកម្មភាព និងថវិកាឆ្នាំ ២០០៧មានចំនួនសរុបប្រហែល ១០ លានដុល្លារ ។ ធនធានបដិភាគរបស់គម្រោង PSDD ឆ្នាំ ២០០៧ មានចំនួន ១៧ ភាគរយ នៃផែនការសកម្មភាព និងថវិកា NCDD និង បានចាត់ចែងដោយ NCDD នៅក្នុងចន្លោះខែ សីហា ដល់ខែធ្នូ តាមរយៈដំណើរប្រជុំពិគ្រោះជាមួយយស្ថាប័នរាជដ្ឋាភិបាលពាក់ព័ន្ធគ្រប់ថ្នាក់ ដោយស្របតាមរូបមន្ត និងលក្ខណៈវិនិច្ឆ័យដែលបានបង្កើតរួចហើយ ។

ការវិភាជន៍ធនធានវិនិយោគ ៥សែនដុល្លារ ទៅក្នុងមូលនិធិឃុំសង្កាត់ និង១.៨លានដុល្លារ ទៅក្នុងមូលនិធិវិនិយោគខេត្ត គឺជាការផ្ទេរមូលនិធិអន្តររដ្ឋបាល ពីរប្រភេទ ដែលផ្តល់សិទ្ធិសម្រេចទាក់ទងទៅនឹង ការចាត់ចែងប្រើប្រាស់ធនធានទៅអោយថ្នាក់ក្រោមជាតិ។ ទោះបីជាមានការរំពឹងទុកថា ហិរញ្ញប្បទានគាំទ្រមូលនិធិឃុំសង្កាត់ គួរទទួលបានការចូលរួមគាំទ្រពីប្រភពផ្សេងៗទៀតក្នុងដំណាក់កាលនេះក្តី គម្រោង PSDD នៅតែជាប្រភពតែមួយគត់ ក្នុងការចូលរួមជាមួយរដ្ឋាភិបាលគាំទ្រមូលនិធិឃុំសង្កាត់។ ចំពោះយុទ្ធសាស្រ្តពង្រឹងតួនាទីថ្នាក់ស្រុកវិញ គម្រោងPSDD នឹងផ្តល់ថវិកា ៣៥០.០០០ដុល្លារ បន្ថែមលើថវិកាបានមកពី ដានីដា ប្រទេសអង់គ្លេស និងសហគមន៍អឺរ៉ុបតាមរយៈ UNDP។ ប្រភេទថវិកាវិភាជន៍ទាំងនេះត្រូវបានបែងចែក ដោយថ្នាក់ជាតិតាមដំណើរការចូលរួម និងគោលការណ៍ដែលបានអនុម័ត។

នៅក្នុងឆ្នាំ ២០០៧នេះ NCDD បានវិភាជន៍ថវិកាចំនួន ៥០០.០០០ដុល្លារ សំរាប់ការគាំទ្រសេវារបស់ក្រសួងសមាជិកនៅថ្នាក់ជាតិចំនួន១២ តាមផែនការសកម្មភាពនិងថវិការបស់ក្រសួងនិមួយៗ ដោយផ្អែកតាម លក្ខណៈវិនិច្ឆ័យ និងអណត្តិរបស់ខ្លួន។ សេវាកម្មរបស់ក្រសួងជាសមាជិក នឹងគ្របដណ្តប់លើអភិបាលកិច្ច និង សកម្មភាព

| តារាង៦ : ថវិកាបដិភាគរបស់គម្រោង PSDD ដល់ផែនការសកម្មភាពនិងថវិកា NCDD 2007 | | | | |
|---|---|---|---|---|
| **ប្រភេទ** | **សរុប PSDD** | **%** | **សរុប NCDD** | **PSDD/ NCDD** |
| **វិនិយោគ** | **3,150,000** | **32%** | **46,506,574** | **7%** |
| មូលនិធិឃុំ | 500,000 | 5% | 21,841,463 | 2% |
| ឃុំគោលដៅ | 0 | 0% | 6,142,592 | 0% |
| វិនិយោគស្រុក | 350,000 | 4% | 3,817,895 | 9% |
| មូលនិធិវិនិយោគខេត្ត | 1,800,000 | 18% | 4,704,930 | 38% |
| កម្មវិធីវិស័យថ្នាក់ជាតិ | 0 | 0% | 6,780,531 | 0% |
| សេវកម្មក្រសួងថ្នាក់ជាតិ | 500,000 | 5% | 3,219,163 | 16% |
| **គាំទ្រកម្មវិធី** | **3,983,369** | **40%** | **5,715,519** | **70%** |
| ថ្នាក់ខេត្ត | 3,336,434 | 33% | 4,802,559 | 69% |
| ថ្នាក់ជាតិ | 646,935 | 6% | 912,960 | 71% |
| **គាំទ្របច្ចេកទេស** | **2,828,536** | **28%** | **6,942,085** | **41%** |
| ទីប្រឹក្សាជាតិប្រចាំថ្នាក់ខេត្ត | 1,590,122 | 16% | 2,159,122 | 74% |
| ទីប្រឹក្សាប្រចាំថ្នាក់ជាតិ | 350,000 | 4% | 1,257,197 | 28% |
| ទីប្រឹក្សាបរទេស | 628,414 | 6% | 1,986,414 | 32% |
| ទីប្រឹក្សាពិគ្រោះយោបល់ | 260,000 | 3% | 1,539,352 | 17% |
| **សរុប** | **$9,961,905** | **100%** | **$59,164,178** | **17%** |

អភិវឌ្ឍន៍ជាច្រើន ដែលទាក់ទងទៅនឹងការកែសម្រួល និងការពង្រឹងនូវគោលនយោបាយ លិខិតបទដ្ឋាននានា និងប្រព័ន្ធ ការត្រួតពិនិត្យ តាមដាន និងវាយតម្លៃលើការបំពេញមុខងាររបស់ថ្នាក់ខេត្តក្រុង និង ឃុំសង្កាត់ ការសម្របសម្រួល និងការអភិវឌ្ឍន៍សមត្ថភាព។ ថវិកាវិភាជន៍របស់គម្រោង PSDD មានចំនួន ៣,៣លាន ដុល្លារ ទៅលើការគាំទ្រកម្មវិធីនៅថ្នាក់ខេត្ត ស្មើនឹង៧១ភាគរយ នៃតម្រូវការថវិកាសរុប របស់គណៈកម្មាធិការប្រតិបត្តិនៃគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្តក្រុងទាំង២៤ ទូទាំងប្រទេស ក្នុងការគាំទ្រមុខងារជាច្រើន ដែលទាក់ទងទៅ នឹងការគ្រប់គ្រង ការសម្របសម្រួល សេវាកម្មហិរញ្ញវត្ថុ និងបច្ចេកទេស ការតាមដាន វាយតម្លៃ ការរៀបចំរបាយការណ៍ និងការកសាងសមត្ថភាព។ សេវាកម្មទាំងនេះ បានផ្តល់អត្ថប្រយោជន៍ដល់ដៃគូអភិវឌ្ឍន៍ នៅក្រោមក្របខ័ណ្ឌផែនការសកម្មភាពនិងថវិការបស់NCDD។ NCDDបានគ្រោងថវិកាសរុបចំនួន ៦៤៧.000 ដុល្លារ សំរាប់លេខាធិការដ្ឋាន និងក្រុមគាំទ្រកម្មវិធីរបស់ខ្លួន លើសកម្មភាពដែលទាក់ទងទៅនឹងការសម្របសម្រួលកម្មវិធី ការតាមដាន ការវាយតម្លៃ និងការរៀបចំរបាយការណ៍ ការអភិវឌ្ឍន៍សមត្ថភាព ក្នុងបរិបទប្រព័ន្ធកម្មវិធីជាតិនានា ការទទួលខុសត្រូវលើការប្រតិបត្តិកិច្ចព្រមព្រៀងហិរញ្ញប្បទាន រវាងរាជរដ្ឋាភិបាល ក្រសួងសមាជិកថ្នាក់ជាតិ និងដៃគូអភិវឌ្ឍន៍។

ការសម្របសម្រួលបច្ចេកទេសនៅក្រោមគម្រោង PSDD រួមមានក្រុមទីប្រឹក្សាប្រចាំ ២៤ ខេត្ត ក្រុង ដើម្បីជួយដល់អភិបាលខេត្តក្រុង គណៈកម្មាធិការប្រតិបត្តិនៃគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្តក្រុង និងមន្ទីរជំនាញ

ជាច្រើន ក្នុងការគ្រប់គ្រងការអនុវត្ត និងការតាមដានលើធនធាន ដែលបានបែងចែកតាមផែនការសកម្មភាព និងថវិកាNCDD និងនៅក្រុមទីប្រឹក្សានៅថ្នាក់ជាតិ ជួយដល់ក្រសួងជាសមាជិកនៅថ្នាក់ជាតិទាំង១២ និង ស្ថាប័នផ្សេងៗទៀត និងលេខាធិការដ្ឋានរបស់NCDD ទៅតាមមុខងារនិងអណត្តិរបស់ខ្លួន។ ក្រុមទីប្រឹក្សាទាំងនេះ ត្រូវធានាអោយមានការតាមដាន ការវាយតម្លៃ ប្រកបដោយប្រសិទ្ធភាព និងគណនេយ្យភាពលើ ផែនការសកម្មភាព និងថវិកា NCDD ប្រសិនបើមានហិរញ្ញប្បទានពីខាងក្រៅច្រើន។ ទីប្រឹក្សាប្រចាំនៅថ្នាក់ខេត្ត ក្រុង នៅក្នុងគម្រោង PSDD សំរាប់ឆ្នាំ ២០០៧ មានចំនួនសរុប ១៣៨នាក់ ឬ គិតជាមធ្យមមានចំនួន ៥.៥ នាក់ ក្នុង១ខេត្ត។ ចំណាយការសម្របសម្រួលបច្ចេកទេសរបស់គម្រោង PSDD នៅថ្នាក់ខេត្ត សំរាប់ឆ្នាំ២០០៧ មានចំនួន ៣.៧% នៃថវិកានៅក្នុងផែនការសកម្មភាពនិងថវិកា NCDD ដែលបានវិភាគទ៏ទៅអោយ ថ្នាក់ក្រោមជាតិ ថវិកានេះមានការថយចុះ បើប្រៀបធៀបទៅនឹងឆ្នាំ ២០០៦។ នៅថ្នាក់ជាតិ មានទីប្រឹក្សាចំនួន ២៨នាក់ ក្នុងនោះមានទីប្រឹក្សា១២នាក់ ត្រូវបានប្រគល់ភារកិច្ចជួយក្រុមគាំទ្រកម្មវិធី NCDD ទីប្រឹក្សា៧នាក់ ជួយនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ លើសកម្មភាពដែលទាក់ទងទៅនឹងឃុំ សង្កាត់ និង ការពង្រឹងតួនាទី ថ្នាក់ស្រុក និងទីប្រឹក្សា ៥នាក់ជួយដល់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងផែនការ។ ទីប្រឹក្សាបរទេសនៅថ្នាក់ជាតិមានចំនួន ៤នាក់ ត្រូវបានប្រគល់ភាកិច្ចជួយ លេខាធិការដ្ឋាន NCDD និងក្រុមគាំទ្រកម្មវិធី និងទីប្រឹក្សាបរទេស ១នាក់ ជួយក្រសួងកសិកម្ម ក្រោមកិច្ចព្រមព្រៀង ចំណាយរួមរវាង IFAD និង UNDP។ ជារួម ធនធាន PSDD ដែលបានវិភាជន៏សំរាប់ កិច្ចសហប្រតិបត្តិការបច្ចេកទេស ឆ្នាំ២០០៧ មានចំនួន២.៨លានដុល្លារ ដោយរាប់ទាំង សេវាការសិក្សាពិគ្រោះយោបល់ មួយចំនួន សម្រាប់ជួយដល់ លេខាធិការដ្ឋាន NCDD និងអគ្គនាយកដ្ឋានរដ្ឋបាលទូទៅក្រសួងមហាផ្ទៃ។ នៅក្នុងថវិកាសរុបនេះដែរ មានថវិកាចំនួន ១២០.០០០ដុល្លារ គ្រោងសំរាប់ការសិក្សាស្រាវជ្រាវ និងការពិគ្រោះយោបល់ផ្សេងៗ ដើម្បីគាំទ្រដល់ការរៀបចំ កម្មវីធីវិមជ្ឈការ និងវិសហមជ្ឈការរបស់រដ្ឋាភិបាល ដែលបានរំពឹងថានឹងអនុវត្តនៅឆ្នាំ ២០០៨ ។

## ៤.៣ ធនាគារពិភពលោកៈ គម្រោងវិនិយោគជនបទ និង អភិបាលកិច្ចមូលដ្ឋាន

យោងតាមកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល និងធនាគារពិភពលោក តួនាទីភ្នាក់ងារអនុវត្តគម្រោងកម្ចីឥណទានចំនួន២៩,៣លានដុល្លារ ត្រូវបានផ្ទេរចេញពីគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា ប្រគល់ទៅជូនNCDD ហើយរយៈពេលអនុវត្តគម្រោង ក៏ត្រូវបានពន្យារពីចុងខែមិថុនា ទៅដល់ចុងខែធ្នូ ឆ្នាំ២០០៧ ផងដែរ។ លើសពីនេះ ដោយគម្រោងPSDD បានព្រមព្រៀង និងធានាបន្តការគាំទ្របច្ចេកទេសដល់គម្រោង RILGP ធនធានបំរុងទុកសំរាប់កិច្ចសហប្រតិបត្តិការ បច្ចេកទេសរបស់គម្រោង RILGP ត្រូវបានបង្វែរទៅប្រើជាប្រភេទវិនិយោគវិញ។

គោលដៅរបស់គម្រោង RILGP គឺចូលរួមកិច្ចអភិវឌ្ឍន៏ជនបទ និង ការកាត់បន្ថយភាពក្រីក្រ តាមរយៈការគាំទ្រដល់ការ ផ្តល់សេវាសាធារណៈជាអាទិភាព នៅថ្នាក់ឃុំសង្កាត់ និងលើកកម្ពស់អភិបាលកិច្ចល្អ តាមរយៈការ

គាំទ្រប្រព័ន្ធអភិបាលកិច្ចមូលដ្ឋានដោយមានការចូលរួម ក្នុងបរិបទវិមជ្ឈការ និងវិសហមជ្ឈការ។ គម្រោងនេះមានសមាសភាគចំនួន ២ :

**សមាសភាគទី១: ផែនការមូលដ្ឋាន និងការវិនិយោគ** គឺជាការគាំទ្រតាមរយៈមូលនិធិឃុំសង្កាត់ ដំណើរការផែនការ នៅថ្នាក់ឃុំសង្កាត់ តាមបែបវិមជ្ឈការ។ ការចំណាយដោយរាជរដ្ឋាភិបាល លើគម្រោងអភិវឌ្ឍន៍ មូលនិធិឃុំសង្កាត់ ត្រូវបានទូទាត់សងវិញពីធនាគាពិភពលោកក្នុងរូមភាពជាឥណទាន ហើយថវិកាដែលទទួលបានពីការទូទាត់សងនេះ រាជរដ្ឋាភិបាលប្រើប្រាស់ដើម្បីបន្តផ្តល់ហិរញ្ញប្បទានដល់មូលនិធិឃុំសង្កាត់។ ថវិកាសរុបត្រូវទូទាត់ពីកម្ចីឥណទាន របស់ធនាគារពិភពលោកក្នុងរយៈពេលអនុវត្តគម្រោង មានចំនួនប្រហែល ២២,៣លានដុល្លារ។ លក្ខណៈវិនិច្ឆ័យ សំរាប់គម្រោងដែលអាចទទួលបានការទូទាត់សង រួមមានតាំងពីទីតាំងគម្រោង (នៅក្នុងខេត្តក្រុងគោលដៅទាំង១៤ចាប់ពីឆ្នាំ២០០៥) លទ្ធផលស្របតាមបញ្ជីគម្រោងដែលកំណត់ដោយធនាគារពិភពលោក ព្រមទាំងស្របតាមបទដ្ឋាននីតិវិធីផ្សេងៗមួយចំនួនទៀត។ នៅត្រឹមដំណាច់ឆ្នាំ២០០៦ កិច្ចសន្យានៅថ្នាក់ឃុំ មានចំនួនសរុប៣.៩០០ ត្រូវប្រើប្រាស់មូលនិធិឃុំសង្កាត់ ប្រមាណ២២,៣លានដុល្លារ ដែលត្រូវបានដាក់ស្នើការទូទាត់ពីធនាគារពិភពលោក ហើយថវិកាទូទាត់បានជាក់ស្តែង មានចំនួនប្រមាណ ១៦,៣លានដុល្លារ។ សមតុល្យចំនួន ៥,៧លានដុល្លារ នឹងត្រូវទូទាត់ក្នុងឆ្នាំ២០០៧ ចំពោះគម្រោងមូលនិធិឃុំសង្កាត់ ដែលរំពឹងថានឹងត្រូវអនុវត្តចប់សព្វគ្រប់នៅក្នុងឆមាសទី១ឆ្នាំ២០០៧នេះ។ ថវិកាដែលបានពីការទូទាត់នេះ រាជរដ្ឋាភិបាលនឹង ប្រើប្រាស់សម្រាប់ចំណាយគម្រោង មូលនិធិឃុំ សង្កាត់ ឆ្នាំ ២០០៧ ។

**សមាសភាគទី២: ការគាំទ្រគោលនយោបាយ និងការគ្រប់គ្រងគម្រោង** គឺជាការគាំទ្រដល់ការការកសាង សមត្ថភាព ជំនួយបច្ចេកទេស លទ្ធកម្មអគារ និងសំភារៈ ឧបករណ៍ ចំណាយប្រតិបត្តិការនៅថ្នាក់ជាតិ ខេត្ត និងឃុំ សំរាប់ការអនុវត្តសមាសភាគ១។ ក្រៅពីនេះ សេវាកម្មទីប្រឹក្សាត្រូវចំណាយសំរាប់គោលបំណងធ្វើការសិក្សាស្រាវជ្រាវយុទ្ធសាស្ត្រ ដែលទាក់ទងទៅកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ការសិក្សាសេដ្ឋកិច្ច សង្គមកិច្ច ការវាយតម្លៃពាក់កណ្តាលការអនុវត្ត និងបញ្ចប់គម្រោង សវនកម្មឯករាជ្យប្រចាំឆ្នាំ។ ថវិកាប្រមាណចំនួន ៣ លានដុល្លារ ត្រូវបានចាត់ចែងសំរាប់សមាសភាគទី២នេះ។

នៅឆ្នាំ២០០៧នេះ ហិរញ្ញប្បទានសំរាប់សមាសភាគទី២ នឹងត្រូវចំណាយលើការកសាងអាគារ គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្តចំនួន២ លទ្ធកម្មម៉ូតូចំនួន ១៣០គ្រឿង និងសេវាទីប្រឹក្សាពិគ្រោះយោបល់មួយចំនួន ដូចបានបង្ហាញនៅក្នុង ឧបសម្ព័ន្ធទី៣: ផែនការសេវាទីប្រឹក្សាពិគ្រោះយោបល់ NCDD និងការគាំទ្រលើការ រៀបចំសិក្ខាសាលាជាតិនានា។

**តារាង ៧: ធនធានគម្រោង RILGP/World Bank** បានបង្ហាញពីការវិភាជន៍មូលនិធិគម្រោង RILGP នៅក្នុងផែនការសកម្មភាពនិងថវិកា ឆ្នាំ២០០៧។ ក្រៅពីថវិកាសំរាប់មូលនិធិឃុំសង្កាត់ មានថវិកាចំនួន ៣៤៧.000ដុល្លារ សំរាប់ការគាំទ្រកម្មវិធីនៅថ្នាក់ជាតិ និងថ្នាក់ខេត្ត ដែលត្រូវបានគ្រោងសំរាប់ ការសាងសង់អាគាររដ្ឋបាល លទ្ធកម្មម៉ូតូ ការរៀបចំសិក្ខាសាលា និងថវិកាបដិភាគសំរាប់សវនកម្មរួមប្រចាំឆ្នាំនៅក្រោមក្រុមគាំទ្រកម្មវិធី។ ថវិកាចំនួន៣៦៧.000ដុល្លារ ផ្សេងទៀត ត្រូវបានគ្រោង សំរាប់សេវាប្រឹក្សាពិគ្រោះយោបល់ និង ការសិក្សាស្រាវជ្រាវផ្សេងៗ ។

| តារាង៧ : ធនធានគម្រោង World Bank/RILG ២០០៧ | | |
|---|---|---|
| **ប្រភេទ** | **ចំនួន** | **%** |
| **វិនិយោគ** | **5,683,000** | **89%** |
| មូលនិធិឃុំ | 5,683,000 | 89% |
| **គាំទ្រកម្មវិធី** | **346,724** | **5%** |
| ថ្នាក់ខេត្ត | 150,000 | 2% |
| ថ្នាក់ជាតិ | 196,724 | 3% |
| **គាំទ្របច្ចេកទេស** | **367,000** | **6%** |
| ទីប្រឹក្សា/ការសិក្សាស្រាវជ្រាវ/សវនកម្ម | 367,000 | 6% |
| **សរុប** | **$6,396,724** | **100%** |
| ***ខេត្ត ក្រុងគោលដៅ*** | ***14*** | |

## ៤.៤ មូលនិធិអន្តរជាតិដើម្បីអភិវឌ្ឍន៍កសិកម្ម (IFAD)

នៅឆ្នាំ ២០០៧នេះ កម្មវិធីកម្ចីឥណទានពី IFAD ត្រូវប្រតិបត្តិការក្រោមក្របខ័ណ្ឌផែនការសកម្មភាព និង ថវិកា NCDD គម្រោងអភិវឌ្ឍន៍ជនបទសហគមន៍មូលដ្ឋាន (CBRD) ក្នុងខេត្ត កំពត និងកំពង់ធំ និងគម្រោងកាត់បន្ថយភាពក្រីក្រជនបទ (RPRP) ក្នុងខេត្តព្រៃវែង និងស្វាយរៀង។ កម្មវិធីកម្ចីទី៣ គឺគម្រោងកែលំអជីវភាពជនបទ (RULIP) បានបញ្ចប់ការចរចារកម្ចីកាលពីខែមករា ២០០៧ និងត្រូវរំពឹងថានឹងបានការអនុម័ត និងចូលជាធរមាននៅក្នុងឆមាសទី១ ឆ្នាំ២០០៧។ គម្រោង RULIP នឹងត្រូវអនុវត្តនៅក្នុងខេត្ត ព្រះវិហារ ក្រចេះ និងរតនៈគីរី។ តារាងទី៨ បានបង្ហាញធនធានសរុប ឆ្នាំ២០០៧ នៃគម្រោងកម្ចីទាំង៣ មានចំនួន ៨.៩លានដុល្លារ ហើយក្នុងនោះ៦.៣លានដុល្លារ ឬ ៧៥% គឺជាថវិកាកម្ចីទាំង៣ ពី IFAD។ មូលនិធិបដិភាគពីខាងរាជរដ្ឋាភិបាល រួមជាមួយបដិភាគពី GTZ និង UNDP សំរាប់គម្រោងទាំង៣ ស្មើនឹង ២៥%នៃថវិកាសរុប។ គម្រោងទាំង៣ ប្រើប្រាស់រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងក្នុងបរិបទវិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីប្រតិបត្តិការ នៅថ្នាក់ក្រោមជាតិ និងពឹងផ្អែកលើការគាំទ្រហិរញ្ញវត្ថុ និងសេវាទីប្រឹក្សាបច្ចេកទេស របស់ PSDD។

| តារាង ៨ : ធនធាន IFAD ឆ្នាំ ២០០៧ | | | | |
|---|---|---|---|---|
| **សមាសភាគ** | **RPRP** | **CBRD** | **RULIP** | **សរុប** |
| **វិនិយោគ** | **3,640,901** | **1,044,033** | **1,187,657** | **5,872,591** |
| ឃុំគោលដៅ | 942,265 | 0 | 0 | 942,265 |
| ថ្នាក់ខេត្ត | 2,565,818 | 946,003 | 942,170 | 4,453,991 |
| សេវាកម្មថ្នាក់ជាតិ | 132,818 | 98,030 | 245,487 | 476,335 |
| **គាំទ្រកម្មវិធី** | **240,021** | **93,185** | **4,500** | **337,706** |
| ថ្នាក់ខេត្ត | 212,981 | 93,185 | 4,500 | 310,666 |
| ថ្នាក់ជាតិ | 27,040 | 0 | 0 | 27,040 |
| សេវាទីប្រឹក្សាផ្សេងៗ | 94,930 | 0 | **0** | **0** |
| **សរុបធនធានរបស់ IFAD** | **$3,975,852** | **$1,137,218** | **$1,192,157** | **$6,210,297** |
| AWPB 2007 | **$4,279,404** | **$3,063,292** | **$1,566,037** | **$8,908,733** |
| **សរុបធនធាន IFAD ជា %** | **93%** | **37%** | **76%** | **70%** |
| ***ខេត្តគោលដៅ*** | ***2*** | ***2*** | ***3*** | ***7*** |

### ៤.៤.១ គម្រោងកាត់បន្ថយភាពក្រីក្រនៅតំបន់ជនបទ (RPRP)

គម្រោង RPRP មានរយៈពេលអនុវត្តចំនួន ០៧ ឆ្នាំ និងថវិកាកម្ចីចំនួន ១៩.៦ លានដុល្លារ នៅក្នុងខេត្ត ព្រៃវែង និងស្វាយរៀង បានឈានចូលឆ្នាំទី៤។ គោលដៅរបស់គម្រោង គឺចូលរួមកាត់បន្ថយភាពក្រីក្រ ១២០.៦០០ គ្រួសារ តាមរយៈជីវភាពត្រូវបានកែលំអ សមត្ថភាពត្រូវបានពង្រឹង ប្រព័ន្ធកសិកម្មប្រកបដោយនិរន្តរភាព និង ការគ្រប់គ្រងធនធានធម្មជាតិ ការស្តារនិងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធចាស់និងថ្មី ការទទួលយកបច្ចេកទេស សេវាកម្ម និងទីផ្សារ ដើម្បីការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកិច្ចរបស់កសិករជនបទ។ គម្រោងមានសមាសភាគ សំខាន់ៗចំនួន ៣ គឺៈ ក) វិនិយោគកសិកម្ម ខ) ការអភិវឌ្ឍន៍មូលដ្ឋាន និង គ) ការគាំទ្រស្ថាប័ន ។

ពេលដែលកម្មវិធី សិលាត្រូវបានបញ្ចប់កាលពីចុងឆ្នាំ២០០៦ កិច្ចព្រមព្រៀងបានអនុម័តផ្ទេរការទទួលខុសត្រូវពី អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា ទៅក្រសួងកសិកម្ម ហើយការទទួលខុសត្រូវ លើសមាសភាគអភិវឌ្ឍន៍មូលដ្ឋាន បានផ្ទេរពី អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារនៃ កម្មវិធីសិលា ទៅក្រុមគាំទ្រកម្មវិធី NCDD។ ចាប់ពីឆ្នាំ ២០០៧នេះទៅ ក្រសួងកសិកម្មនឹងសម្របសម្រួលគម្រោងទូទៅ និងធ្វើជាមាត់ច្រក និងវេទិកាសំរាប់រៀបចំគោលនយោបាយជាមួយ រាជរដ្ឋាភិបាលលើបញ្ហាដែលទាក់ទង ទៅនឹង ប្រជាពលរដ្ឋក្រីក្រ ការកាត់បន្ថយភាពក្រីក្រ វិមជ្ឈការ និងវិសហមជ្ឈការ ដែលពាក់ព័ន្ធដល់កិច្ចអភិវឌ្ឍន៍ វិស័យកសិកម្ម និង ការកាត់បន្ថយភាពក្រីក្រនៅជនបទ ។

នៅក្នុងឆ្នាំ២០០៧ សមាសភាគកសិកម្ម គម្រោងបានគ្រប់ដណ្តប់ ៨៤ឃុំ និង ១៣ស្រុកគោលដៅ (៥០ឃុំ និង ៨ស្រុក ក្នុងខេត្តព្រៃវែង និង ៣៤ឃុំ និង ៥ស្រុក ក្នុងខេត្តស្វាយរៀង) ។ ក្រុមផ្សព្វផ្សាយថ្នាក់ឃុំ មានចំនួន សរុប ១៦៨នាក់ ចុះកិច្ចសន្យាជាមួយមន្ទីរកសិកម្មរបស់ខេត្តទាំង២ ដើម្បីផ្តល់សេវាផ្សព្វផ្សាយកសិកម្មដល់ ក្រុមជួយខ្លួនឯងចំនួន ១.៦០០ (៩៤៤ក្រុម ក្នុងខេត្តព្រៃវែង និង ៦៥៦ក្រុម ក្នុងខេត្តស្វាយរៀង) និងអ្នកទទួលផលផ្ទាល់សរុបមានចំនួន ៤០.០០០គ្រួសារកសិករ។ មន្ត្រីផ្សព្វផ្សាយភូមិសរុបចំនួន ៥០០នាក់ នឹងទទួលការបណ្តុះបណ្តាលពីទេពកោសល្យផ្សព្វផ្សាយបច្ចេកទេសកសិកម្ម និងបច្ចេកទេសជាមូលដ្ឋាន ដើម្បីអាចទទួលខុសត្រូវ ជាបណ្តើរៗពីមន្ត្រីផ្សព្វផ្សាយឃុំនាពេលអនាគត។ នីតិវិធី និងយុទ្ធសាស្ត្រសំរាប់ផ្ទេរតួនាទី និងការទទួលខុសត្រូវ របស់មន្ត្រីផ្សព្វផ្សាយឃុំ ទៅអោយមន្ត្រីផ្សព្វផ្សាយភូមិ គឺជាការងារដ៏សំខាន់មួយនៃ និរន្តរភាព និងពិភាក្សា អោយបានច្បាស់ជាមួយដៃគូពាក់ព័ន្ធនៅក្នុងការអនុវត្តឆ្នាំ ២០០៧ ។

នៅក្រោមសមាសភាគអភិវឌ្ឍន៍មូលដ្ឋាន ឆ្នាំ២០០៧ មូលនិធិអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធឃុំ (CIDF) ដែលមានការវិភាជន៍បន្ថែមលើមូលនិធិឃុំសង្កាត់ ដល់ឃុំគោលដៅចំនួន១៤៨ឃុំ ជាមធ្យម ២៥.០០០ដុល្លារ សំរាប់ឃុំគោលដៅនីមួយៗ ក្នុងរយៈពេល៥ឆ្នាំ។ ការប្រើប្រាស់មូលនិធិ CIDF គឺអាស្រ័យទៅលើឃុំគោលដៅ ដែលបានវិភាជន៍ថវិកា CIDF ដើម្បីគាំទ្រអាទិភាពរបស់ខ្លួន នៅក្នុងកម្មវិធីវិនិយោគឃុំ ហើយថវិកាCIDF សរុប សំរាប់ឆ្នាំ ២០០៧នេះ មានចំនួន ៩៤២.០០០ដុល្លារ។

សមាសភាគគាំទ្រស្ថាប័ន មានការគាំទ្រកម្មវិធីដល់ក្រសួងកសិកម្ម ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងកិច្ចការនារី និងក្រុមគាំទ្រកម្មវិធី NCDD នៅថ្នាក់ជាតិ ព្រមទាំងគាំទ្រដល់គណៈកម្មាធិការប្រតិបត្តិនៃខេត្តទាំងពីរ ដើម្បីធានា ថាកម្មវិធីត្រូវបានគ្រប់គ្រង និងប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព អោយស្របតាមអភិក្រម វិមជ្ឈការ និង វិសហមជ្ឈការ និង ធានាថាមានការបញ្ជ្រាបយែនឌ័រតាមរយៈកម្មវីធីនេះ ។

### ៤.៤.២ គម្រោងអភិវឌ្ឍន៍ជនបទ និងសហគមន៍មូលដ្ឋាន (CBRD)

គម្រោង CBRD មានរយៈពេល ៧ឆ្នាំ មានថវិកាចំនួន ២៣លានដុល្លារ គ្រប់គ្រងចាត់ចែងដោយ ក្រសួងអភិវឌ្ឍន៍ជនបទជាមួយហិរញ្ញប្បទានរួមជាមួយអាល្លឺមង់/GTZ អូស្ត្រាលី/CAAEP និងអង្គការស្បៀងអាហារពិភពលោក នឹងអនុវត្តឆ្នាំចុងក្រោយរបស់ខ្លួន នៅឆ្នាំ ២០០៧នេះ ក្នុងខេត្តពីរ គឺខេត្តកំពត និងកំពង់ធំ ។ គម្រោង CBRD មានសមាសភាគចំនួន៤ សំខាន់ៗ គឺ ការអភិវឌ្ឍន៍សហគមន៍ ការអភិវឌ្ឍន៍កសិកម្មនិងចិញ្ចឹមសត្វ ហេដ្ឋារចនាសម្ព័ន្ធជនបទ និងការគាំទ្រអភិវឌ្ឍន៍ស្ថាប័ន។ គម្រោងនេះផ្តោតលើកត្តាសំខាន់ពីរគឺៈ ១)ការកាត់បន្ថយភាពក្រីក្រ និងអភិក្រមសហគមន៍មូលដ្ឋាន ដោយផ្តល់អំណាចឱ្យប្រជាពលរដ្ឋ និងសហគមន៍គោលដៅ

ដើម្បីប្រើប្រាស់ធនធានផ្ទាល់របស់ពួកគេ និងចូលរួមយ៉ាងសកម្ម ក្នុងការសំរេចចិត្តគាំទ្រគម្រោង និងអន្តរាគមន៍នានា និង ២) ប្រព័ន្ធបែបវិមជ្ឈការ និង នីតិវិធីដើម្បី រៀបចំ ផែនការ ហិរញ្ញវត្ថុ និង ការអនុវត្ត ។

នៅក្នុងឆ្នាំ២០០៧ គម្រោងCBRD នឹងនៅតែគាំទ្រដល់ការគ្របដណ្តប់គោលដៅលើ ៧ ក្នុងចំណោម ៨ស្រុក នៅខេត្តកំពត និង ៤ ក្នុងចំណោម ៨ស្រុក នៅខេត្តកំពង់ធំ (៨ស្រុកគោលដៅសំរាប់សមាសភាគកសិកម្ម)។ គម្រោង បាននិងកំពុងជួយគ្រួសារកសិករក្រីក្រ និងក្រុមប្រឹក្សាឃុំ តាមរយៈសកម្មភាពផ្សេងៗជាច្រើន ដូចជា ផ្សព្វផ្សាយបច្ចេកទេសកសិកម្ម សកម្មភាពជួយខ្លួនឯង និង ការកែលំអនិង សំណង់ហេដ្ឋារចនាសម្ព័ន្ធ ។

ផែនការសកម្មភានិងថវិកាឆ្នាំ ២០០៧ មានថវិកាសរុប ៣លានដុល្លារ ដែលក្នុងនោះ ១,១៣លានដុល្លារ ត្រូវបាន វិនិយោគដោយប្រាក់កម្ចី ដោយវិភាជន៍ ១,០៤លានដុល្លារ សំរាប់វិស័យកសិកម្ម ប្រពន្ធ័ធារាសាស្ត្រខ្នាតមធ្យម អភិវឌ្ឍន៍សហគមន៍ បញ្ជ្រាបយែនឌ័រ និងការគាំទ្រកម្មវិធីថ្នាក់ខេត្ត រីឯថវិកា ៩៨.០០០ដុល្លារ ទៀតសម្រាប់ គាំទ្រដល់អង្គភាពគាំទ្រគម្រោងនៃក្រសួងអភិវឌ្ឍន៍ជនបទ។

## ៤.៤.៣ គម្រោងកែលំអជីវភាពជនបទ (RULIP)

គម្រោង RULIP ជាគម្រោងថ្មីមួយ មានរយៈពេលអនុវត្ត៧ឆ្នាំ និងមានថវិកាចំនួន ៩.២១លានដុល្លារ ទទួល អនុវត្តដោយក្រសួងកសិកម្ម និងមានហិរញ្ញប្បទានរួមជាមួយ UNDP ហើយត្រូវបានចាប់ផ្តើមអនុវត្ត នៅពាក់ កណ្តាលឆ្នាំ២០០៧នេះ នៅក្នុងខេត្តគោលដៅ៣គឺ ក្រចេះ ព្រះវិហារ និងរតនគីរី។ គម្រោងនេះ មានសមាសភាគ ចំនួន២គឺ: ១)-ការកែលំអជីវភាព និង ២)-ការគាំទ្រវិមជ្ឈការ និង វិសហមជ្ឈការ លើវិស័យកសិកម្ម ។

នៅក្រោមសមាសភាគកែលំអជីវភាព គម្រោងនឹងផ្តោតលើការកែលំអសន្តិសុខស្បៀងរបស់ប្រជាពលរដ្ឋក្រីក្រ និង លើកកំពស់ពិពិធកម្មកសិកម្ម និងការអភិវឌ្ឍន៍វិស័យកសិកម្មឆ្ពោះទៅរកទីផ្សារ។ សមាសភាគនេះបានស្រង់ យកបទពិសោធន៍វិជ្ជមានរបស់គម្រោង RPRP ដូចជា ការបង្កើតក្រុមជួយខ្លួនឯង ដោយផ្សារភ្ជាប់ទៅនឹង កំណែ លំអជីវភាព កំណែលំអប្រព័ន្ធកសិកម្ម ធ្វើផែនការមូលដ្ឋាន ដោយផ្អែកលើការវិភាគ ប្រព័ន្ធក្សេត្រ-បរិស្ថាន និង ការគាំទ្រ និងពង្រឹងសមត្ថភាព ក្រុមអ្នកផ្សព្វផ្សាយកសិកម្ម។ កម្មវិធីគាំទ្របន្ថែម ដែលអាចអនុវត្តបានសមស្រប នៅក្នុងសហគមន៍នានា រួមមាន: ១)-គាំទ្រការធ្វើផែនការ និងត្រួតពិនិត្យនៅថ្នាក់ឃុំ ២)-ការគាំទ្រមន្ត្រី ផ្សព្វផ្សាយ ពេទ្យសត្វ និងមន្ត្រីជលផលភូមិ ៣)-ការបញ្ជ្រាបយែនឌ័រ ៤)-គាំទ្រការផ្តួចផ្តើមរកទីផ្សារ ៥)-ការ បង្ហាញប្រព័ន្ធកសិកម្មចំរុះ ៦)-ការគាំទ្រវិស័យឯកជន ៧)-ការតាំងពិព័រណ៍ផលិតផលស្រុក និង ៨)-ការបង្កើត ក្លឹបយុវកសិករ។

សមាសភាគគាំទ្រវិមជ្ឈការ និងវិសហមជ្ឈការ ក្នុងវិស័យកសិកម្ម រួមមានសមាសភាគរង៣ គឺ ១-គាំទ្រកម្មវិធីវិនិយោគកសិកម្មថ្នាក់ខេត្ត ២-ការគាំទ្រការបញ្ជ្រាបយែនឌ័រក្នុងវិស័យកសិកម្ម និង ៣-សហគមន៍រៀនសូត្រ។

ផែនការសកម្មភាពនិងថវិកាឆ្នាំ២០០៧ សំរាប់គម្រោងនេះ មានថវិកាសរុប១,៥លានដុល្លារ ក្នុងនោះថវិកា ១,២លានដុល្លារ គាំទ្រដោយប្រាក់កម្ចី ពី IFAD។

### ៤.៥ ធនាគារអភិវឌ្ឍន៍អាស៊ី (ADB)

ការគាំទ្រពីធនាគារអភិវឌ្ឍន៍អាស៊ី សំរាប់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ មាន២គម្រោងគឺៈ គម្រោងអភិវឌ្ឍន៍ក្រុមប្រឹក្សាឃុំ (ជំហានទី២ចាប់ផ្តើមអនុវត្តដើមឆ្នាំ២០០៧) និងគម្រោងជីវភាពរស់នៅប្រកប ដោយនិរន្តរភាពជុំវិញបឹងទន្លេសាប (TSSLP)។ តារាងទី៩ មានបង្ហាញធនធាន ADB ឆ្នាំ២០០៧ ដែលមានថវិកាសរុប ៥,៦លានដុល្លារ ត្រូវបញ្ចូលទៅផែនការហិរញ្ញវត្ថុឆ្នាំ ២០០៧នៅក្រោមគម្រោងទាំងពីរ ។

### ៤.៥.១ គម្រោងអភិវឌ្ឍន៍ក្រុមប្រឹក្សាឃុំ (CCDP2)

គម្រោង CCDP2 ជាជំហានទី២នេះ នៃការគាំទ្រឃុំសង្កាត់ ដោយធនាគារអភិវឌ្ឍន៍អាស៊ី មានរយៈពេលអនុវត្តចំនួន២ឆ្នាំ ត្រូវបានអនុម័ត និងចាប់ផ្តើមអនុវត្តនៅដើមឆ្នាំ ២០០៧នេះ។ ដោយអនុវត្តបន្តពីជំហានទី១ គម្រោង CCDP2 មានសមាសភាគចំនួន ០៣ ដូចខាងក្រោមៈ

**សមាសភាគ១-មធ្យោបាយជួយសម្រួលការងារឃុំៈ** គម្រោងនឹងបន្តផ្តល់មធ្យោបាយសមរម្យ សម្រាប់ការប្រជុំ និង ប្រតិបត្តិការនានា របស់ក្រុមប្រឹក្សាឃុំសង្កាត់ និងសាធារណៈជន ដែលបង្ហាញពីតួនាទី និងភាពចាំបាច់នៃប្រជាធិបតេយ្យនៅមូលដ្ឋាននៅថ្នាក់ឃុំ។ អាគារឃុំចំនួនសរុប ២៣៥កន្លែង នឹងត្រូវសាងសង់ក្នុងរយពេល២ឆ្នាំ។

**សមាសភាគ២-អភិវឌ្ឍន៍ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋានៈ** គម្រោងនឹងគាំទ្រដល់ការរៀបចំ និងដាក់ប្រតិបត្តិការនូវប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋានដោយកុំព្យូទ័រ ដែលប្រកបដោយនិរន្តរភាពមួយ ដោយធានាឱ្យមានឯកសារដើមដកល់ទុកប្រកបដោយសុវត្ថិភាព និងប្រព័ន្ធទិន្នន័យអេឡិចត្រូនិកកណ្តាលមួយ ដែលអាចបើកមើល និងកត់ត្រាបន្ថែមបានពីចំងាយ។

**សមាសភាគ៣-ការអភិវឌ្ឍន៍សមត្ថភាពៈ** គម្រោងនឹងគាំទ្រការបណ្តុះបណ្តាល ស្តីពីការចំណាយប្រកបដោយប្រសិទ្ធិភាព ដល់ក្រុមប្រឹក្សាឃុំសង្កាត់ ស្មៀន និងមន្ត្រីរាជការ និងយុទ្ធនាការផ្សព្វផ្សាយរយពេល ២៤ខែ ដើម្បីផ្សព្វផ្សាយពីគោលបំណង និង ការអនុវត្តប្រជាធិបតេយ្យនៅថ្នាក់មូលដ្ឋាន ។

គម្រោងCCDP2 ក្នុងឆ្នាំ២០០៧ មានថវិកាសរុបចំនួន ១.៨៣លានដុល្លារ សំរាប់ការសាងសង់ អាគាររដ្ឋបាលឃុំចំនួន៩៣ ដោយគ្រោងចំនាយសម្រាប់អាគារនិមួយៗ ១៩.៥០០ដុល្លារ។ ទីតាំងសំណង់អាគារ រដ្ឋបាលឃុំ សង្កាត់ត្រូវផ្អែកតាមលក្ខណៈវិនិច្ឆ័យរបស់ក្រសួងមហាផ្ទៃ និងតាមគោលការណ៍អនុវត្តដែលមានស្រាប់ ពាក់ព័ន្ធនឹងការដេញថ្លៃមានលក្ខណៈប្រកួតប្រជែង និងប្រើប្រាស់គណនីធនាគារឯកជនសំរាប់ការ ទូទាត់ជាមួយអ្នកទទួលការ។ នៅក្រោមសមាសភាគ២ មានថវិកាសរុបចំនួន ៣១០.០០០ដុល្លារ ត្រូវបានវិភាជន៍សំរាប់ឆ្នាំ ២០០៧ ក្នុងផែនការហិរញ្ញប្បទានសម្រាប់លទ្ធកម្មកុំព្យូទ័រ សំរាប់ការរៀបចំប្រព័ន្ធនិងសាកល្បងប្រពន្ធ័ និងការបណ្តុះបណ្តាល អ្នកប្រើប្រាស់ឧបករណ៍ និងការបញ្ចូលទិន្នន័យ។

នៅក្រោមសមាសភាគ៣ ថវិកាសរុបចំនួន ២៣០.០០០ដុល្លារ ត្រូវបានវិភាជន៍សំរាប់ឆ្នាំ២០០៧ ក្នុងនោះ ១៧០.០០០ដុល្លារ សំរាប់គាំទ្រសកម្មភាពបណ្តុះបណ្តាលជាអាទិភាព ដែលបានកំណត់នៅក្នុងផែនការ NCDD ឆ្នាំ២០០៧ និង ៦០.០០០ដុល្លារទៀត សំរាប់មូលនិធិផ្សព្វផ្សាយព័ត៌មាន។ មូលនិធិផ្សព្វផ្សាយព័ត៌មាន នឹងត្រូវប្រើប្រាស់សំរាប់ ការផលិតនិងផ្សព្វផ្សាយពត៌មានស្តីពី ដំណើរការប្រជាធិបតេយ្យ និងវិមជ្ឈការ នៅមូលដ្ឋាន ដោយប្រើមធ្យោបាយចំរុះ (ដូចជាល្ខោនខ្លីៗ ទូរទស្សន៍ វិទ្យុ ផ្ទាំងផ្សព្វផ្សាយ និងសៀវភៅព័ត៌មានខ្លីៗ) និងត្រូវធ្វើលទ្ធកម្មតាមរយៈការដេញថ្លៃប្រកួតប្រជែង។ ថវិកាចំនួន៣០០.០០០ដុល្លារ ត្រូវបានវិភាជន៍សម្រាប់សេវាទីប្រឹក្សា និង៤៥.០០០ដុល្លារ សំរាប់ចំណាយប្រតិបត្តិការដែលទាក់ទងទៅនឹងការអនុវត្ត សមាសភាគ ទាំងបី ។

| តារាង ៩ : ធនធាន ADB ឆ្នាំ ២០០៧ | | | |
|---|---|---|---|
| **សមាសភាគ** | **CCDP II** | **TSSLP** | **សរុប** |
| **វិនិយោគ** | **2,410,000** | **1,012,012** | **3,422,012** |
| ឃុំគោលដៅ | 1,825,000 | 617,012 | 2,442,012 |
| ថ្នាក់ខេត្ត | | | 0 |
| សេវាកម្មក្រសួងថ្នាក់ជាតិ | 585,000 | 395,000 | 980,000 |
| **គាំទ្រកម្មវិធី** | **0** | **110,000** | **110,000** |
| ថ្នាក់ខេត្ត | 0 | 110,000 | 110,000 |
| ថ្នាក់ជាតិ | 0 | 0 | 0 |
| **ជំនួយបច្ចេកទេស** | **300,000** | **1,723,000** | **2,023,000** |
| ថ្នាក់ខេត្ត | 0 | 444,000 | 444,000 |
| ថ្នាក់ជាតិ | 300,000 | 1,279,000 | 1,579,000 |
| **សរុបធនធាន** ADB | **$2,710,000** | **$2,845,012** | **$5,555,012** |
| ***ខេត្តគោលដៅ*** | ***10*** | ***5*** | ***15*** |

### ៤.៥.២ គម្រោងនិរន្តរភាពជីវភាពបឹងទន្លេសាប (TSSL)

គម្រោងនិរន្តភាពជីវភាពបឹងទន្លេសាប (TSSL)ជាជំនួយឥតចំណងមានថវិកាប្រមាណ ១៥លានដុល្លារ បានមកពីមូលនិធិពិសេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ជំនួយឥតចំណងចំនួន ៤.៧៤លានដុល្លារ ពីរដ្ឋាភិបាលប្រទេសហ្វាំងឡង់ (គ្រប់គ្រងដោយធនាគាអភិវឌ្ឍន៍អាស៊ី) និងទុនបដិភាគពីរាជរដ្ឋាភិបាលចំនួន ៦សែនដុល្លារ។ ជំនួយឥតចំណងនឹងមានប្រសិទ្ធភាពចាប់ពីថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៦ ហើយរយៈពេលប្រើប្រាស់ នឹងបញ្ចប់នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១០ ដោយមានកសួងមហាផ្ទៃ ជាស្ថាប័នអនុវត្ត ។

បរិបទនៃគំរោង ផ្តើមពីការប្រើប្រាស់បឹងទន្លេសាប ភាពជាដៃគូរវាងស្ថាបន័នានា និងប្រជាពលរដ្ឋ ក្នុងការរួមគ្នាឆ្លើយតបទៅនឹងបញ្ហាភាពក្រីក្រ និងបញ្ហាបរិស្ថាននៅតំបន់បឹងទន្លេសាប ព្រមទាំងផ្អែកតាមយុទ្ធសាស្រ្ត បឹងទន្លេសាបដែលបានគាំពារ ជំរុញ និងសម្របសម្រួលលើៈ (១)-កំណើសេដ្ឋកិច្ចប្រកបដោយនិរន្តភាព ដោយផ្តោតលើពលរដ្ឋក្រីក្រ (២)-សិទ្ធិប្រើប្រាស់លើអចលនទ្រព្យ និង (៣)-ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន។ គោលការណ៍ជាយុទ្ធសាស្រ្ត គឺៈ (១)-ជីវភាពប្រកបដោយនិរន្តរភាព (២)-យុត្តិធមិសង្គម និង (៣)-ពាក់ពន្ធ័ទូទាំងតំបន់អាងបឹងទន្លេសាប។ គម្រោងTSSL នឹងកែលំអជីវភាព ដោយបង្កើនសិទ្ធិនិងលទ្ធភាពប្រើប្រាស់ អចលនទ្រព្យ ដោយសហគមន៍ ក្នុងខេត្តចំនួន៥ ដែលនៅជាប់បឹងទន្លេសាប។ តំបន់របស់គំរោង គឺនៅជុំវិញទន្លេសាប ហើយតំបន់ស្នូល គឺនៅជាប់ទន្លេសាប។ ជាពិសេស គំរោងនេះគ្រប់ដណ្តប់ ៣៧ឃុំគោលដៅដែលមាន ៣១៦ភូមិ និងមានប្រជាពលរដ្ឋ ២៨៧.៤៣០នាក់ ក្នុង ៥៤.៨៥៧គ្រួសារ។ សមាសភាគ សំខាន់ៗរបស់គំរោងមានដូចខាងក្រោមៈ

**សមាសភាគទី១ ការអភិវឌ្ឍន៍ដោយផ្អែកលើឆន្ទៈរបស់សហគមន៍ៈ** សមាសភាគនេះអនុវត្តដោយក្រសួងមហាផ្ទៃរួមមានមូលនិធិលេកស្ទួយជីវភាពសហគមន៍ ដែលគ្រប់គ្រងដោយក្រុមប្រឹក្សាឃុំ និងផ្តល់ថវិកាសំរាប់ កសាងហេដ្ឋារចនាសម្ព័ន្ធសង្គម ជីវភាពរស់នៅ សហគមន៍នេសាទ និងជំនួយសំរាប់បង្កើត និងអនុវត្តកញ្ចប់មូលនិធិវិនិយោគលើកស្ទួយ ជីវភាពរស់នៅ។

**សមាសភាពទី២ គោលនយោបាយសុវត្ថិភាពតំបន់ស្នូលៈ** សមាសភាពនេះ អនុវត្តដោយលេខាធិការដ្ឋាន នៃតំបន់អាងបឹងទន្លេសាប សំដៅបង្កើតឱ្យមានជាមូលដ្ឋានពតិមាន និងប្រព័ន្ធគ្រប់គ្រង សំរាប់តំបន់ស្នូល ព្រមទាំងធ្វើឱ្យប្រសើរឡើងនូវបណ្តាញទំនាក់ទំនង អភិរក្សដែនជំរកមច្ឆជាតិ។

**សមាសភាគទី៣ កសាងជំនាញនិងការយល់ដឹងសំរាប់និរន្តរភាពជីវភាពៈ** សមាសភាគនេះផ្តោតលើ ១)-គាំទ្រការធ្វើឱ្យប្រសើរឡើងនូវប្រពន្ធ័សំរបសំរួល កិច្ចអភិវឌ្ឍន៍ដោយផ្អែកតាមឆន្ទៈរបស់សហគមន៍ ដែលមាន

ក្រុមប្រឹក្សា អភិវឌ្ឍន៍ជនបទ និងកសិកម្ម ភ្នាក់ងារអនុវត្ត។ ២)-បង្កើនជំនាញលើការអភិវឌ្ឍន៍ដោយផ្អែកលើឆន្ទៈរបស់សហគមន៍ មានក្រសួងមហាផ្ទៃជាភ្នាក់ងារអនុវត្ត។ និង ៣-ផ្តល់ការអប់រំលើផ្នែកបរិស្ថាន ដើម្បីការពារធនធានធម្មជាតិ ដែលមានក្រសួងបរិស្ថាន ភ្នាក់ងារអនុវត្ត។

ដូចបានបង្ហាញនៅក្នុងតារាងទី៩ ខាងលើ ក្នុងឆ្នាំ២០០៧នេះ ផែនការចំណាយសរុប នៃគំរោងនេះមានចំនួន ២,៩លានដុល្លា ក្នុងនោះថវិកាចំនួន ៦១៧,000ដុល្លារ គឺជាមូលនិធិបន្ថែមសំរាប់ឃុំគោលដៅ។

## ៤.៦ កម្មវិធីគ្រប់គ្រងធនធានធម្មជាតិនិងការលើកស្ទួយជីវភាពរស់នៅ (NRM&L)

កម្មវិធី NRM&L ជាកម្មវិធីរយៈពេល៤ឆ្នាំ (ឆ្នាំ២០០៧-ឆ្នាំ២០១០) ដែលផ្តល់ហិរញ្ញវត្ថុរួមគ្នាដោយ រដ្ឋាភិបាលដាណឺម៉ាក និងចក្រភពអង់គ្លេស ក្រោមក្របខ័ណ្ឌការផ្តល់ជំនួយពហុភាគី សម្រាប់លើកស្ទួយជីវភាពរស់នៅ (MDLF)។ កម្មវិធី NRM&L មានសមាសភាគសំខាន់៧៣ ពាក់ព័ន្ធគ្នា ដូចជា កម្មវិធីគ្រប់គ្រងធនធានធម្មជាតិតាមរយៈ វិមជ្ឈការ និងវិសហមជ្ឈការ សមាសភាគសង្គមស៊ីវិល និងសមាសភាគអភិវឌ្ឍន៍ វិស័យគោលនយោបាយសម្រាប់ការគ្រប់គ្រងដីធ្លី រុក្ខាប្រមាញ់ និងនេសាទ។ សម្រាប់ផែនការសកម្មភាពនិងថវិកាឆ្នាំ២០០៧របស់គណៈកម្មាធិការជាតិ ដឹកនាំការងារកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ (គ.ជ.វ.វ) សមាសភាគគ្រប់គ្រងធនធានធម្មជាតិ ក្នុងបរិបទ វិមជ្ឈការ និងវិសហមជ្ឈការ និងការគ្រប់គ្រងដីធ្លី ដែលជាសមាសភាគរងនឹងផ្ទេរធនធានទៅថ្នាក់ក្រោមជាតិ ដោយ ប្រើប្រាស់ប្រព័ន្ធ និងរចនាសម្ព័ន្ធគ្រប់គ្រង វិមជ្ឈការ និងវិសហមជ្ឈការដែលមានស្រាប់។

### ៤.៦.១ សមាសភាគគ្រប់គ្រងធនធានធម្មជាតិក្នុងក្របខ័ណ្ឌវិមជ្ឈការនិងវិសហមជ្ឈការ

សមាសភាគគ្រប់គ្រងធនធានធម្មជាតិ ក្នុងក្របខ័ណ្ឌវិមជ្ឈការនិងវិសហមជ្ឈការត្រូវបានរៀបចំឡើង ដោយឈរលើ មូលដ្ឋាននៃបទពិសោធន៍ ដែលទទួលបានពីការអនុវត្តគំរោងគ្រប់គ្រងធនធានធម្មជាតិនិងបរិស្ថាន នៅថ្នាក់ឃុំនិងសហគមន៍មូលដ្ឋាន (CCB-NREM) រយៈពេល៣ឆ្នាំ ដែលផ្តល់ហិរញ្ញប្បទានដោយរដ្ឋាភិបាលដាណឺម៉ាក និង ដែលអនុវត្ត ដោយគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា ពីឆ្នាំ២០០៤ដល់ឆ្នាំ២០០៦។ គំរោង CCB-NREM ផ្តោតលើការបញ្ជ្រាបការគ្រប់គ្រងធនធានធម្មជាតិនិងបរិស្ថាន ផែនការប្រើប្រាស់ដីធ្លី និងការប្រើប្រាស់ធនធានធម្មជាតិ ប្រកបដោយចិរភាព ដើម្បីលើកស្ទួយជីវភាពរស់នៅ របស់ប្រជាជនក្រីក្រជនបទ នៅថ្នាក់ក្រោមជាតិ ដោយប្រើប្រាស់ នីតិវិធី ប្រព័ន្ធ និងរចនាសម្ព័ន្ធនានា ពាក់ព័ន្ធនឹងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ របស់រាជរដ្ឋាភិបាលកម្ពុជា។ ក្នុងឆ្នាំ២០០៦ គម្រោងនេះបានពង្រីកវិសាលភាពគ្របដណ្តប់ របស់ខ្លួនរហូតដល់១០ខេត្តក្រុង។

គោលដៅរបស់សមាសភាគ គ្រប់គ្រងធនធានធម្មជាតិក្នុងបរិបទវិមជ្ឈការនិងវិសហមជ្ឈការ គឺការកាត់បន្ថយភាពងាយរងគ្រោះរបស់ពលរដ្ឋក្រីក្រនៅជនបទ ដែលជីវភាពរស់របស់ពួកគេពឹងផ្អែកតែទៅលើធនធានធម្មជាតិ។ គម្រោង មានគោលបំណងធ្វើឱ្យប្រសើរឡើងនូវដំណើរការអភិបាលកិច្ចមូលដ្ឋាន ដើម្បីឱ្យការគ្រប់គ្រងធនធានធម្មជាតិមានចិរភាព និងផ្តល់ប្រយោជន៍ឱ្យអ្នកក្រីក្រ។ គម្រោង NRM&L មានលទ្ធផលរំពឹងទុកចំនួន៥ ដែលត្រូវសម្រេចឱ្យបាន គឺ:

1. ភាពស៊ីសង្វាក់គ្នា រវាងគោលនយោបាយគ្រប់គ្រងធនធានធម្មជាតិ នៅក្នុងបរិបទវិមជ្ឈការ និងវិសហមជ្ឈការ ត្រូវ បានធ្វើឱ្យកាន់តែប្រសើរឡើង។
2. លិខិតបទដ្ឋានគតិយុត្តិនានា សម្រាប់បញ្ជ្រាបការគ្រប់គ្រងធនធានធម្មជាតិ ទៅក្នុងដំណើរការកសាងផែនការតាមបែបវិមជ្ឈការនិងវិសហមជ្ឈការ ត្រូវបានរៀបចំឡើង។
3. ទុនវិនិយោគសម្រាប់គម្រោងគ្រប់គ្រងធនធានធម្មជាតិ និងជីវភាពរស់នៅ ត្រូវបានគាំទ្រទៅដល់ថ្នាក់ឃុំ តាមរយៈការចូលរួមរបស់សង្គមស៊ីវិល និងការធ្វើសេចក្តីសម្រេចចិត្ត នៅក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ឃុំសង្កាត់។
4. ដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ ក្នុងវិស័យគ្រប់គ្រងធនធានធម្មជាតិ និងលើកស្ទួយជីវភាព រស់នៅ នៅថ្នាក់ខេត្ត ត្រូវបានពង្រឹង។
5. ការឆ្លើយតបរបស់ថ្នាក់ស្រុក ទៅនឹងតម្រូវការរបស់អន្តរឃុំ ដើម្បីទទួលបាននូវទុនវិនិយោគ សម្រាប់សកម្មភាព គ្រប់គ្រងធនធានធម្មជាតិនិងជីវភាពរស់នៅ ត្រូវបានកែលំអឱ្យបានប្រសើរឡើង។

តារាងទី១០ ស្តីពីធនធានសរុបឆ្នាំ២០០៧របស់DANIDA/DFID សម្រាប់គាំទ្រគម្រោង NRM&L ខាងក្រោមបង្ហាញថា សមាសភាគគ្រប់គ្រងធនធានធម្មជាតិ ក្នុងបរិបទវិមជ្ឈការ និងវិសហមជ្ឈការ មានធនធានសរុបចំនួន ៤,៧២លានដុល្លារ សម្រាប់អនុវត្តក្នុងឆ្នាំ២០០៧។ ធនធានវិនិយោគសរុបចំនួន ៤,៣៨លានដុល្លារ ដែលត្រូវវិភាជបន្ថែមសម្រាប់ គាំទ្រថវិការបស់ក្រុមប្រឹក្សាឃុំគោលដៅ៥១៧ ក្នុង៦៦ស្រុក ក្រោមគម្រោងសាកល្បង ថ្នាក់ស្រុកខណ្ឌ របស់ក្រសួងមហាផ្ទៃ និងសម្រាប់ខេត្តគោលដៅទាំង១០ដែលកម្មវិធីត្រូវអនុវត្តក្នុងឆ្នាំ២០០៧។ ក្របខ័ណ្ឌអ្នកផ្តល់ជំនួយពហុភាគីសម្រាប់លើកស្ទួយជីវភាពរស់នៅ បានវិភាជធនធានសរុបចំនួន ៣២០.០០០ដុល្លារ ដើម្បីគាំទ្រ ដល់សេវាប្រឹក្សាពិគ្រោះយោបល់ជាក់លាក់មួយចំនួន ដែលនឹងចូលរួមគាំទ្រ ដល់ការរៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍ របស់សមាសភាគគ្រប់គ្រងធនធានធម្មជាតិក្នុង បរិបទវិមជ្ឈការនិងវិសហមជ្ឈការ ព្រមទាំងកម្មវិធីជាតិទាំងមូលផងដែរ។

សមាសភាគគ្រប់គ្រងធនធានធម្មជាតិ ក្នុងបរិបទវិមជ្ឈការនិងវិសហមជ្ឈការ នឹងទទួលបានផលប្រយោជន៍ពីជំនួយ បច្ចេកទេស និងការគាំទ្រកម្មវិធីតាមរយៈក្រុមគាំទ្រគម្រោងរបស់អគ្គលេខាធិការដ្ឋាននៃ NCDD និង

គម្រោង PSDD ។ ច្បាប់ចំលងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០០៧ របស់សមាសភាគ គ្រប់គ្រងធនធានធម្មជាតិក្នុង បរិបទវិមជ្ឈការនិងវិសហមជ្ឈការ មាននៅក្នុងការិយាល័យនៃអគ្គលេខាធិការដ្ឋានរបស់ NCDD ។

| តារាង១០: ធនធានសរុបឆ្នាំ២០០៧ របស់គម្រោងNRM&Lដែលផ្តល់មូលនិធិដោយDanida/DfID | | | |
|---|---|---|---|
| **ប្រភេទ** | **D&D** | **គ្រប់គ្រងដីធ្លី** | **សរុប** |
| **វិនិយោគ** | **4,380,006** | **679,710** | **5,059,716** |
| ឃុំគោលដៅ | 2,000,006 | 382,000 | 2,382,006 |
| ស្រុក | 1,980,000 | 114,000 | 2,094,000 |
| ខេត្ត | 400,000 | 183,710 | 583,710 |
| **គាំទ្រកម្មវិធី** | **20,178** | | |
| ខេត្ត | 0 | | |
| ថ្នាក់ជាតិ | 20,178 | | |
| **គាំទ្របច្ចេកទេស** | **320,000** | | |
| សេវាប្រឹក្សាពិគ្រោះយោបល់ | 320,000 | | |
| **សរុបរួម** | **$4,720,184** | **$679,710** | **$5,059,716** |
| ***ចំនួនខេត្តគ្របដណ្តប់*** | ***10*** | ***10*** | ***10*** |

## ៤.៦.២ សមាសភាគរងគ្រប់គ្រងដីធ្លី

ទិសដៅអភិវឌ្ឍន៍នៃ សមាសភាគរងគ្រប់គ្រងដីធ្លី គឺការកាត់បន្ថយភាពងាយរងគ្រោះ របស់ប្រជាពលរដ្ឋ នៅជនបទ ដែលជីវភាពរស់នៅរបស់ពួកគេ ពឹងផ្អែកតែទៅលើធនធានធម្មជាតិ។ គោលបំណងរបស់ សមាសភាគរងនេះ គឺប្រជាពលរដ្ឋ ក្រីក្រនៅជនបទ ទទួលបានសិទ្ធិកាន់កាប់ដីធ្លី និងសិទ្ធិប្រើប្រាស់ដីធ្លីនិងធនធានផ្សេងៗទៀត។ ជាងនេះទៅទៀត សមាសភាគរងគ្រប់គ្រងដីធ្លី មានលទ្ធផលរំពឹងទុកចំនួន៦ដែលត្រូវសម្រេចឱ្យបាន ដូចជា :

1. ជំរុញ និងបង្កភាពស៊ីចង្វាក់គ្នានៃគោលនយោបាយវិស័យ និងអន្តរវិស័យស្តីពីការគ្រប់គ្រងដីធ្លី។
2. កសាង និងតាក់តែងលិខិតបទដ្ឋានគតិយុត្តិ សម្រាប់ការកសាងផែនការប្រើប្រាស់ដីធ្លី និងការគ្រប់គ្រងដីធ្លី។
3. ពង្រឹងសមត្ថភាពស្ថាប័នរបស់ អគ្គនាយកដ្ឋានគ្រប់គ្រងដីធ្លីនិងនគរូបនីយកម្ម។
4. ផែនការប្រើប្រាស់ដីធ្លី ការផ្តល់សិទ្ធិកាន់កាប់ដីមានរយៈពេលកំណត់ និងគោលការណ៍ណែនាំ សម្រាប់ការគ្រប់គ្រងធនធាន ធម្មជាតិ ឧបករណ៍និងបែបបទផ្តល់សេវាកម្ម ត្រូវបានអនុវត្ត។
5. កែលំអលទ្ធភាពរបស់សង្គមស៊ីវិល ក្នុងការទទួលបានពតិមានស្តីពីការប្រើប្រាស់ដីធ្លី។
6. ផ្តល់វិនិយោគគាំទ្រការអនុវត្តការកសាងផែនការប្រើប្រាស់ដីធ្លី និងការគ្រប់គ្រងដីធ្លីដែលជាផ្នែកមួយនៃការគ្រប់គ្រងដីធ្លីតាមកម្មវិធីដែលបានកំណត់ទុកជាមុន នាពេលអនាគត។

ដូចមាននៅក្នុងតារាងទី១០ ថវិកាសរុបចំនួន ៦៨០.០០០ដុល្លារ របស់សមាសភាគគ្រប់គ្រងដីធ្លី ត្រូវបានវិភាជសម្រាប់ អនុវត្តសកម្មភាពនៅថ្នាក់ក្រោមជាតិ ក្នុងឆ្នាំ២០០៧។ ថវិកាចំនួន ១៨៤.០០០ដុល្លារ នឹងត្រូវប្រើសម្រាប់ការអភិវឌ្ឍន៍សមត្ថភាពបច្ចេកទេស របស់ការិយាល័យគ្រប់គ្រងដីធ្លីនៅថ្នាក់ខេត្ត និងថវិកាចំនួន ១១៣.០០០ដុល្លារ សម្រាប់ថ្នាក់ស្រុក។ មូលនិធិនេះនឹងត្រូវប្រើសម្រាប់ការបណ្តុះបណ្តាល/ការកសាងសមត្ថភាព ចំណាយប្រតិបត្តិការ ការអភិវឌ្ឍន៍ និងការអនុវត្តនូវការរៀបចំនានា ដោយផ្អែកតាមការអនុវត្តជាក់ស្តែង ស្តីពីផែនការ និងផែនទីប្រើប្រាស់ដីធ្លី ព្រមទាំងសម្រាប់ចំណាយលើវេទិកាប្រចាំត្រីមាស រួមគ្នាជាមួយនឹងសមាសភាគគ្រប់គ្រងធនធានធម្មជាតិ ក្នុងបរិបទវិមជ្ឈការ និងវិសហមជ្ឈការ។ វេទិកាប្រចាំត្រីមាសនេះ គឺជាឱកាសមួយដែលអាចពិភាក្សាអំពីការរីកចំរើន និងចែករំលែកបទពិសោធន៍រៀង១ខ្លួន។ ជាងនេះទៀត ថវិកា ៣៨២.០០០ដុល្លារ នឹងត្រូវប្រើសម្រាប់គាំទ្រ ផែនការប្រើប្រាស់ដីធ្លីនៅថ្នាក់ឃុំ ដែលជាផ្នែកស្នូលមួយ នៃដំណើរការផែនការអភិវឌ្ឍន៍ឃុំ/កម្មវិធីវិនិយោគឃុំ សកម្មភាពរៀបចំផែនទីប្រើប្រាស់ដីធ្លី ការកំណត់ព្រំដែនឃុំ ការកំណត់និងគូសផែនទីដីរបស់រដ្ឋ ការចុះបញ្ជីដីរបស់ឃុំ និងការដោះស្រាយទំនាស់ដីធ្លីនៅថ្នាក់ឃុំ។

សមាសភាគរងគ្រប់គ្រងដីធ្លីនឹងត្រូវអនុវត្តដោយអគ្គនាយកដ្ឋានគ្រប់គ្រងដីធ្លី ដែលមានការិយាល័យនៅក្នុងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ សមាសភាគរងនេះនឹងទទួលផលពីជំនួយបច្ចេកទេសជាច្រើន ទាំងនៅថ្នាក់ជាតិនិងនៅថ្នាក់ខេត្ត។ ច្បាប់ចំលងផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំ២០០៧ របស់សមាសភាគរងគ្រប់គ្រងដីធ្លីនេះ មាននៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

## ៤.៧ សហគមន៍អឺរ៉ុប

សហគមន៍អឺរ៉ុប (EC) រួមជាមួយនឹងកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP) ផ្តល់ហិរញ្ញប្បទានរួមគ្នាដល់ គម្រោងចំនួន២ ដែលត្រូវអនុវត្តក្នុងឆ្នាំ២០០៧ក្រោមក្របខ័ណ្ឌរួមគណៈកម្មាធិការដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ ដូចមានបង្ហាញនៅក្នុងតារាង១១ ស្តីពីធនធានឆ្នាំ២០០៧របស់គម្រោង EC-UNDP ថវិកាសរុបចំនួន ៤លានដុល្លារ ត្រូវបានវិភាជរួមគ្នាសម្រាប់អនុវត្តផែនការសកម្មភាពនិងថវិកាឆ្នាំ២០០៧ របស់ គម្រោងទាំងពីរ។

### ៤.៧.១ គម្រោងពង្រឹងអភិបាលកិច្ចមូលដ្ឋានតាមរយៈវិមជ្ឈការនិងលិទ្ធិប្រជាធិបតេយ្យ

ឆ្នាំ២០០៧ គឺជាឆ្នាំទី២ នៃការអនុវត្តរបស់គម្រោងពង្រឹងអភិបាលកិច្ចមូលដ្ឋាន តាមរយៈវិមជ្ឈការ និង លិទ្ធិប្រជាធិតេយ្យ (DDLG)។ គម្រោង DDLG គឺជាគម្រោងដែលមានរយៈពេល៥ឆ្នាំ ក្នុងចំនួនថវិកាសរុប ១០,៥លានអឺរ៉ូ ដែលជាថវិការួមគ្នាពីសហគមន៍អឺរ៉ុប និងកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ។ ក្រុមប្រឹក្សាឃុំ

សង្កាត់ គឺជាចំនុចចាប់ផ្តើមរបស់គម្រោងនេះ។ គម្រោង DDLG មានសមាសភាគ៣ ដែលអាស្រ័យគ្នាទៅវិញទៅមក ដូចខាងក្រោមៈ

- បង្កើតយន្តការសំដែងមតិ និងយន្តការគណនេយ្យភាព ដើម្បីកែលំអការពិភាក្សា លើកកម្ពស់ភាពជាដៃគូ និង គណនេយ្យភាព ព្រមទាំងសម្របសម្រួលការកសាងសមត្ថភាព។
- បង្កើតបណ្តាញក្រុមប្រឹក្សាឃុំនៅថ្នាក់ជាតិ និងថ្នាក់ខេត្ត ឱ្យក្លាយទៅជាអង្គភាពមួយ ដើម្បីពង្រឹងតួនាទីរបស់ ក្រុមប្រឹក្សាឃុំក្នុងដំណើរការវិមជ្ឈការ។ និង
- គាំទ្រដល់គម្រោងអន្តរឃុំនានា ដែលបំរើផលប្រយោជន៍ឱ្យប្រជាជនក្រីក្រ ឬគាំទ្រដល់កិច្ចប្រឹងប្រែងអភិវឌ្ឍន៍តំបន់មូលដ្ឋាន។

ចុងឆ្នាំ២០០៦ សម្ព័ន្ធជាតិក្រុមប្រឹក្សាឃុំសង្កាត់បានរៀបចំផែនការយុទ្ធសាស្ត្រ៣ឆ្នាំ (២០០៧-២០០៩) ផែនការសកម្មភាពនិងថវិកាឆ្នាំ២០០៧ និតិវិធីនិងជំរើសនានាអំពីការប្រមូលកំរៃសមាជិកភាព និងគោលការណ៍ណែនាំសម្រាប់ចាត់ចែងការងារបោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ ដែលពាក់ព័ន្ធនឹងសមាគមន៍ ក្រុមប្រឹក្សាឃុំសង្កាត់ ថ្នាក់ជាតិ និងថ្នាក់ខេត្ត។ ឯកសារទាំងនេះ ត្រូវបានបង្ហាញ និងអនុម័ត ក្នុងការប្រជុំសមាជិកសម្ព័ន្ធជាតិក្រុមប្រឹក្សាឃុំសង្កាត់ កាលពីថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០៧។ ការប្រឈមក្នុងឆ្នាំ២០០៧ គឺត្រូវជួយសមាគមន៍ក្រុមប្រឹក្សាឃុំសង្កាត់ ថ្នាក់ខេត្ត ក្នុងការបើកគណនីធនាគារ រៀបចំផែនការនិងថវិកា និងជ្រើសរើសបុគ្គលិកសម្រាប់លេខាធិការដ្ឋាន ដើម្បីឱ្យមានដំណើរការដូចសម្ព័ន្ធជាតិក្រុមប្រឹក្សាឃុំសង្កាត់។ ដំណើរការនេះ រំពឹងថានឹងធ្វើឱ្យសមាគមន៍ក្រុម ប្រឹក្សាឃុំ សង្កាត់ ថ្នាក់ខេត្តក្លាយទៅជាអន្តរការីសម្រាប់ការផ្លាស់ប្តូរពត៌មាន និងការតស៊ូមតិ អំពីតម្រូវការនិងចំណាប់អារម្មណ៍ របស់ក្រុមប្រឹក្សាឃុំសង្កាត់ ជាពិសេសនៅក្នុងក្របខ័ណ្ឌ កំណែទម្រង់កំពុងបន្តនេះ។

ពាក់ព័ន្ធទៅនឹងកិច្ចសហប្រតិបត្តិការអន្តរឃុំ ថវិកាសរុបសម្រាប់ឆ្នាំ២០០៧ គឺ ១.៣២០.០០០ដុល្លារ ត្រូវបានវិភាជ សម្រាប់គាំទ្រការវិនិយោគ និងសេវាកម្ម ដែលបានរៀបចំឡើងតាមរយៈការពិភាក្សា និងការរៀបចំផែនការអន្តរឃុំនៅ ក្នុងស្រុកទាំង៤៤ នៃខេត្តគោលដៅទាំង១០។ ថវិកាបន្ថែមចំនួន ១៥០.០០០ដុល្លារ ទៀត នឹងត្រូវគាំទ្រដល់គណៈកម្មាធិការប្រតិបត្តិនៃខេត្តទាំង១០ សម្រាប់ការងារសម្របសម្រួល តាមដានត្រួតពិនិត្យ និងរបាយការណ៍ ដើម្បីគាំទ្រ ដល់គម្រោងអន្តរឃុំ។ បន្ថែមលើនេះ គម្រោងមានថវិកាបន្ថែមចំនួន ២០០.០០០ដុល្លារ ទៀត សម្រាប់ប្រើប្រាស់ក្នុងឆ្នាំ២០០៧ ផ្អែកទៅតាមតម្រូវការ និងសំណើសុំមូលនិធិគម្រោង អន្តរឃុំ។

| តារាង១១: ធនធានសរុបឆ្នាំ២០០៧របស់គំរោង EC-UNDP | | | |
|---|---|---|---|
| **សមាសភាគ** | **DDLG** | **EFMP** | **សរុប** |
| **វិនិយោគ** | **2,182,508** | **1,022,000** | **3,204,508** |
| ស្រុក | 1,487,895 | | 1,487,895 |
| ខេត្ត | | 1,022,000 | 1,022,000 |
| សេវាកម្មថ្នាក់ជាតិ | 694,613 | | 694,613 |
| **គាំទ្រកម្មវិធី** | **193,581** | **55,650** | **249,231** |
| ថ្នាក់ខេត្ត | 193,581 | 55,650 | 249,231 |
| ថ្នាក់ជាតិ | | | 0 |
| **ជំនួយបច្ចេកទេស** | **512,894** | **59,000** | **571,894** |
| ថ្នាក់ខេត្ត | | 29,000 | 29,000 |
| ថ្នាក់ជាតិ | 512,894 | 30,000 | 542,894 |
| **ធនធានសរុបរបស់ EC-UNDP** | **$2,888,983** | **$1,136,650** | **$4,025,633** |
| ***ចំនួនខេត្តគ្របដណ្តប់*** | ***10*** | ***1*** | ***11*** |

### ៤.៧.២ មូលនិធិសហគមន៍អឺរ៉ុបសម្រាប់គម្រោងខ្នាតតូច (EFMP)

យោងទៅតាមកិច្ចព្រមព្រៀងបដិភាគហិរញ្ញវត្ថុរវាង UNDP និង EC គម្រោងមូលនិធិសហគមន៍អឺរ៉ុបសម្រាប់គម្រោងខ្នាតតូច (EFMP) ដែលមានរយៈពេល២ឆ្នាំក្នុងទឹកប្រាក់ចំនួន ១.៧លានអឺរ៉ូ ត្រូវបានចុះហត្ថលេខាដោយផ្ទាល់រវាង UNDP និងអភិបាលខេត្តបាត់ដំបងដែលជាប្រធានគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត កាលពីខែកក្កដា ឆ្នាំ២០០៦។ គោលដៅរួមរបស់គម្រោង គឺ ការកាត់បន្ថយភាពក្រីក្រក្នុងប្រទេសកម្ពុជា តាមរយៈការជួយស្តារឡើងវិញ នូវសេដ្ឋកិច្ចសង្គមជាមូលដ្ឋានរបស់ប្រជាជនក្នុងស្រុកគោលដៅទាំង៤ នៃខេត្តបាត់ដំបង។ គម្រោងបានដៅយកឃុំចំនួន២៤ ក្នុងស្រុក៤ ហើយនឹងផ្តល់នូវការវិនិយោគ និងសេវាសាធារណៈនានា ច្រើនក្នុងឃុំទាំងនោះ។ គម្រោងនឹងសម្រេចឱ្យបាននូវលទ្ធផលរំពឹងទុកដូចខាងក្រោម ៖

- លទ្ធភាពធ្វើដំណើរពីភូមិទៅឃុំ ពីឃុំទៅស្រុកនិងទីផ្សារ ត្រូវបានកែលំអ ព្រមទាំងស្តារឡើងវិញ នូវផ្លូវនានាក្នុងទីរួមខេត្ត ដោយដាក់បណ្តាញលូកាត់ផ្លូវឱ្យសមស្រប។
- សាងសង់សាលាបឋម និងមធ្យមសិក្សា ជាពិសេសសម្រាប់ឃុំទាំងឡាយដែលគ្មានសាលារៀន ឬសាលារៀននៅឆ្ងាយពីភូមិដែលប្រជាជនរស់នៅ។ ការសាងសង់នេះក៏រួមបញ្ចូលផងដែរនូវ ការបំពាក់គ្រឿងសង្ហារឹមចាំបាច់សម្រាប់ថ្នាក់រៀន ហើយបើចាំបាច់ ក៏ត្រូវផ្តល់ផងដែរ នូវទឹក និងអនាម័យ។
- ផ្តល់ទឹកស្អាតសម្រាប់បរិភោគ ដោយត្រូវសាងសង់មធ្យោបាយផ្គត់ផ្គង់ទឹក ជាពិសេស ដូចជា អណ្តូងស្នប់ និង អណ្តូងខួង ព្រមទាំងឧបករណ៍អនាម័យផ្សេងៗទៀត។
- ជួយស្ត្រីដែលក្រីក្រ និងដែលងាយរងគ្រោះឱ្យមានលទ្ធភាពកែលំអ ល័ក្ខខ័ណ្ឌរស់នៅរបស់ខ្លួននិងគ្រួសារដោយ ត្រូវរៀនអំពីវិជ្ជាជីវៈដែលត្រូវនឹងទីផ្សារ នៅតាមមណ្ឌលបណ្តុះបណ្តាលថ្នាក់ស្រុកថ្មី២។

ក្នុងឆ្នាំ២០០៧ ថវិកាសរុបប្រមាណ ១,១៤លានដុល្លារ ត្រូវបានបែងចែក ហើយនឹងត្រូវផ្ទេរដោយផ្ទាល់ពី UNDP ទៅ គណៈកម្មាធិការប្រតិបត្តិនៃគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្តបាត់ដំបង។ គម្រោង PSDD ជាអ្នកផ្តល់ការគាំទ្រ ផ្នែកបច្ចេកទេស។

## ៤.៨ កម្មវិធីសិទ្ធិកុមាររបស់យូនីសេហ្វ

កម្មវិធីសិទ្ធិកុមាររបស់អង្គការយូនីសេហ្វ (សកម្មភាពសហគមន៍ដើម្បីសិទ្ធិកុមារ) គឺជាកម្មវិធីមួយក្នុងចំណោមកម្មវិធីផ្សេងៗទៀត ដែលមាននៅក្នុងកម្មវិធីថ្នាក់ប្រទេសរបស់យូនីសេហ្វសម្រាប់ឆ្នាំ២០០៦ ដល់ឆ្នាំ២០១០ ដែលបាន ចុះហត្ថលេខាជាមួយក្រសួងផែនការ។ ចាប់តាំងពីឆ្នាំ២០០៤មក អង្គការយូនីសេហ្វ បានទទួលស្គាល់នូវរាល់ប្រព័ន្ធ និងរចនាសម្ព័ន្ធគ្រប់គ្រងថ្នាក់ខេត្ត សម្រាប់អនុវត្តផែនការសកម្មភាពនិងថវិកា ប្រចាំឆ្នាំរបស់កម្មវិធីសិទ្ធិកុមារ ដោយទទួលបានការគាំទ្រពីជំនួយបច្ចេកទេសរបស់គម្រោង PLG ដែលបច្ចុប្បន្នជាគម្រោង PSDD។ អនុស្សារណៈយោគយល់គ្នាថ្មីមួយ នឹងត្រូវបង្កើតឡើង ក្នុងឆ្នាំ២០០៧ ដើម្បីបន្តភាពជាដៃគូ គាំទ្រដល់កំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការរបស់រដ្ឋាភិបាល។

កម្មវិធីសិទ្ធិកុមារផ្តោតលើ ក) ការគាំទ្រកិច្ចសហប្រតិបត្តិការតាមបណ្តាក្រសួងជំនាញ រដ្ឋបាលថ្នាក់ក្រោមជាតិ (ថ្នាក់ខេត្តនិងថ្នាក់ស្រុក) ក្រុមប្រឹក្សាឃុំ ព្រមទាំងអ្នកផ្តល់សេវាសង្គមសំខាន់ៗ ក្នុងក្របខ័ណ្ឌវិមជ្ឈការ និង វិសហមជ្ឈការ ដើម្បីទទួលបាននូវការគោរពសិទ្ធិកុមារ និង ខ) ការចូលរួមកាត់បន្ថយអត្រាមរណៈដ៏ខ្ពស់ របស់កុមារ និងលើកកម្ពស់លទ្ធភាពចូលរៀនបឋមសិក្សារបស់កុមារក្នុងប្រទេសកម្ពុជា ដោយត្រូវលើកកម្ពស់លទ្ធភាពទទួលបាន ទឹកស្អាត និង អនាម័យបរិស្ថានទាំងនៅថ្នាក់សហគមន៍និងនៅតាមសាលាបឋមសិក្សានានា។

កម្មវិធីសិទ្ធិកុមារមានគោលបំណងបញ្ជាក់ និងពង្រឹងទំនាក់ទំនងរវាងភាគីពាក់ពន្ធ័នានា ក្នុងរដ្ឋាភិបាល និងសង្គមស៊ីវិល ដើម្បីជំរុញឱ្យការកសាងផែនការ ការផ្តល់សេវាកម្មនិងលទ្ធភាពទទួលបានសេវាកម្មកាន់តែមានប្រសិទ្ធិភាពនៅថ្នាក់មូលដ្ឋាន ព្រមទាំងដើម្បីលើកកម្ពស់ការផ្តល់សេវាកម្ម ទៅតាមតម្រូវការរបស់សហគមន៍ និងផ្តល់ការការពារ ដល់កុមារពីការមិនយកចិត្តទុកដាក់ ការរើសអើង ការបំពារបំពាន និងអំពើហិង្សា។ កម្មវិធីសិទ្ធិកុមារមានគម្រោងពីរគឺ :

### ៤.៨.១. អភិបាលកិច្ចមូលដ្ឋានដើម្បីសិទ្ធិកុមារ

គម្រោងនេះមានគោលបំណងពង្រឹងសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងរដ្ឋាភិបាលមូលដ្ឋាននៅថ្នាក់ខេត្ត ស្រុក និងឃុំ ដើម្បី ក)-វាយតម្លៃ និងវិភាគបញ្ហានិងអាទិភាពសំខាន់ៗពាក់ព័ន្ធទៅនឹងសិទ្ធិរបស់ស្ត្រី និងកុមារ

ខ) -ចាត់វិធានការសាមញ្ញៗ ដែលអាចអនុវត្តទៅបាន ដើម្បីដោះស្រាយបញ្ហានិងអាទិភាពទាំងនោះ និង គ) -តាមដានត្រួតពិនិត្យលទ្ធផលនៃការអនុវត្តទាំងនោះជាលក្ខណៈប្រព័ន្ធ។

គម្រោងក៏ផ្តោតផងដែរទៅលើការពង្រឹងកិច្ចសហប្រតិបត្តិការ រវាងរដ្ឋបាលថ្នាក់ខេត្ត និងស្រុក ក្រុមប្រឹក្សាឃុំ និងអ្នកផ្តល់សេវាកម្មនៅមូលដ្ឋាន ដូចជានាយកសាលា គ្រូបង្រៀន និងបុគ្គលិកសុខភាព ដើម្បីកែលំអការផ្តល់និងការប្រើប្រាស់សេវាកម្មដោយកុមារនិងស្ត្រីពេញមួយឆ្នាំៗ និងក្នុងកំឡុងពេលនៃដំណើរការ កសាងផែនការឃុំប្រចាំឆ្នាំ។

### ៤.៨.២. អនាម័យទឹកនិងបរិស្ថាន

គម្រោងនេះមានគោលបំណងកែលំអលទ្ធភាពទទួលបានទឹកស្អាត និងអនាម័យបរិស្ថាន ទាំងនៅតាមគ្រួសារនិងសាលារៀន។ គម្រោងក៏មានបំណងផងដែរ ដើម្បីពង្រឹងសមត្ថភាពរបស់ភ្នាក់សំខាន់ៗមួយចំនួនរបស់រដ្ឋាភិបាល នៅ តាមថ្នាក់នីមួយៗនៃរដ្ឋបាលស្របទៅតាមតួនាទីរៀងៗខ្លួន ដែលត្រូវផ្គត់ផ្គង់ទឹកស្អាតនិងផ្តល់សេវាអនាម័យនៅតាម ជនបទ ដោយត្រូវធានាបាននូវគុណភាពខ្ពស់។

| តារាង១២: ធនធានសរុបឆ្នាំ២០០៧របស់ UNICEF | | |
|---|---|---|
| **ប្រភេទ** | **ចំនួន** | **%** |
| **វិនិយោគ** | **2,220,897** | **79%** |
| ឃុំគោលដៅ | 318,276 | 11% |
| វិនិយោគខេត្ត | 1,441,030 | 51% |
| សេវាកម្មថ្នាក់ជាតិ | 461,591 | 16% |
| **គាំទ្រកម្មវិធី** | **295,560** | **10%** |
| ថ្នាក់ខេត្ត | 295,560 | 10% |
| **ជំនួយបច្ចេកទេស** | **300,000** | **11%** |
| ថ្នាក់ខេត្ត | 150,000 | 5% |
| ថ្នាក់ជាតិ | 150,000 | 5% |
| **សរុបរួម** | **$2,816,457** | **100%** |
| ***ចំនួនខេត្តគ្របដណ្តប់*** | *6* | |

នៅថ្នាក់ខេត្ត គណៈកម្មាធិការប្រតិបត្តិនៃគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត ជាអ្នកចាត់ចែងនិងសម្របសម្រួលរាល់សកម្មភាពដែលផ្តល់ហិរញ្ញវត្ថុដោយកម្មវិធីសិទ្ធិកុមារ។ ក្រុមប្រឹក្សាឃុំ និងមន្ទីរជំនាញថ្នាក់ខេត្ត ជាអ្នកអនុវត្តនូវ រាល់សកម្មភាពទាំងនេះ ស្របទៅតាមអណត្តិរបស់ខ្លួន។ នៅថ្នាក់ជាតិ កម្មវិធីសិទ្ធិកុមារ មានកិច្ចសហការដោយផ្ទាល់ ជាមួយក្រសួងមួយចំនួនដែលជាសមាជិករបស់ គជវវ ដូចជា ក្រសួងមហាផ្ទៃ (នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន) ក្រសួងកិច្ចការនារី ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងផែនការ។

ដូចដែលមានបង្ហាញនៅក្នុងតារាងទី១២ខាងលើ សម្រាប់ឆ្នាំ២០០៧ យូនីសេហ្វបានបែងចែកថវិកាសរុបចំនួន ២,៨លានដុល្លារ សម្រាប់កម្មវិធីនេះ។ ក្នុងឆ្នាំ២០០៧ កម្មវិធីសិទ្ធិកុមារនឹងបង្កើនចំនួនឃុំគោលដៅ របស់ខ្លួន ពី២០៣ ទៅ៣១៧ ក្នុងខេត្តគោលដៅទាំង៦។ ឃុំទាំងនោះនឹងទទួលបានការវិភាជន៍បន្ថែម ដើម្បីគាំទ្រដល់សកម្មភាពនានាពាក់ព័ន្ធស្ត្រី និងកុមារ។ ថវិកាប្រមាណ១,៤៥លានដុល្លារ ត្រូវបានរៀបចំសម្រាប់គាំទ្រដល់សកម្មភាពវិស័យដែលអនុវត្តដោយ មន្ទីរជំនាញថ្នាក់ខេត្ត ក្រោមកិច្ចសហការជាមួយក្រុមប្រឹក្សាឃុំ។ ថវិកាចំនួន ៤៦១.៥៩០ដុល្លារត្រូវបានវិភាជន៍ សម្រាប់គាំទ្រដល់ក្រសួងចំនួន៤ ដែលជាសមាជិករបស់ គ.ជ.វ.វ និងដែលមានការពាក់ព័ន្ធដ៏ជិតស្និតជាមួយកម្មវិធីសិទ្ធិកុមារ។ អង្គការយូនីសេហ្វផ្តល់បដិភាគចំនួន ២៩៥.៥៦០ដុល្លារ សម្រាប់គាំទ្រកម្មវិធីថ្នាក់ខេត្ត ដែលក្នុងនោះ ថវិកាចំនួនប្រហែល ៧៥.០០០ដុល្លារ ត្រូវបានបែងចែកសម្រាប់គាំទ្រប្រតិបត្តិការសំខាន់ៗរបស់គណៈកម្មាធិការប្រតិបត្តិខេត្ត និង ២២០.០០០ដុល្លារ សម្រាប់ផ្នែករដ្ឋបាលមូលដ្ឋានក្នុងខេត្ត ទាំង៦ ដើម្បីសម្របសម្រួលការគាំទ្រដល់ក្រុមប្រឹក្សាឃុំ ពាក់ព័ន្ធនឹងបញ្ហានានារបស់ស្ត្រីនិងកុមារ។

## ៤.៩ រដ្ឋាភិបាលកាណាដា

### ៤.៩.១ គម្រោងអភិវឌ្ឍន៍វិស័យកសិកម្មក្នុងតំបន់ដែលរងផលប៉ះពាល់ដោយគ្រាប់មីន

គម្រោងអភិវឌ្ឍន៍វិស័យកសិកម្មក្នុងតំបន់ដែលរងផលប៉ះពាល់ដោយគ្រាប់មីន (ADMAC) គឺជាគម្រោងដែលមានរយៈពេល៤ឆ្នាំ ក្នុងទឹកប្រាក់សរុបចំនួន ៤,១៧លានដុល្លារ។ ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ របស់ប្រទេសកាណាដា (CIDA) ជាអ្នកផ្តល់ហិរញ្ញវត្ថុសម្រាប់គម្រោងនេះ។ គម្រោងនេះបានចាប់ផ្តើមអនុវត្តក្នុងឆ្នាំ២០០៦ ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រោមកិច្ចសហការជាមួយអាជ្ញាធរកម្ពុជា ទទួលបន្ទុក បោសសំអាតមីននិងគ្រាប់មិនទាន់ផ្ទុះ (CMAA) ដែលជាដៃគូសហប្រតិបត្តិការ។ គម្រោង ADMAC មានបំណងចូលរួមកាត់បន្ថយភាពក្រីក្រក្នុងចំណោមប្រជាកសិករ ប្រុស-ស្រីដែលងាយរងគ្រោះ ដោយត្រូវបង្កើនសន្តិសុខស្បៀង និងប្រាក់ចំណូល ក្នុងស្រុកគោលដៅទាំង៦ ដែលរងផលប៉ះពាល់ដោយគ្រាប់មីន ក្នុងខេត្តក្រុងភាគពាយ័ព្យចំនួន៣ គឺខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង និងក្រុងប៉ៃលិន។

គម្រោង ADMAC មានសមាសភាគ២ គឺ: ១)-សមាសភាគផ្សព្វផ្សាយកសិកម្មដែលមាន៤កម្មវិធី (ដូចជា កម្មវិធី ផ្តួចផ្តើមផលិតកម្ម - PSP, កម្មវិធីកែលំអកសិកម្ម - AIP, កម្មវិធីមីក្រូហិរញ្ញវត្ថុសម្រាប់វិស័យកសិកម្ម និង ការគាំទ្រការអនុវត្ត) និង ២)-សកម្មភាពបោសសំអាតមីន។ សមាសភាគផ្សព្វផ្សាយកសិកម្ម គឺត្រូវបានរៀបចំឡើង ដោយផ្អែកយ៉ាងខ្លាំងលើបទពិសោធន៍នានា ទទួលបានពីការអនុវត្តគម្រោងមួយចំនួន ដែលគាំទ្រដោយ IFAD កន្លងមក ដូចជា គម្រោងអភិវឌ្ឍន៍វិស័យកសិកម្មគាំទ្រកម្មវិធីសិលា (ADESS) និងគម្រោង

កាត់បន្ថយភាពក្រីក្រនៅតំបន់ជនបទ (RPRP)។ កម្មវិធី PSP បានកំណត់យកក្រុមគ្រួសារក្រីក្របំផុត ដែលមានកំរិតអសន្តិសុខស្បៀងខ្ពស់ ជាក្រុមគោលដៅ ដោយត្រូវផ្តល់ទុនកសិកម្ម និងការបណ្តុះបណ្តាលជំនាញកសិកម្ម។ កម្មវិធី AIP បានកំណត់យក កសិករដែលមានបទពិសោធន៍ និងដែលមានសន្តិសុខស្បៀង ប្រសើរជាងក្រុមគោលដៅរបស់កម្មវិធី PSP ជាក្រុមគោលដៅ។ អ្នកខ្លះក្នុងចំណោមក្រុមគោលដៅរបស់កម្មវិធី AIP នឹងក្លាយទៅជាអ្នកផ្សព្វផ្សាយកសិកម្មថ្នាក់ភូមិ។ កម្មវិធីមីក្រូហិរញ្ញវត្ថុសម្រាប់វិស័យកសិកម្ម ដែលជាកម្មវិធីមួយផ្តោតលើការសន្សំប្រាក់និងក្រុមឥណទាននៅថ្នាក់ឃុំ នឹងជួយឱ្យក្រុមគោលដៅអាចទទួលបានទុន។

សមាសភាគបោសសំអាតមីន រួមមានការគាំទ្រដល់អង្គភាពផែនការបោះសំអាតមីន (MAPU) ក្នុងខេត្តគោលដៅទាំង៣។ ដោយសារសមាសភាគ PSP និងAIP នឹងត្រូវអនុវត្តក្នុងភូមិទាំងឡាយ ដែលរងផលប៉ះពាល់ ដោយគ្រាប់មីន (នៅតែមានរបាយការណ៍អំពីតំបន់ដែលសង្ស័យថាមានមីននៅក្នុងភូមិទាំងនោះ ឬ ភូមិដែលទើបតែបានបោសសំអាតមីនក្នុងពេលថ្មីៗបំផុត) MAPU នឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការរៀបចំផែនការ និងការសម្របសម្រួល រាល់ការឆ្លើយតបនានា ចំពោះស្ថានភាពផ្សេងៗនៃដីធ្លី។ ស្ថានភាពទាំងនោះអាចជាតំបន់ ដែលសង្ស័យថាមានមីន (SMA) ជំនួយដែលត្រូវផ្តល់បន្ទាប់ពីដីត្រូវបានដោះមីនហើយក្នុងពេលថ្មីៗបំផុត និង ជំនួយផ្សេងៗទៀតដែលចាំបាច់សម្រាប់ ជួយក្រុមកសិករគោលដៅរបស់កម្មវិធី PSP និង AIP ចូលរួមក្នុងការងារផលិតកម្មកសិកម្ម ហើយតំបន់ដែលសង្ស័យ ថាមានមីនតែមានភាពមិនច្បាស់លាស់ មានន័យថាតំបន់នេះ ត្រូវបានដោះមីនរួចហើយ ប៉ុន្តែប្រជាជននៅតែ ព្រួយបារម្ភអំពីសុវត្ថិភាពរបស់ពួកគេ។

**តារាង១៣: ធនធានសរុបឆ្នាំ២០០៧របស់កាណាដា**

| សមាសភាគ | ADMAC | FSIP | សរុប | % |
|---|---|---|---|---|
| **វិនិយោគ** | **907,591** | **41,900** | **949,491** | **92%** |
| ថ្នាក់ខេត្ត | 875,127 | 41,900 | 917,027 | 89% |
| សេវាកម្មនៅថ្នាក់ជាតិ | 32,464 | | 32,464 | 3% |
| **គាំទ្រកម្មវិធី** | **18,474** | **9,000** | **27,474** | **3%** |
| ថ្នាក់ខេត្ត | 18,474 | 9,000 | 27,474 | 3% |
| **ជំនួយបច្ចេកទេស** | **50,351** | **0** | **50,351** | **5%** |
| ទីប្រឹក្សាពិគ្រោះយោបល់ | 50,351 | | 50,351 | 5% |
| **សរុបរួម** | **976,416** | **50,900** | **1,027,316** | **100%** |
| ***ចំនួនខេត្តគ្របដណ្តប់*** | *3* | *1* | *4* | |

ដូចមាននៅក្នុងតារាង១៣ សម្រាប់ឆ្នាំ២០០៧ កាណាដាបានបែងចែកថវិកាសរុបចំនួន ៩៧៦.៤១៦ដុល្លារ ដើម្បីគាំទ្រ ការអនុវត្តសកម្មភាពរបស់មន្ទីរកសិកម្មថ្នាក់ខេត្ត និងអង្គភាព MAPU ក្នុងខេត្តក្រុងគោលដៅទាំង៣។

ផ្អែកលើ បទពិសោធន៍និងយុទ្ធសាស្ត្រដែលបានបង្កើតឡើងក្រោមការអនុវត្តគម្រោង RPRP/IFAD គម្រោង ADMAC យកចិត្តទុកដាក់ជាពិសេសលើការបញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្ម។ គម្រោង ADMAC នឹងបន្ត អភិវឌ្ឍន៍ របៀបរបបនៃការជ្រើសរើស និងការបណ្តុះបណ្តាលក្រុមអ្នកផ្សព្វផ្សាយថ្នាក់ឃុំ ដែលដើរតួជាអ្នកសម្របសម្រួល រវាង ក្រុមកសិករនិងការិយាល័យកសិកម្មស្រុក សម្រាប់គាំទ្រសកម្មភាពកសិកម្មនៅមូលដ្ឋាន។

### ៤.៩.២ គម្រោងសន្តិសុខស្បៀងនិងកែលំអអនាម័យ (FSIP)

យោងតាមកិច្ចព្រមព្រៀងដែលបានចុះហត្ថលេខាដោយផ្ទាល់រវាងកាណាដានិងអភិបាលខេត្តតាកែវដែលជាប្រធានគណៈកម្មាធិការអភិវឌ្ឍន៍ជនបទ កាលពីឆ្នាំ២០០៥ គម្រោង FSIP ដែលត្រូវបានពន្យាការអនុវត្តរយៈពេល២ឆ្នាំ ក្នុង ទឹកប្រាក់ចំនួន ១៥០.០០០ដុល្លារ នឹងត្រូវបញ្ចប់ការអនុវត្តរបស់ខ្លួនក្នុងឆ្នាំ២០០៧។ គណៈកម្មាធិការអភិវឌ្ឍន៍ជនបទ ខេត្តតាកែវ ជាអ្នកអនុវត្តគម្រោងនេះដោយផ្ទាល់ ដោយប្រើប្រព័ន្ធនានាដែលបាន បង្កើតឡើងក្នុងក្របខ័ណ្ឌវិមជ្ឈការ និងវិសហមជ្ឈការ ហើយគម្រោង PSDD ជាអ្នកផ្តល់ជំនួយបច្ចេកទេស។ គម្រោងនឹងត្រូវអនុវត្តក្នុងភូមិចំនួន៧៤ នៃ១៦ឃុំ ក្នុងស្រុកចំនួន៥នៃខេត្តតាកែវ ហើយគម្រោង នឹងអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍រួម ដោយផ្តោតជាពិសេស លើការកែលំអអាហារូបត្ថមរបស់ប្រជាជនក្រីក្រនៅជនបទ។ សកម្មភាពចំបងៗ របស់គម្រោងរួមមានប្រព័ន្ធកសិកម្មចំរុះ ការចិញ្ចឹមសត្វ ការចិញ្ចឹមត្រី ផ្គត់ផ្គង់ទឹកស្អាតតាមជនបទ និងការអប់រំពីអនាម័យ។ ដើម្បីអនុវត្តសកម្មភាពក្នុងឆ្នាំ២០០៧ ការិយាល័យសហប្រតិបត្តិការ របស់កាណាដា បានបែងចែកនិងផ្ទេរថវិកាសរុប ៥១.០០០ដុល្លារ ដោយផ្ទាល់ទៅឱ្យ គណៈកម្មាធិការប្រតិបត្តិខេត្តតាកែវ។

### ៤.១០ USAID/PACT : កម្មវិធីគាំទ្រកំណែទម្រង់រដ្ឋបាលមូលដ្ឋាន (គម្រោងល្អ- LAAR)

ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិរបស់សហរដ្ឋអាមេរិក (USAID) បានផ្តល់ជំនួយឥតសំណងចំនួន១៤.៤លានដុល្លារ ឱ្យអង្គការផែកកម្ពុជា ដើម្បីអនុវត្តគម្រោងរយៈពេល៥ឆ្នាំ ក្នុងគោលបំណងបង្កើនការចូលរួមរបស់ក្រុមប្រឹក្សាឃុំ និងប្រជាពលរដ្ឋ ក្នុងដំណើរការកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការនៅប្រទេសកម្ពុជា។ ឆ្នាំ២០០៧ គឺជាឆ្នាំទី២របស់ គម្រោង**ល្អ**។ គម្រោង**ល្អ**មានគោលបំណង (១)អនុវត្តក្នុង ៣០០ឃុំក្នុងខេត្តចំនួន៨ (២)បង្កើនការចូលរួមនិង លិទ្ធិប្រជាធិបតិយ្យ នៅថ្នាក់ក្រោមជាតិ (៣) កសាងទំនាក់ទំនងខ្សែបណ្តោយ និងខ្សែទទឹងរវាងរដ្ឋាភិបាលមូលដ្ឋាន រដ្ឋាភិបាលថ្នាក់ជាតិ និងសង្គមស៊ីវិល (៤) បង្កើនការចូលរួមរបស់ប្រជាជន ក្នុងដំណើរការកសាងកម្មវិធីវិនិយោគឃុំ (CIP) និងដំណើរការកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ។ ដោយ គម្រោង **ល្អ** ជាគម្រោងពហុវិស័យ គម្រោងនេះត្រូវបានរៀបចំឡើង ដោយផ្អែកលើកម្មវិធីនានា ដែលកំពុងអនុវត្តក្នុងក្របខ័ណ្ឌវិមជ្ឈការ ដោយយកចិត្តទុកដាក់ ជាពិសេសលើអភិបាលកិច្ចល្អ ក្រុមប្រជាពលរដ្ឋ ដែលមានតំណាងតិច និងការគ្រប់គ្រងធនធានធម្មជាតិ (NRM)។ គម្រោងនេះនឹងលើកកម្ពស់អភិបាលកិច្ចល្អ តាមរយៈ

ការអនុវត្តគោលការណ៍សំខាន់ទាំង៤ ដូចជា ការចូលរួម ភាពជាដៃគូ តម្លាភាព និង គណនេយ្យភាព។ គម្រោង**ល្អ** គឺអនុវត្តផ្ទាល់ដោយអង្គការផែកកម្ពុជា ហើយអនុសារណៈ យោគយល់គ្នាដែលបានចុះហត្ថលេខាដោយ UASAID និងក្រសួងមហាផ្ទៃ បានកំណត់យ៉ាងច្បាស់នូវកិច្ចសហ ប្រតិបត្តិការរវាងរដ្ឋាភិបាលទាំង២។ បន្ថែមលើនេះ អង្គការផែកកម្ពុជាក៏បានពិភាក្សានិងរៀបចំអនុសារណៈ យោគយល់គ្នាជាមួយរដ្ឋាភិបាលថ្នាក់ខេត្ត ដែលត្រូវអនុវត្តគម្រោងផងដែរ។ គម្រោង **ល្អ** មានសមាសភាគសំខាន់៧ មួយចំនួនដូចខាងក្រោម :

1. **ការគាំទ្រនិងកសាងសមត្ថភាព:** ជាអាទិភាព ការគាំទ្រនិងកសាងសមត្ថភាពត្រូវបានផ្តល់ទៅឱ្យអង្គការមិនមែនរដ្ឋាភិបាលជាដៃគូជាអ្នកអនុវត្ត។ គម្រោង **ល្អ** នឹងផ្តល់ការកសាងសមត្ថភាព ទាំងអង្គការសង្គមស៊ីវិល និងក្រុមប្រឹក្សាឃុំ ដោយផ្តោតលើ ១) ការបង្កើនការចូលរួម និងការធ្វើសេចក្តីសម្រេចចិត្ត របស់សាធារណៈជន ក្នុងការងាររបស់ក្រុមប្រឹក្សា និង២) កែលំអការគ្រប់គ្រងមូលនិធិឃុំសង្កាត់ ឱ្យកាន់តែមានតម្លាភាព និងគណនេយ្យ ភាព។

2. **មូលនិធិអភិវឌ្ឍន៍សង្គម:** គម្រោង**ល្អ** ផ្តល់ជំនួយឥតសំណងសម្រាប់គាំទ្រគម្រោងអភិវឌ្ឍន៍សង្គមដែលជាអាទិភាពអភិវឌ្ឍន៍កំណត់ឡើងដោយសហគមន៍មូលដ្ឋាន។ ឃុំគោលដៅនីមួយៗនឹងអាចទទួលបានថវិកាប្រហែល ៧.០០០ដុល្លារ ដែលនឹងត្រូវប្រើប្រាស់ក្នុងរយៈពេល៣ឆ្នាំ។ ដើម្បីបង្កើនភាពជាម្ចាស់របស់ឃុំ និងចីរភាពរបស់គម្រោង ឃុំគោលដៅនីមួយៗត្រូវចូលរួមទុនបដិភាគ។

3. **ការគាំទ្រលើការគ្រប់គ្រងជំនួយឥតសំណង:** ជំនួយឥតសំណងចំនួន ៥.០០០ដុល្លារ នឹងផ្តល់ទៅឱ្យក្រុមប្រឹក្សាឃុំដែលមានគំនិតច្នៃប្រឌិតខ្ពស់ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក អង្គការសហគមន៍មូលដ្ឋាន និងបណ្តាញថ្នាក់ភូមិ ដើម្បីគាំទ្រគម្រោងនានាដែលមានបំណងបង្កើនការចូលរួមរបស់ប្រជាពលរដ្ឋ និងផ្តោតលើបញ្ហាអន្តរវិស័យ ដូចជា អភិបាលកិច្ចល្អ ក្រុមប្រជាពលរដ្ឋដែលមានតំណាងតិច និងការគ្រប់គ្រងធនធានធម្មជាតិ។

ដូចមានបង្ហាញនៅក្នុងតារាងទី១៤ អំពីធនធានសរុបឆ្នាំ២០០៧របស់ USAID/PACT ថវិកាប្រមាណជា ១,៦៧លានដុល្លារ ត្រូវបានវិភាជនិងផ្តល់ជាជំនួយឥតសំណង ទៅឱ្យអង្គការមិនមែនរដ្ឋាភិបាលជាដៃគូ សម្រាប់គាំទ្រដល់ការកសាងសមត្ថភាព និងសកម្មភាពលើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋ។ បន្ថែមលើនេះ ថវិកាចំនួន ៦០០.០០០ដុល្លារ ត្រូវបានបែងចែកសម្រាប់អង្គការផែកកម្ពុជាផ្តល់ការគាំទ្រផ្ទាល់ ហើយថវិកាចំនួន ២៦៥.០០០ដុល្លារ ត្រូវបានផ្តល់ទៅឱ្យក្រុមប្រឹក្សាឃុំសង្កាត់ ក្នុងរូបភាពជាជំនួយឥតសំណង។ ក្នុងឆ្នាំ២០០៧ ជំនួយឥតសំណងប្រហែលជា ៦០០.០០០ដុល្លារ នឹងត្រូវផ្តល់ទៅឱ្យក្រុមប្រឹក្សាឃុំសង្កាត់ សម្រាប់គាំទ្រគម្រោងអភិវឌ្ឍន៍សង្គមក្នុងឆ្នាំ២០០៨។ សម្រាប់ផែនការសកម្មភាពនិងថវិកាឆ្នាំ២០០៧របស់ គ.ជ.វ.វ មានតែថវិកា

ដែលបានអនុម័តជាជំនួយឥតសំណង សម្រាប់ផ្តល់ទៅឱ្យក្រុមប្រឹក្សាឃុំសង្កាត់ប៉ុណ្ណោះ ដែលត្រូវបានរំលេចនៅក្នុង តារាងថវិកា។

| តារាង១៤: ធនធានសរុបឆ្នាំ២០០៧របស់ USAID/PACT | | |
|---|---|---|
| **ប្រភេទ** | **ចំនួន** | **%** |
| **វិនិយោគ** | **265,000** | **14%** |
| ឃុំគោលដៅ | 265,000 | |
| **គាំទ្រកម្មវិធី** | **1,665,000** | **86%** |
| ជំនួយឥតសំណងដល់NGOs | 1,065,000 | 55% |
| ការគាំទ្រដល់ក្រុមប្រឹក្សាឃុំរបស់គម្រោង LAAR | 600,000 | 31% |
| **សរុបរួម** | **$1,930,000** | **100%** |
| ***ចំនួនខេត្តគ្របដណ្តប់*** | *7* | |

## ៤.១១ រាជរដ្ឋាភិបាលអាល្លឺម៉ង់ (GTZ)

ក្នុងនាមជាដៃគូរអភិវឌ្ឍន៍ដើម្បីគាំទ្រវិមជ្ឈមការ និងវិសហមជ្ឈមការនៅប្រទេសកម្ពុជា កិច្ចសហការ ជាមួយភ្នាក់ងារ GTZ ត្រូវបន្តពង្រឹងតាមរយៈការពិគ្រោះយោបល់ជាប្រចាំ។ ដូចជាគម្រោង IFAD/CBRDដែរ ការគាំទ្រហិរញ្ញវត្ថុរបស់ភ្នាក់ងារ GTZ តាមរយៈគម្រោងអភិវឌ្ឍន៍ជនបទដោយមានការចូលរួម (RDP) នៅតែដើរតួនាទីដ៏សំខាន់ ក្នុងការផ្តល់ជំនួយបច្ចេកទេសជាចំបង ដើម្បីគាំទ្រដំណើរអភិវឌ្ឍន៍មូលដ្ឋាន តាមបែបវិមជ្ឈការ ការអភិវឌ្ឍន៍សហគមនិងសង្គមស៊ីវិល និងការអភិវឌ្ឍន៏វិស័យកសិកម្ម នៅក្នុងខេត្តកំពង់ធំនិង កំពត។ ជំនួយច្ចេកទេសរបស់រដ្ឋាភិបាលអាល្លឺម៉ង់ ផ្តោតលើ:

- ការពង្រឹងសមត្ថភាពចំពោះដៃគូដែលពាក់ព័ន្ធការអភិវឌ្ឍន៍នៅមូលដ្ឋាន អង្គការសង្គមស៊ីវិល វិស័យឯកជន និងបន្តគាំទ្របន្ថែម ដល់សកម្មភាពគម្រោង CBRD/RDP ។
- គាំទ្រចំពោះយុទ្ធសាស្រ្តពង្រឹងសមត្ថភាព ដល់ក្រុមគោលដៅគម្រោង CBRD និងរចនាសម្ព័ន្ធថ្នាក់ឃុំសង្កាត់ និងភូមិរបស់ពួកគេ។
- គាំទ្រដល់ការអនុវត្ត បច្ចេកទេសផ្តួចផ្តើមថ្មីៗ និងប្រព័ន្ធគ្រប់គ្រងរបស់គម្រោង CBRD ។
- ចងក្រងឯកសារដែលជាបទពិសោធន៍សម្រាប់ទុកជាមេរៀន និងប្រើប្រាស់នៅថ្នាក់ជាតិ និងវេទិកានានា។

នៅឆ្នាំ២០០៧នេះ ការគាំទ្ររបស់ GTZ ចំពោះគម្រោង CBRD នឹងផ្តោតទៅលើនិរន្តរភាពនៃសមិទ្ធផលដែលសម្រេចបាននាពេលកន្លងមក ដោយមានការពង្រឹងយន្តការ ដើម្បីធានាឱ្យមានកិច្ចសហការកាន់ តែជិតស្និតរវាងក្រុមប្រឹក្សាឃុំសង្កាត់ និងសង្គមស៊ីវិល(បណ្តាញភូមិ) ការគាំទ្រសមាគមក្រុមប្រឹក្សាឃុំ នៅថ្នាក់ខេត្ត និង

សាខាថ្នាក់ស្រុក ការពង្រឹងគណៈកម្មការបច្ចេកទេសនៅមូលដ្ឋានសម្រាប់ប្រតិបត្តិការ និង ផែនទីគម្រោង ហេដ្ឋារចនាសម្ព័ន្ធ ការពង្រឹងវិស័យឯកជនលើការអភិវឌ្ឍន៍កសិកម្ម និងការគាំទ្រដល់គ្រួសារងាយរងគ្រោះ នៅតាម ភូមិ។ លើសពីនេះ ក៏មានការគាំទ្រផ្នែកប្រព័ន្ធតាមដានលើផលប៉ះពាល់និងការចងក្រង ឯកសារផងដែរ។

ដូចបានបង្ហាញជូននៅក្នុងតារាង ១៥ ខាងក្រោមនេះ នៅឆ្នាំ ២០០៧ ជំនួយរបស់ GTZ នៃប្រទេស អាល្លឺម៉ង់ ដែលស្ថិតនៅក្រោមគម្រោងអភិវឌ្ឍន៍ជនបទដោយមានការចូលរួម (RDP) បានគាំទ្រដំណើរការអនុវត្ត គម្រោង IFAD/CBRD ដែលមានថវិកាសរុបចំនួន ៦០០.០០០ដុល្លារ។ ក្នុងនោះ ថវិកាចំនួន ៣៥០.០០០ដុល្លារ សម្រាប់កិច្ចសហការ បច្ចេកទេស និងថវិកាចំនួន ២៥០.០០០ដុល្លារ សម្រាប់គាំទ្រកម្មវិធីនៅក្នុងខេត្តចំនួន២។

| តារាង ១៥: ធនធានរបស់ GTZ អាល្លឺម៉ង់ឆ្នាំ ២០០៧ | | |
|---|---|---|
| **ផ្នែក** | **ចំនួន** | **%** |
| **វិនិយោគ** | **0** | **0%** |
| **គាំទ្រកម្មវិធី** | **250,000** | **42%** |
| **គាំទ្របច្ចេកទេស** | **350,000** | **58%** |
| **ថ្នាក់ខេត្ត** | 350,000 | 58% |
| **ថ្នាក់ជាតិ** | 0 | 0% |
| **សរុបរួម** | **$600,000** | **100%** |
| **ខេត្តគ្របដណ្តប់** | ***2*** | |

## ៤.១២ ការគាំទ្ររបស់អង្គការ UNFPA ក្នុងការអនុវត្តកម្មវិធីវិមជ្ឈការ និងវិសហមជ្ឈការ

មូលនិធិអង្គការសហប្រជាជាតិសម្រាប់សកម្មភាពប្រជាជន (UNFPA) បានចុះកិច្ចព្រមព្រៀងលើ ផែនការ សកម្មភាព និងថវិកាជាមួយនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ ដើម្បីគាំទ្រការពង្រឹងសមត្ថភាព លើបញ្ហាប្រជាជន ដល់អ្នកពាក់ព័ន្ធការងារវិមជ្ឈការ ក្រុមប្រឹក្សាឃុំសង្កាត់ អ្នកទទួលបន្ទុកស្ត្រីនិងកុមារ សមាជិក សហគម ដែលស្ថិតនៅក្នុងខេត្តនិងឃុំគោលដៅ។ លទ្ធផលរំពឹងទុកនៃការចុះកិច្ចព្រមព្រៀងនេះរួមមាន ១) ការ រៀបចំគោលនយោបាយជាតិប្រជាជន និងកសាងផែនការវិមជ្ឈការទាក់ទងទៅនឹងបញ្ហាប្រជាជន និងកាត់បន្ថយ ភាពក្រីក្រនិង ការអភិវឌ្ឍមូលដ្ឋាន។ ២) យន្តការស្ថាប័ន និងការអនុវត្តនៃវប្បធម៌សង្គមត្រូវបាន ជំរុញព្រមទាំង ការពារនូវសិទ្ធរបស់ស្ត្រី និងកុមារី ដើម្បីធានាឱ្យមានសមធម៌យេនឌ័រ នៅក្នុងសង្គម។ ៣) បង្កើនចំណេះដឹង និង សិទ្ធិអំណាចរបស់ស្ត្រី និងយុវវ័យ ដែលពាក់ព័ន្ធទៅនឹងសិទ្ធិបន្តពូជ ដោយរួមទាំងសេវាសុខភាព បន្តពូជផងដែរ។

នៅក្នុងឆ្នាំ២០០៧ សកម្មភាពបណ្តុះបណ្តាល និងលើកកំពស់ចំណេះដឹងដែលពាក់ព័ន្ធទៅ នឹងសុខភាព សហគមន៍ សុខភាពបន្តពូជ និងសមធិមយេនឌ័រ នឹងត្រូវបានអនុវត្តនៅក្នុងឃុំគោលដៅចំនួន១៥១ ក្នុងខេត្តចំនួន៥ ដោយមានការបន្សុីគ្នាជាមួយដំណើរការរៀបចំកម្មវិធីវិនិយោគឃុំ សង្កាត់ ក្នុងគោលបំណងជំរុញផែនការអភិឌ្ឍន៍ នៅមូលដ្ឋាន និងបញ្ហាប្រជាជន។

នៅក្នុងតារាងទី១៦ខាងក្រោមនេះ បង្ហាញថាឃុំចំនួន១៥១ នឹងទទួលបានការគាំទ្រនូវថវិកាចំនួន ៧៥.៥០០ដុល្លារ ដែលឃុំនីមួយៗទទួលបានថវិកា ៥០០ដុល្លារ ដើម្បីអនុវត្តសកម្មភាពខាងលើ។ ក្រៅពីនោះ ថវិកាចំនួន ២៥.៨៤០ ដុល្លារ ត្រូវបានផ្តល់ឱ្យផ្នែករដ្ឋបាលមូលដ្ឋាននៅថ្នាក់ខេត្ត និង៧៤.០០០ដុល្លារ សម្រាប់នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្នុងការគាំទ្រសកម្មភាព វេទិកា សិក្ខាសាលា វគ្គបណ្តុះបណ្តាលដល់គ្រូឧទ្ទេស និង សកម្មភាពចុះតាមដាន។

| តារាង១៦: ប្រភពធនធានរបស់UNFPA នៅឆ្នាំ ២០០៧ | | |
|---|---|---|
| **ផ្នែក** | **ចំនួន** | **%** |
| **ការវិនិយោគ** | **149,660** | **85%** |
| ឃុំគោលដៅ | 75,500 | 43% |
| សេវាកម្មថ្នាក់ជាតិ | 74,160 | 42% |
| **គាំទ្រកម្មវិធី** | **25,841** | **15%** |
| ខេត្ត | 25,841 | 15% |
| **សរុបរួម** | **$175,501** | **100%** |
| ***ខេត្តគោលដៅ*** | *5* | |

## ៤.១៣ ដៃគូជាមួយអង្គការមិនមែនរដ្ឋាភិបាល (NGO)

**អង្គការ GRET:** ស្ថិតនៅក្រោមកម្មវិធីថ្មីមួយដែលមានឈ្មោះថា PACEPAC អង្គការ GRET នឹងបន្តការងាររបស់ខ្លួនក្នុងការកែលំអអនាម័យ និងលទ្ធភាពប្រើប្រាស់ទឹកស្អាតនៅតំបន់គោលដៅ ជាពិសេស ការបង្កើតប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតនៅតំបន់ទីប្រជុំជន ដែលអ្នកពាក់ព័ន្ធរួមមាន វិស័យឯកជន និងសហគមអ្នកប្រើប្រាស់ទឹក។ យោងតាមអនុសារណៈយោគយល់ ដែលបានចុះកិច្ចព្រមព្រៀងជាមួយ គ.ប្រ/គ.អ.ជ.ខ នៃខេត្ត តាកែវ និង កណ្តាល ខេត្តនីមួយៗនឹងត្រូវជ្រើសរើសឃុំសាកល្បងចំនួនមួយ ដោយផ្អែកទៅលើឆន្ទៈរបស់ពួកគេ ក្នុងការអនុវត្តផែនការអនាម័យនិងទឹកស្អាតជាមួយសហគម។ ថវិកាប្រមាណ ៣៥.០០០ដុល្លារ នឹងត្រូវផ្តល់ជូនដល់ ខេត្តគោលដៅនីមួយៗ ក្នុងការគាំទ្រសកម្មភាពដែលបានផ្តួចផ្តើមនេះ ក្នុងនោះថវិកា ៤.៥០០ដុល្លារ សម្រាប់គាំទ្របណ្តុះបណ្តាល កិច្ចសម្របសម្រួលនិងការគ្រប់គ្រងនិង ទឹកប្រាក់ចំនួន ៣០.០០០ដុល្លារ សម្រាប់ចំណាយលើ

វិនិយោគកម្មវិធី។ នៅក្នុងកិច្ចព្រមព្រៀងបានចែងថា គ.ប្រ/គ.អ.ជ.ខ ជាអ្នកគ្រប់គ្រងកិច្ចសន្យានិងអនុវត្តកិច្ចសន្យាតាមរយៈប្រព័ន្ធកម្មវិធីនៅថ្នាក់ខេត្ត។

ក្រៅពីអង្គការជាដៃគូរខាងលើដែលធ្វើការផ្ទាល់ នៅមានអង្គការរាប់រយផ្សេងទៀតបានធ្វើការជា ប្រយោលនៅក្នុងប្រទេស ដែលទាក់ទងទៅនឹងការពិគ្រោះយោបល់និង កិច្ចសហការពាក់ព័ន្ធបញ្ហាអភិបាលកិច្ចមូលដ្ឋាន និងអភិវឌ្ឍន៍។ ឧទាហរណ៍អំពីបណ្តាញការងារ និងសុខដុមនីយកម្ម ដែលបានបង្កើតឡើងតាមរយៈ សិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុកក្នុងឆ្នាំ២០០៦ យើងឃើញថាមានអង្គការជាតិនិងអន្តរជាតិប្រហែល ៣០០ បានសន្យាផ្តល់ការគាំទ្រចំពោះគម្រោងវិនិយោគអាទិភាពនិង ការផ្តល់សេវាកម្មរបស់ឃុំ សង្កាត់ ដែលបានលើកឡើងដោយចុះកិច្ចសន្យាបណ្តោះអាសន្នចំនួនប្រហែលជា ១៤.០០០ ជាមួយឃុំ សង្កាត់។ កិច្ចសម្របសម្រួល និងពិគ្រោះយោបល់ ត្រូវបានអនុវត្តនៅគ្រប់កម្រិត ក្នុងដំណើរការតាមដាននិងអនុវត្តកិច្ចសន្យាទាំងនេះ។ ក្រៅពីនោះ នៅបណ្តាខេត្តភាគច្រើន វេទិកាអភិវឌ្ឍន៍នៅថ្នាក់ខេត្តមានការចូលរួមយ៉ាងសកម្មពីតំណាងអាជ្ញាធរ គ្រប់លំដាប់ថ្នាក់ អង្គការជាតិ និងអន្តរជាតិ ក្នុងការដោះស្រាយបញ្ហា ចែករំលែកបទពិសោធន៍និង ពង្រឹង កិច្ចសហប្រតិបត្តិការ។

## ៥. កិច្ចព្រមព្រៀងហិរញ្ញវត្ថុ លំហូរមូលនិធិ ការអនុវត្ត និងការចាត់ចែងកិច្ចសន្យា

គ្រប់ធនធានទាំងអស់ខាងលើ ត្រូវបានអនុម័តក្រោមកិច្ចព្រមព្រៀងហិរញ្ញវត្ថុផ្សេងៗគ្នា រវាងភ្នាក់ងារផ្តល់ជំនួយនិងរាជរដ្ឋាភិបាលកម្ពុជា។ ភាពទាក់ទិនជាមួយនឹង ផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំរបស់ គជវវ ត្រូវបានបកស្រាយ នៅក្នុងកិច្ចព្រមព្រៀងនានានោះតែម្តង ក្នុងទម្រង់ជា អនុសារណៈនៃការយោគយល់ ដែលរួមបញ្ចូលទាំងកិច្ចព្រមព្រៀងជាក់លាក់ជាមួយនឹងអាជ្ញាធរខេត្តក្រុងផង ឬត្រូវពិភាក្សាបញ្ជាក់ថែមតាមរយៈការចាត់ចែងជាក់ស្តែង។ ចំពោះស្ថាប័ន ហិរញ្ញវត្ថុអន្តរជាតិ ធនធានហិរញ្ញ វត្ថុត្រូវបានផ្ទេរពីគណនីពិសេសនៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទៅភ្នាក់ងារអនុវត្តនៅថ្នាក់ជាតិ និងថ្នាក់ខេត្តក្រុង តាមរយៈប្រព័ន្ធរតនាគារជាតិ ឬធនាគារពាណិជ្ជ។ ចំពោះជំនួយគាំទ្រជាទ្វេ ឬពហុភាគី ធនធានហិរញ្ញវត្ថុត្រូវបានផ្ទេរ ទៅគណនីគំរោងដែលគ្រប់គ្រងដោយភ្នាក់ងារអនុវត្ត និងត្រូវបានផ្ទេរពី គណនីគំរោងទៅអោយអាជ្ញាធរថ្នាក់ក្រោមជាតិ។ នៅពេលថ្នាក់ខេត្តក្រុងទទួលបានការធនធានហិរញ្ញវត្ថុហើយ ធនធានហិរញ្ញវត្ថុទាំងនោះត្រូវប្រើប្រាស់ ដោយអនុវត្តតាមនីតិវិធីគ្រប់គ្រងកិច្ចសន្យា គ្រប់គ្រងហិរញ្ញវត្ថុ ទូទាត់កិច្ចបញ្ជីការ និងប្រព័ន្ធរបាយការណ៍រួមតែមួយ ដែលនីតិវិធិទាំងនោះ ត្រូវបានកំណត់នៅក្នុងសៀវភៅណែនាំ ដែលអនុម័តដោយ គជវវ **(NCDD)**។

ដើម្បីបំពេញតម្រូវការរបស់ភ្នាក់ងារផ្តល់ជំនួយផ្សេៗពីគ្នា លើកិច្ចព្រមព្រៀងហិរញ្ញវត្ថុ និងលំហូរមូលនិធិពីថ្នាក់ជាតិទៅថ្នាក់ខេត្ត-ក្រុង ក្របខ័ណ្ឌផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់គណៈកម្មាធិការជាតិគាំទ្រកំណែទំរង់វិមជ្ឈការ និងវិសហមជ្ឈការបានធានាចំពោះចំណុចសំខាន់ៗរបស់កម្មវិធី និងការរៀបចំកិច្ចសន្យាអោយមាន

| កំពង់ចាម | 2,595,270 | 588,552 | 570,000 | 322,446 | **4,076,268** | 300,603 | **4,376,871** | 81,571 | 0 | **81,571** | **4,458,442** |
| កំពង់ឆ្នាំង | 861,574 | 50,028 | 175,000 | 70,800 | **1,157,402** | 162,602 | **1,320,004** | 75,406 | 11,000 | **86,406** | **1,406,409** |
| កំពង់ស្ពឺ | 1,327,957 | 413,770 | 210,000 | 519,894 | **2,471,621** | 252,856 | **2,724,477** | 96,651 | 0 | **96,651** | **2,821,128** |
| កំពង់ធំ | 1,108,165 | 133,034 | 25,000 | 825,956 | **2,092,155** | 202,527 | **2,294,682** | 191,895 | 71,000 | **262,895** | **2,557,576** |
| កំពត | 1,071,257 | 0 | 25,000 | 1,022,478 | **2,118,735** | 168,762 | **2,287,497** | 159,841 | 55,000 | **214,841** | **2,502,338** |
| កណ្ដាល | 1,950,806 | 45,900 | 205,000 | 129,925 | **2,331,631** | 244,057 | **2,575,688** | 80,993 | 0 | **80,993** | **2,656,681** |
| កោះកុង | 343,501 | 105,348 | 270,000 | 136,668 | **855,517** | 154,980 | **1,010,497** | 51,353 | 0 | **51,353** | **1,061,850** |
| ក្រចេះ | 542,655 | 200,043 | 150,000 | 447,659 | **1,340,357** | 131,702 | **1,472,059** | 63,946 | 0 | **63,946** | **1,536,005** |
| មណ្ឌលគិរី | 204,406 | 82,205 | 150,000 | 132,066 | **568,677** | 103,804 | **672,482** | 60,209 | 0 | **60,209** | **732,691** |
| ភ្នំពេញ | 1,213,340 | 0 | 115,000 | 114,400 | **1,442,740** | 157,679 | **1,600,419** | 70,451 | 0 | **70,451** | **1,670,870** |
| ព្រះវិហារ | 510,062 | 0 | 25,000 | 492,632 | **1,027,694** | 123,336 | **1,151,030** | 71,319 | 0 | **71,319** | **1,222,349** |
| ព្រៃវែង | 1,683,717 | 690,650 | 205,000 | 1,813,966 | **4,393,333** | 288,692 | **4,682,025** | 116,734 | 0 | **116,734** | **4,798,759** |
| ពោធិសាត់ | 685,183 | 438,891 | 180,000 | 173,584 | **1,477,658** | 144,998 | **1,622,656** | 172,403 | 100,000 | **272,403** | **1,895,059** |
| រតនគិរី | 493,183 | 185,003 | 360,000 | 584,431 | **1,622,617** | 176,052 | **1,798,669** | 67,022 | 0 | **67,022** | **1,865,692** |
| សៀមរាប | 1,344,605 | 474,433 | 300,000 | 223,363 | **2,342,401** | 211,432 | **2,553,833** | 156,851 | 71,000 | **227,851** | **2,781,684** |
| ក្រុងព្រះសីហនុ | 266,876 | 83,063 | 180,000 | 137,818 | **667,757** | 112,448 | **780,205** | 50,543 | 0 | **50,543** | **830,748** |
| ស្ទឹងត្រែង | 332,773 | 18,822 | 25,000 | 242,675 | **619,270** | 153,630 | **772,900** | 82,059 | 0 | **82,059** | **854,959** |
| ស្វាយរៀង | 1,023,978 | 404,064 | 145,000 | 1,422,653 | **2,995,695** | 244,630 | **3,240,325** | 106,751 | 0 | **106,751** | **3,347,076** |
| តាកែវ | 1,461,191 | 77,700 | 175,000 | 146,275 | **1,860,166** | 217,754 | **2,077,920** | 65,026 | 0 | **65,026** | **2,142,946** |
| ឧត្តរមានជ័យ | 311,507 | 31,537 | 25,000 | 136,962 | **505,006** | 143,299 | **648,305** | 85,959 | 0 | **85,959** | **734,264** |
| ក្រុងកែប | 57,219 | 18,878 | 60,000 | 88,298 | **224,395** | 57,230 | **281,625** | 26,784 | 0 | **26,784** | **308,409** |
| ក្រុងប៉ៃលិន | 105,681 | 0 | 25,000 | 280,986 | **411,667** | 71,215 | **482,882** | 26,784 | 0 | **26,784** | **509,666** |
| **សរុបរួម** | **$21,841,463** | **$4,281,104** | **$3,650,000** | **$11,296,254** | **$41,068,821** | **$4,175,834** | **$45,244,655** | **$2,151,829** | **$319,000** | **$2,470,829** | **$47,715,484** |
| | **$26,122,567** | | | | | | | | | | |

| តារាងទី២០ : សរុបសង្ខេបថ្នាក់ជាតិ | | | | | | |
|---|---|---|---|---|---|---|
| ស្ថាប័នថ្នាក់ជាតិ | សេវាកម្ម | កិច្ចសហប្រតិបត្តិការបច្ចេកទេស | | | | សរុបរួម |
| | | ថ្នាក់ជាតិ | អន្តរជាតិ | ក្នុងស៊ុលតង់ | សរុប | |
| នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន/ ក្រសួងមហាផ្ទៃ | **1,960,273** | 999,931 | 859,000 | 530,697 | **2,389,628** | **4,349,901** |
| ហិរញ្ញវត្ថុ/ រតនាគារ | **67,064** | 17,292 | 25,000 | | **42,292** | **109,356** |
| ផែនការ | **85,000** | 30,292 | 50,000 | | **80,292** | **165,292** |
| អភិវឌ្ឍន៍ជនបទ | **508,881** | 10,000 | 45,000 | | **55,000** | **563,881** |
| កិច្ចការនារី | **97,090** | 10,000 | 45,000 | | **55,000** | **152,090** |
| ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល | **20,000** | | | | **0** | **20,000** |
| រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ | **10,000** | | | | **0** | **10,000** |
| **សរុបរង សមាជិកគ.ជ.វ.វ** | **2,748,308** | **1,067,515** | **1,024,000** | **530,697** | **2,622,212** | **5,370,520** |
| កសិកម្ម | **402,355** | 35,000 | 96,750 | 181,655 | **313,405** | **715,760** |
| ធនធានទឹក | **20,000** | 0 | 0 | | **0** | **20,000** |
| សង្គមកិច្ច | **20,000** | 0 | 0 | | **0** | **20,000** |
| គ្រប់គ្រងដីធ្លី | **3,500** | 0 | 0 | | **0** | **3,500** |
| បរិស្ថាន | **20,000** | 0 | 0 | | **0** | **20,000** |
| អាជ្ញាធរមីនកម្ពុជា | **5,000** | 0 | 0 | | **0** | **5,000** |
| **សរុប** | **3,219,163** | **1,102,515** | **1,120,750** | **712,352** | **2,935,617** | **6,154,780** |
| ក្រុមគាំទ្រកម្មវិធី គ.ជ.វ.វ | **912,960** | 154,682 | 461,664 | 827,000 | **1,443,346** | **2,356,306** |
| **សរុបរួម** | **$4,132,123** | **$1,257,197** | **$1,582,414** | **$1,539,352** | **$4,378,963** | **$8,511,086** |

## ៨. ការវិភាគថវិកាតាមសមាសភាគ

### ៨.១ មូលនិធិឃុំ សង្កាត់

### ៨.១.១ ធនធានមូលនិធិ

ធនធានមូលនិធិដែលបានវិភាជន៍ជូនដល់ឃុំសង្កាត់ សំរាប់ឆ្នាំថវិកា២០០៧ បានមកពីប្រភពមួយចំនួន ដូចជាៈ

**រាជរដ្ឋាភិបាលៈ** យោងតាមអនុក្រឹត្យលេខ ១១ ការចូលរួមពីថវិកាជតិទៅក្នុងមូលនិធិឃុំសង្កាត់ សំរាប់ឆ្នាំ២០០៧ ត្រូវបានកំណត់ចំនួនស្មើនឹង ២,៥៦% នៃចំណូលចរន្ត។ ការចូលរួមពីថវិកាជាតិទៅក្នុងមូលនិធិឃុំសង្កាត់ សំរាប់ឆ្នាំ២០០៧ មានចំនួន ៨៣.៥០០.០០០រៀល ស្មើនឹង ២០.៣៦៥.៨៥៤ដុល្លារ សហរដ្ឋអាមេរិក។ ថវិកាចំនួន ៤.០០០.០០០.០០០រៀល ត្រូវបានបន្ថែមសំរាប់រ៉ាប់រងចំណាយប្រាក់ឧបត្ថម្ភប្រធានភូមិ អនុប្រធានភូមិ និងជំនួយការភូមិ ហើយដែលជាលទ្ធផលនាំអោយការចូលរួមពីថវិកាជាតិទៅក្នុងមូលនិធិឃុំសង្កាត់ ឆ្នាំ២០០៧ មានចំនួនរហូតដល់ទៅ ៨៧.០០០លានរៀល (ស្មើនឹង ២១,៣៤លានដុល្លារ សហរដ្ឋអាមេរិក)។ ថវិកាមូលនិធិឃុំសង្កាត់ឆ្នាំ២០០៧ មានចំនួនកើនឡើងច្រើនជាងថវិកាមូលនិធិឃុំសង្កាត់ ឆ្នាំ២០០៦ ប្រមាណ២៦% ដែលស្មើនឹងថវិកាចំនួន ១៧,៩ពាន់លានរៀល (៤,៤ លានដុល្លារសហរដ្ឋអាមេរិក)។

**គំរោងគាំទ្រការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យតាមរយៈវិមជ្ឈការ និងវិសហមជ្ឈការ (PSDD):** គំរោង **PSDD** បានបញ្ជាក់ការសន្យារបស់ខ្លួននៅខែកញ្ញា ឆ្នាំ២០០៦ ថានឹងចូលរួមថវិកាចំនួន ៥សែននដុល្លារ ទៅក្នុងមូលនិធិឃុំសង្កាត់ ឆ្នាំ២០០៧ ដែលចំនួននេះស្មើនឹង ២,០៥ពាន់លានរៀល ដែលចំនួននេះតិចជាង ចំនួនថវិកាគំរោង **PLG** បានចូលរួមទៅក្នុងមូលនិធិឃុំសង្កាត់ ឆ្នាំ២០០៦ ដែលមានចំនួនដល់ទៅ១,៥ លានដុល្លារ ការថយចំនួនថវិកានេះបណ្តាលមកពីការកាត់បន្ថយថវិកាជារួម និងតម្រូវការថវិកានៅក្នុងខ្ទង់ថវិកាដីទៃ ទៀត។

**គំរោងវិនិយោគជនបទ និងអភិបាលកិច្ចមូលដ្ឋានរបស់ធនាគារពិភពលោក (World Bank RILG):** ស្ថិតក្រោម កំចីឥណទានរបស់ធនាគារពិភពលោក រំពឹងថាធនាគារពិភពលោក នឹងទូទាត់សងវិញដល់រាជរដ្ឋាភិបាលក្នុងឆ្នាំ២០០៧ នូវថវិកាចំនួនប្រមាណ ៥,៧លានដុល្លារ សំរាប់គំរោងមូលនិធិឃុំសង្កាត់ ឆ្នាំ២០០៦ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងកំពុងអនុវត្តនៅខេត្តក្រុងទាំង១៤ ក្នុងកំឡុងត្រីមាសទី១នៃឆ្នាំ ២០០៧។ ផ្អែកតាមកិច្ចព្រមព្រៀងក្នុងឆ្នាំ២០០៣ រាល់ការទូទាត់សងវិញពីធនាគារពិភពលោក នឹងត្រូវយកមកប្រើប្រាស់ សំរាប់គោលបំណងរបស់មូលនិធិឃុំសង្កាត់ ហើយករណីនេះនឹងត្រូវយកមកអនុវត្តសំរាប់មូលនិធិឃុំសង្កាត់ ឆ្នាំ២០០៧ដែរ។ កំចីឥណទានរបស់ធនាគារពិភពលោកមិនមែនជាធនធានបន្ថែមលើមូលនិធិឃុំសង្កាត់ ដែលមានស្រាប់នេះទេ តែវាជាការគាំទ្រដល់ថវិកាជាតិ ហើយវាជាការចូលរួមយ៉ាងសំខាន់ ដល់ចលនាសាច់ប្រាក់របស់ មូលនិធិផងដែរ។ ដោយរង់ចាំការចរចាររវាងធនាគារពិភពលោក ជាមួយនឹងរាជរដ្ឋាភិបាល លើការពន្យាពេល អនុវត្តគំរោង

សំរាប់៣ឆ្នាំបន្តទៅមុខទៀត ដែលរួមជាមួយនឹងការបង្កើនថវិកាច្រើនគួរសម ហើយដែលទំនងជាថាគំរាង មូលនិធិឃុំសង្កាត់ ឆ្នាំ២០០៧ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ នឹងអាចទទួលបានហិរិញ្ញប្បទានពីឥណទាន នេះ។

**តារាងលេខ២១** ខាងក្រោម ឆ្លុះបញ្ចាំងពីចំនួនថវិកាដែលបានចូលរួមដល់ឃុំ សង្កាត់ និង ចំនួនសមាមាត្រដោយរួមបញ្ចូលនឹង ការរំពឹងទុកនៃការទូទាត់សងវិញរបស់ធនាគារពិភពលោក។

| តារាងលេខ ២១: មូលនិធិឃុំ សង្កាត់ឆ្នាំ២០០៧ និងចំនួនសមាមាត្រ | | | | | |
|---|---|---|---|---|---|
| ប្រភព | រៀល | ដុល្លារ | ចំនួនវិភាជន៍ | | |
| | | | រៀល | ដុល្លារ | % |
| រាជរដ្ឋាភិបាល | 87,500,000,000 | 21,341,463 | 64,199,700,000 | 15,658,463 | 72% |
| ធនាគារពិភពលោក | | | 23,300,300,000 | 5,683,000 | 26% |
| ភីអេសឌីឌី | 2,050,000,000 | 500,000 | 2,050,000,000 | 500,000 | 2% |
| **សរុប** | **89,550,000,000** | **$21,841,463** | **89,550,000,000** | **$21,841,463** | **100%** |

## ៨.១.២ ការធ្វើកម្មវិធិលើធនធានមូលនិធិឃុំ សង្កាត់

ការធ្វើកម្មវិធីនៃធនធានមូលនិធិឃុំ សង្កាត់អនុវត្តស្របតាមប្រការទាំងឡាយដែលមានក្នុងអនុក្រឹត្យលេខ ១១ ដែលបានកំណត់ថា ធនធានមិនច្រើនជាង ៣៣% នៃធនធានសរុបត្រូវបែងចែកសំរាប់សមាសភាគរដ្ឋបាលទូទៅ និងធនធានមិនតិចជាង ៦៦% នៃធនធានសរុបត្រូវបែងចែកសំរាប់សមាសអភិវឌ្ឍន៏មូលដ្ឋាន។ ធនធានមូលនិធិសរុប ដែលរួមបញ្ចូលគ្នាពីការចូលរួមរបស់ថវិកាជាតិ និងការចូលរួមថវិការបស់គំរោង **PSDD** ត្រូវបានចាត់កម្មវិធីស្របតាម ប្រការទាំងឡាយនៃអនុក្រឹត្យនេះ។ ដោយពិនិត្យលើតម្រូវការថវិកាបន្ថែម ក្រោយពេលដែលមានការបង្កើន ប្រាក់ឧបត្ថម្ភដល់ប្រធានភូមិ អនុប្រធានភូមិ និងជំនួយការភូមិមកវាត្រូវបានកត់សម្គាល់ឃើញថា មូលនិធិសំរាប់ តម្រូវការរបស់ក្រុមប្រឹក្សាឃុំ សង្កាត់លើផ្នែករដ្ឋបាលទូទៅមានការថយចុះយ៉ាងខ្លាំង ដោយថវិកាមួយចំនួនធំ ត្រូវរ៉ាប់រងលើចំណាយបន្ថែមនេះ។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលបានយល់ព្រម ក្នុងការរក្សាទុកនូវកំរិតថវិកា សំរាប់ចំណាយ រដ្ឋបាលទូទៅស្មើនឹងកំរិថវិកាសំរាប់ចំណាយរដ្ឋបាលទូទៅរបស់មូលនិធិឃុំ សង្កាត់ឆ្នាំ២០០៦ តាមរយៈការបន្ថែម ថវិកាសំរាប់រ៉ាប់រងលើប្រាក់ឧបត្ថម្ភភូមិ ហើយដែលចំណុចទាំងនេះ ត្រូវបានឆ្លុះបញ្ចាំង នៅក្នុងតារាងលេខ ២២ ខាងក្រោមៈ

| តារាងលេខ ២២: ការវិភាជន៍ថវិកាឃុំ សង្កាត់ឆ្នាំ២០០៧ តាមសមាសសភាគ | | | | |
|---|---|---|---|---|
| **សមាសសភាគមូលនិធិឃុំ សង្កាត់** | **ចំនួនវិភាជន៍** | **%** | **ចំនួនជាមធ្យម/ឃុំ សង្កាត់** | |
| | | | **រៀល** | **ដុល្លារ** |
| **រដ្ឋបាលទូទៅ** | 28,514,000,000 | 32% | 17,590,376 | 4,290 |
| **ប្រាក់ឧបត្ថម្ភភូមិ** | 4,000,000,000 | 4% | 2,467,613 | 602 |
| **សរុបរង** | **32,514,000,000** | **36%** | **20,057,989** | **4,892** |
| **អភិវឌ្ឍន៍មូលដ្ឋាន** | 57,036,000,000 | 64% | 35,185,688 | 8,582 |
| **សរុប** | **89,550,000,000** | **100%** | **55,243,677** | **$13,474** |

**សមាសសភាគរដ្ឋបាលទូទៅនៃមូលនិធិឃុំ សង្កាត់:** សមាសសភាគរដ្ឋបាលទូទៅត្រូវបានបែងចែកដោយផ្អែកតាមចំនួន ក្រុមប្រឹក្សាឃុំសង្កាត់ ដែលចំនួននេះត្រូវបានកំណត់តាមចំនួនប្រជាពលរដ្ឋ។ ដើម្បីពង្រឹងគណនេយ្យភាពរបស់ ភូមិចំពោះក្រុមប្រឹក្សាឃុំ សង្កាត់ដែលត្រូវបានជ្រើសរើសនៅថ្នាក់មូលដ្ឋាន។ ដូចការកត់ចំណាំខាងលើដើម្បីកាត់បន្ថយផលប៉ះពាល់ជារួម ដល់ថវិការដ្ឋបាលឃុំសង្កាត់ ដែលបណ្តាលមកពីការការកើតឡើងចំណាយដល់ ទៅបួនដងនៃចំណាយប្រាក់ឧបត្ថម្ភភូមិ នោះថវិកាវិភាជន៍បន្ថែមត្រូវធ្វើឡើងសំរាប់ថវិកាមូលនិធិឆ្នាំ២០០៧ ដើម្បីរ៉ាប់រងលើចំណាយប្រាក់ឧបត្ថមភូមិដែលមានការកើនឡើងនោះ។ ដូចដែលបានឆ្លុះបញ្ចាំងក្នុងតារាងលេខ ២៣ ខាងក្រោម ការរួមបញ្ចូលចំណាយសំរាប់ប្រាក់ឧបត្ថមក្រុមប្រឹក្សា ឃុំសង្កាត់ និងចំណាយសំរាប់ប្រាក់ឧបត្ថមភូមិក្នុងឆ្នាំ២០០៧ មានចំនួនជិតដល់៨០% នៃថវិកាវិភាជន៏សរុបសំរាប់សមាសសភាគរដ្ឋបាលទូទៅ។ ថវិកាសំរាប់រ៉ាប់រង ចំណាយរដ្ឋបាលក្រៅពីប្រាក់ឧបត្ថម្ភមានចំនួនជាមធ្យម ១,៥៩៤ដុល្លារ ក្នុងឆ្នាំ២០០៦ តែនៅឆ្នាំ២០០៧ ថវិកាសំរាប់រ៉ាបរងចំណាយរដ្ឋបាល ក្រៅពីប្រាក់ឧបត្ថម្ភមានចំនួនជាមធ្យមតែ ១,០០២ដុល្លារ ប៉ុណ្ណោះ ឬមានការថយចុះប្រហែល៣០%។ ក្រុមប្រឹក្សាឃុំសង្កាត់ ត្រូវបានលើកទឹកចិត្តអោយប្រើប្រាស់ថវិកា សមាសសភាគរដ្ឋបាលទូទៅដើម្បីរ៉ាប់រងលើចំណាយនៃការជួលបុគ្គលិក កិច្ចការរដ្ឋបាល និងកិច្ចការអភិវឌ្ឍន៍។ ការបែងចែកសមាសភាគរដ្ឋបាលទូទៅតាមប្រភេទថវិកា និងចំនួនថវិកាមធ្យមសំរាប់ឃុំសង្កាត់នីមួយៗ ដូចមាននៅក្នុង តារាងខាងក្រោម:

| តារាងលេខ ២៣: ថវិកាវិភាជន៏សំរាប់សមាសសភាគរដ្ឋបានទូទៅ | | | | | |
|---|---|---|---|---|---|
| **ប្រភេទថវិកា** | **ថវិកាវិភាជន៏សរុប** | | **%** | **ចំនួនជាមធ្យម/ឃុំ សង្កាត់** | |
| | **រៀល** | **ដុល្លារ** | | **រៀល** | **ដុល្លារ** |
| ប្រាក់ឧបត្ថម្ភសមាជិកក្រុមប្រឹក្សា | 10,482,240,000 | 2,556,644 | 32% | 6,466,527 | 1,577 |
| ប្រាក់ឧបត្ថម្ភភូមិ | 14,865,120,000 | 3,625,639 | 46% | 9,170,339 | 2,237 |
| ចំណាយរដ្ឋបាល | 7,166,640,000 | 1,747,961 | 22% | 4,421,123 | 1,078 |
| **សរុប** | **32,514,000,000** | **$7,930,244** | **100%** | **20,057,989** | **$4,892** |

**សមាសសភាគអភិវឌ្ឍន៍មូលដ្ឋាននៃមូលនិធិឃុំ សង្កាត់:** ដូចដែលបានបង្ហាញក្នុងតារាងលេខ២៣ ខាងលើ ថវិកាចំនួន៥៧ពាន់លានរៀល ត្រូវបានបែងចែកសំរាប់សមាសសភាគអភិវឌ្ឍន៍មូលដ្ឋាន ដែលជាលទ្ធផលនាំអោយថវិកាវិភាជន៍ជាមធ្យមសំរាប់ឃុំសង្កាត់នីមួយៗ មានចំនួន៨.៥៨២ដុល្លារ។ តារាងលេខ២៥ ខាងក្រោម ឆ្លុះបញ្ចាំងអំពីកំណើនរបស់ថវិកានៃសមាសសភាគអភិវឌ្ឍន៍មូលដ្ឋានពីឆ្នាំ២០០៤ ដែលពេលនោះសមាសសភាគនេះ ត្រូវបានវិភាជន៍ ដល់គ្រប់ឃុំ សង្កាត់ទូទាំងប្រទេសជាលើកដំបូង រហូតដល់ឆ្នាំ២០០៧។

| **តារាងលេខ ២៤: ថវិកាវិភាជន៍សំរាប់សមាសសភាគអភិវឌ្ឍន៍មូលដ្ឋាន ២០០៤-២០០៧** | | | | |
|---|---|---|---|---|
| **សមាសសភាគអភិវឌ្ឍន៍មូលដ្ឋាន** | **2004** | **2005** | **2006** | **2007** |
| **ឃុំ សង្កាត់** | 1,621 | 1,621 | 1,621 | 1,621 |
| **សមាសសភាគអភិវឌ្ឍន៍មូលដ្ឋាន (ដុល្លារ)** | 9,666,667 | 11,347,000 | 12,968,000 | 13,911,220 |
| **សរុបកំណើនប្រចាំឆ្នាំ** | | 17% | 14% | 7% |
| **ថវិកាវិភាជន៍ជាមធ្យម/ឃុំ សង្កាត់** | 5,963 | 7,000 | 8,000 | 8,582 |
| **កំណើនជាមធ្យមប្រចាំឆ្នាំ** | | 17% | 14% | 7% |

ដូចដែលបានឆ្លុះបញ្ចាំង ក្នុងតារាងខាងលើ ទំហំសរុបនៃសមាសសភាគអភិវឌ្ឍន៍មូលដ្ឋាន បានកើនឡើងជាលំដាប់ ដែលក្នុងនោះថវិកាឆ្នាំ២០០៧ បានកើនឡើងចំនួន១លានដុល្លារ ធៀបនឹងថវិកាឆ្នាំ២០០៦។ ថវិកាវិភាជន៍ សំរាប់មូលនិធិឃុំសង្កាត់ឆ្នាំ២០០៧ សរុបតាមខេត្តក្រុងនីមួយៗ សំរាប់សមាសសភាគទាំងពីរគឺ រដ្ឋបាលទូទៅ និងអភិវឌ្ឍន៍ មាននៅក្នុងតារាងលេខ១៩ ស្តីពីសង្ខេបថវិកាថតាមខេត្តក្រុង និងថវិកាវិភាជន៍ សំរាប់ឃុំសង្កាត់នីមួយមាននៅក្នុងឧបសម្ព័ន្ធ ៤ ស្តីពីថវិកាវិភាជន៍សំរាប់មូលនិធិឃុំ សង្កាត់ ឆ្នាំ២០០៧។

## ៨.២ ឃុំ សង្កាត់តាមតំបន់គោលដៅ

ដូចដែលបានឆ្លុះបញ្ចាំងក្នុងតារាងលេខ២៥ ខាងក្រោម មានដៃគូអ្នកផ្តល់ជំនួយចំនួន៩ ដែលបានវិភាជន៍ធនធានវិនិយោគសរុបចំនួន ៦លានដុល្លារ ដល់ឃុំសង្កាត់គោលដៅមួយចំនួន។ ការវិភាជន៍ថវិកាទាំងនោះ តំណាងអោយការផ្តល់ធនធានវិនិយោគបន្ថែមលើថវិកាវិភាជន៍ជាប្រចាំរបស់មូលនិធិឃុំសង្កាត់។ ការវិភាជន៍ធនធាន ទាំងនោះត្រូវបានបង្ហាញយ៉ាងសង្ខេប ក្នុងតារាងខាងក្រោម៖

| តារាងលេខ ២៥: ថវិកាវិភាជន៍សំរាប់ឃុំ សង្កាត់តាមតំបន់គោលដៅ | | | |
|---|---|---|---|
| **ប្រភពធនធាន** | **ឃុំ សង្កាត់** | **ថវិកា** | **ចំនួនមធ្យម/ឃុំ សង្កាត់** |
| Danida/UK-NRML | 517 | 2,000,006 | 3,868 |
| ADB-CCDP2 | 94 | 1,825,000 | 19,500 |
| IFAD/RPRP-CIDF | 148 | 942,265 | 6,367 |
| RGC/IFAD counterpart | 148 | 39,533 | 267 |
| ADB-TSSL | 37 | 617,012 | 16,676 |
| UNICEF/Seth Koma | 318 | 318,276 | 1,001 |
| USAID/PACT-LAAR | 200 | 265,000 | 1,325 |
| UNFPA | 151 | 75,500 | 500 |
| GRET-KOSAN | 2 | 60,000 | 30,000 |
| សរុប | **1,615** | **$6,142,592** | |

**គំរោងធនធានធម្មជាតិ និងជីវភាពរស់នៅ (DANIDA/UK-NRML):** នៅឆ្នាំ២០០៧ ក្រោមសមាសសភាគវិមជ្ឈការ និងវិសហមជ្ឈការ នៃគំរោងធនធានធម្មជាតិ និងជីវភាពរស់នៅ **(Danida/UK-NRML)** មានឃុំសង្កាត់សរុបចំនួន ៥១៧ ក្នុងខេត្ត-ក្រុងគោលដៅចំនួន១០ ដែលខេត្ត-ក្រុងនីមួយៗ នឹងទទួលបានថវិកាវិភាជន៍ជាមធ្យមចំនួន ៣,៨៦៨ដុល្លារ ដែលជាធនធានវិនិយោគបន្ថែម ដើម្បីគាំទ្រដល់ការសកម្មភាព ដែលទាក់ទងនឹងការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន ហើយដែលបានកំណត់ក្នុងផែនការវិនិយោគរបស់ឃុំសង្កាត់ ដែលមានថវិកាសរុបចំនួន ២លានដុល្លារ។ ចំនួនថវិកាវិភាជន៍សរុប និងចំនួនថវិកាវិភាជន៍សំរាប់ឃុំសង្កាត់ គោលដៅនីមួយៗឆ្នាំ២០០៧ មានចំនួនទ្វេដង បើធៀបនឹងថវិកាវិភាជន៍ឆ្នាំ២០០៦ ដែលស្ថិតក្រោមគំរោង CCB-NREM ។

**គំរោងកំចីឥណទាន ADB/CCDP2 របស់ធនាគារអភិវឌ្ឍន៍អាស៊ី:** រំពឹងថាគំរោង **ADB/CCDP2** ជំហានទី២ នឹង ត្រូវចុះហត្ថលេខាជាមួយនឹងក្រសួងមហាផ្ទៃ និងអនុម័តថវិកានាត្រីមាសទី១ នៃឆ្នាំ២០០៧។ ថវិកាវិភាជន៍ប្រមាណ ១,៨០លានដុល្លារ នឹងត្រូវបញ្ចូលនៅក្នុងផែនការហិរញ្ញវត្ថុសំរាប់ឆ្នាំ២០០៧ ដើម្បីរ៉ាប់រងលើចំណាយការសាងសង់សំណង់អាគារការិយាល័យរដ្ឋបាលឃុំ សង្កាត់ចំនួន៩៤ ក្នុងតំលៃ ១៩.០០០ដុល្លារ សំរាប់សំណង់អាគារការិយាល័យរដ្ឋបាល និងគ្រឿងសង្ហារឹមនៃឃុំសង្កាត់នីមួយៗ។ ការជ្រើសរើសទីតាំងឃុំ សំរាប់សំណង់អាគាររដ្ឋបាលឃុំសង្កាត់ នឹងត្រូវកំណត់ដោយនីតិវិធី និងលក្ខណៈវិនិច្ឆ័យមួយចំនួននាចុងត្រីមាសទី១ នៃឆ្នាំ ២០០៧។ ថវិកាវិភាជន៍សរុបសំរាប់ខេត្តនីមួយៗ មិនបានបញ្ចូលទៅក្នុងតារាងសង្ខេបសថវិកាវិភាជន៍តាមខេត្ត នីមួយៗទេ។

**គំរោងកំចីឥណទាន IFAD/RPRP របស់មូលនិធិអន្តរជាតិដើម្បីអភិវឌ្ឍន៍សិកម្ម:** គំរោងកំចីឥណទានកាត់បន្ថយភាពក្រីក្រតាមជនបទ IFAD/RPRP របស់មូលនិធិអន្តរជាតិដើម្បីអភិវឌ្ឍន៍សិកម្ម នៅខេត្តព្រៃវែង និងខេត្តស្វាយរៀង ដោយរួមបញ្ចូលទាំងមូលនិធិអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធឃុំ (CIDF) បានផ្តោតយកចិត្តទុកដាក់លើឃុំក្រីក្រចំនួន១៤៨ នៅក្នុងខេត្តទាំងពីរ។ ស្ថិតក្រោមមូលនិធិ (CIDF) ឃុំទាំង១៤៨ ទទួលបានថវិកាវិភាជន៍ជាមធ្យម មានចំនួន២៥.០០០ដុល្លារ សំរាប់រយៈពេលប្រាំឆ្នាំ។ ដោយផ្អែកតាមថវិកាសរុប ដែលបានវិភាជន៍

ដល់ឃុំនីមួយៗ ក្រុមប្រឹក្សាឃុំត្រូវកំណត់ចំនួនថវិកាជាក់លាក់ ដើម្បីបញ្ចូលទៅក្នុងថវិកាប្រចាំឆ្នាំរបស់ខ្លួនស្របតាមចំណាត់អាទិភាព ដែលបានកំណត់ក្នុងផែនការវិនិយោគឃុំ មានចំនួនមិនអោយលើសពី ១២.០០០ដុល្លារសំរាប់ឆ្នាំ ថវិកាណាមួយ។ ធនធាននេះនឹងត្រូវផ្ទេរតាមរយៈរតនាគារជាតិ ទៅគណនីឃុំនីមួយៗ នៅរតនាគារខេត្ត ហើយនឹង ត្រូវអនុវត្តតាមនីតិវិធីរបស់ប្រព័ន្ធមូលនិធិឃុំសង្កាត់។ ជាផ្នែកមួយនៃកិច្ចព្រមព្រៀងហិរញ្ញប្បទានតំលៃនៃចំណាយមួយផ្នែក ត្រូវរ៉ាប់រងដោយថវិកាបដិភាគរបស់រាជរដ្ឋាភិបាល។ នៅឆ្នាំ២០០៧ ឃុំគោលដៅសរុបចំនួន១៤៨ នៅក្នុងខេត្តទាំងពីរនេះបានវិភាជន៍ថវិកាសរុបចំនួន ៩៨២.០០០ដុល្លារ ដែលជាមធ្យមមានចំនួន ៦.៦០០ដុល្លារ ក្នុងមួយឃុំ ហើយពីថវិកាវិភាជន៍នេះ ឃុំនីមួយៗបានបំរុងថវិកាចំនួន ៥០០ដុល្លារ សំរាប់ការថែទាំផ្លូវជនបទ។

**គំរោងកំចីឥណទាន ADB/TSSL *របស់ធនាគារអភិវឌ្ឍន៍អាស៊ី*:** ស្ថិតក្រោមគំរោងកំចីឥណទាន **ADB/TSSL** របស់ធនាគារអភិវឌ្ឍន៍អាស៊ីមូលនិធិជីវភាពរស់នៅត្រូវបានបង្កើតឡើង ហើយថវិកាសរុបចំនួន ៦១៧.០០០ដុល្លារ ត្រូវបានបញ្ចូលទៅក្នុងផែនការហិរញ្ញវត្ថុសំរាប់ ៣៧ឃុំ នៅក្នុងតំបន់ទ្រនាប់បឹងទន្លេសាប និងមានជាមធ្យមចំនួន ១៦.៦៧៦ ដុល្លារសហរដ្ឋអាមេរិកក្នុងមួយឃុំ ហើយចំនួនថវិកាវិភាជន៍ជាក់ស្តែងនឹងត្រូវកំណត់នៅក្នុងដំណើរការកសាងផែនការ និងកិច្ចសន្យានៃឆ្នាំបន្ទាប់។

***យូនីសេហ្វ/សិទ្ធិកុមារ* (UNICEF/Seth Koma):** តាមរយៈកិច្ចសហប្រតិបត្តិរវាងអង្គការ យូនីសេហ្វជាមួយនឹង គណៈកម្មាធិការជាតិគាំទ្រឃុំសង្កាត់ (NCSC) តាំងពីឆ្នាំ២០០៤មក គណៈកម្មការទទួលបន្ទុកកិច្ចការស្ត្រីនិងកុមារ របស់ក្រុមប្រឹក្សាឃុំសង្កាត់ ត្រូវបានបង្កើតឡើងនៅគ្រប់ឃុំសង្កាត់ ដែលគាំទ្រដោយគម្រោងយូនីសេហ្វ/សិទ្ធិកុមារ។ ក្នុងឆ្នាំ២០០៧ អង្គការយូនីសេហ្វនឹងបង្កើនវិសាលភាពរបស់ខ្លួនពីចំនួន ២០៣ឃុំ សង្កាត់ទៅចំនួន ៣១៨ឃុំសង្កាត់ នៅក្នុងខេត្តគោលដៅចំនួន៦ និងបានវិភាជន៍ថវិកាសរុបចំនួន ៣១៨.២៧៦ ដុល្លារដោយជាមធ្យម ឃុំនីមួយៗនឹងទទួលបានថវិកាប្រមាណ ៩៨០ដុល្លារ។ ប្រាក់ឧបត្ថម្ភលើកទឹកចិត្តនឹងត្រូវផ្តល់ដល់ជនបង្គោលដែលទទួលបន្ទុកកិច្ចស្ត្រី និងកុមារ ទាំង៣១៧ឃុំ ដែលមិនមែនជាសមាជិកក្រុមប្រឹក្សាឃុំ និងដល់គ្រូបង្រៀនដែលត្រូវបានជួល សំរាប់សាលាមត្តេយ្យភូមិ និងចំណាយដទៃទៀតដែលពាក់ព័ន្ធនឹងសកម្មភាពរបស់គណៈកម្មការទទួលបន្ទុកកិច្ចការស្ត្រី និងកុមារ។

**គំរោង AUSAID/PACT-LAAR:** ស្ថិតក្រោមផែនការសកម្មភាព និងថវិការបស់គំរោង **LAAR** ឆ្នាំ២០០៧ ថវិកាសរុបចំនួន ២៦៥.០០០ដុល្លារ ត្រូវបានវិភាជន៍ជូនដល់ឃុំសង្កាត់ចំនួន២០០ នៅក្នុងខេត្តចំនួន៨ ក្នុងទម្រង់ជាការផ្តល់អោយដែលមានចំនួនជាមធ្យម ១.៣២៥ដុល្លារក្នុងមួយឃុំ។ ថវិកាដែលបានផ្តល់ នឹងត្រូវបានប្រើប្រាស់ ដើម្បីគាំទ្រដល់ការផ្សព្វផ្សាយពតិមាននៅមូលដ្ឋាន សកម្មភាពសេវាសង្គម និង ចំណាយទាំងឡាយណាដែលទាក់ទងនឹងការរៀបចំគំរោងអភិវឌ្ឍន៍សង្គម ដែលគេរំពឹងថានឹងចាប់ផ្តើមនៅដើម ឆ្នាំ២០០៨។

**អង្គកាយូអិនអេហ្វភីអេ UNFPA**: តាមរយៈអនុសារណៈនៃការយល់ព្រម ជាមួយនាយកដ្ឋានរដ្ឋបាលមូលដ្ឋាននៃក្រសួងមហាផ្ទៃ អង្គការយូអិនអេហ្វភីអេ (UNFA) នឹងផ្តល់ថវិកាសរុបចំនួន ៧៥.០០០ដុល្លារ ដល់ ឃុំចំនួន១៥១ នៅក្នុងខេត្តចំនួន៥ ដើម្បីគាំទ្រសកម្មភាពមួយចំនួនដែលទាក់ទងនឹងការផ្សារភ្ជាប់រវាងប្រជាសាស្ត្រ ភាពក្រីក្រ និងការអភិវឌ្ឍន៍មូលដ្ឋាន ដោយរួមបញ្ចូលសិទ្ធិស្ត្រី និងកុមារ សមភាពយេនឌ័រ និងលើកកម្ពស់ការ យល់ដឹងស្តីពីសុខភាពប្រជាសាស្ត្រ។

**អង្គកាគ្រេត GRET** : តាមបទពិសោធ៍ជាច្រើនឆ្នាំលើការងារទឹកស្អាត និងការរៀបចំបណ្តាញចែកចាយទឹកតាមជនបទ តាមរយៈភាពជាដៃគូរវាងវិស័យឯកជន និងវិស័យសាធារណៈ អង្គការGRET បានចុះហត្ថលេខាលើអនុសារណៈនៃការយល់ដឹងជាមួយនឹងគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្តកណ្តាល និងតាកែវ ដើម្បីពង្រីកការគាំទ្រសំរាប់រយៈពេល៣ឆ្នាំបន្ទាប់ទៀត។ គេរំពឹងថា នៅឆ្នាំ២០០៧ ឃុំមួយ នៅក្នុងខេត្តទនីមួយៗ នឹងត្រូវបានជ្រើសរើស សំរាប់គាំទ្រដល់ការទាក់ទងនឹងថវិកាចំនួន៣០.០០០ ដុល្លារសហរដ្ឋអាមេរិកពីអង្គការ GRET និងថវិកា ប្រមាណ២០.០០០ ដុល្លារសហរដ្ឋអាមេរិកទៀត ដែលជាថវិកាបន្ថែមពីដៃគូឯកជន និងសហគមន៍។

## សេចក្តីសង្ខេបលើការវិនិយោគឃុំ សង្កាត់

ដោយរួមបញ្ចូលគ្នានូវថវិកាវិភាជន៍ សមាសសភាគអភិវឌ្ឍន៍មូលដ្ឋានរបស់មូលនិធិឃុំសង្កាត់ និងថវិកាវិភាជន៍តាមឃុំសង្កាត់ គោលសំរាប់គំរោងជាក់លាក់មួយចំនួននោះ គឺនៅឆ្នាំ២០០៧ យើងមានថវិកាសរុបប្រមាណ ២០ លានដុល្លារ សំរាប់ការវិនិយោគឃុំសង្កាត់ និងមានចំនួនជាមធ្យម ១២.៣៧០ដុល្លារ ក្នុងមួយឃុំសង្កាត់។ ផ្អែកតាមការពិនិត្យលើថវិកាវិភាជន៍ជាក់ស្តែងសំរាប់ឆ្នាំ២០០៧ ថវិកាវិភាជន៍ទាំងពីរគឺ មូលនិធិឃុំសង្កាត់ និងថវិកាឃុំសង្កាត់ គោលដៅ ដែលតារាងលេខ២៦ ខាងក្រោម បង្ហាញពីទំហំថវិកាវិនិយោគដែលមានសំរាប់ ឃុំសង្កាត់ទូទាំងប្រទេស។ ឃុំសង្កាត់ ចំនួន១៥៨ ដែលស្មើនឹង១៦% នៃឃុំសង្កាត់ ទូទាំងប្រទេសមានធនធានវិនិយោគច្រើនជាង១៥.០០០ដុល្លារ ក្នុងមួយឃុំសង្កាត់ និងឃុំសង្កាត់ចំនួន៦៩០ ស្មើនឹង៤៣% មានធនធានវិនិយោគ រវាងពី១០.០០០ ដល់១៥.០០០ដុល្លារក្នុងមួយឃុំសង្កាត់ និងឃុំសង្កាត់ចំនួន៣៤០ ស្មើនឹង២១% មានធនធានវិនិយោគរវាងពី៨.០០០ ដល់១០.០០០ដុល្លារ ក្នុងមួយឃុំសង្កាត់ ហើយឃុំសង្កាត់ចំនួន៣០០ មានធនធានវិនិយោគតិចជាង៨.០០០ ដុល្លារសហរដ្ឋអាមេរិកក្នុងមួយឃុំ សង្កាត់។

និន្នាការកំណើននេះមានសំរាប់គំរោងអភិវឌ្ឍន៍ក្នុងប្រទេសកម្ពុជា ដើម្បីវិភាជន៍ធនធានឱ្យដល់ឃុំសង្កាត់ គោលដៅមានសភាពជាវិជ្ជមាន ទោះជាយ៉ាងណាក៏ដោយ វាក៏ត្រូវគេរំពឹងថា ការគាំទ្ររបស់រាជរដ្ឋាភិបាលទៅលើ មូលនិធិឃុំសង្កាត់ និងការវិភាជន៍ថវិកាដោយផ្អែកតាមគោលការណ៍ស្មើភាពដល់គ្រប់ឃុំ សង្កាត់នឹងនៅតែបន្ត កើនឡើង។

លើសពីនេះទៀត ការដែលឃុំសង្កាត់មួយចំនួនទទួលបានធនធានពី៣ទៅ៤ប្រភពនោះ បញ្ជាក់ពីសារៈសំខាន់នៃកិច្ចការនានាដែលនាំទៅដល់ ការធ្វើសុខដុមនីយកម្មនូវនីតិវិធីផ្សេងៗដែលពាក់ព័ន្ធ ក្នុងឆ្នាំ២០០៧ នេះដើម្បីកាត់បន្ថយភាពសាំញ៉ាំ ចំពោះឃុំ សង្កាត់ ។

| តារាងលេខ ២៦: ថវិកាវិភាជន៍សមាសសភាគអភិវឌ្ឍន៍មូលដ្ឋាន សំរាប់ឃុំ សង្កាត់ ឆ្នាំ២០០៧ | | |
|---|---|---|
| **ប្រភពធនធាន** | **ចំនួនថវិកា (ដុល្លារ)** | |
| **មូលនិធិឃុំ សង្កាត់** | $13,911,220 | |
| **ថវិកាឃុំ សង្កាត់គោលដៅ** | $6,142,592 | |
| **ថវិកាសរុប** | **$20,053,812** | |
| **ថវិកាវិភាជន៍ជាមធ្យមសរុប** | **$12,371** | |
| **ទំហំថវិកាវិភាជន៍** | **ចំនួន ឃុំ សង្កាត់** | **%** |
| > $ 20,000 | 126 | 8% |
| $ 15,000 - 19,999 | 132 | 8% |
| $ 10,000 -14,999 | 690 | 43% |
| $8,000 -9,999 | 340 | 21% |
| <$8,000 | 333 | 21% |

## ៨.៣ កម្មវិធីសាកល្បងពង្រឹងតួនាទីថ្នាក់ស្រុក ខណ្ឌ

កម្មវិធីសាកល្បងពង្រឹងតួនាទីថ្នាក់ស្រុក ខណ្ឌរបស់គ.ជ.វ.វ ឆ្នាំ២០០៧ ទទួលបានហិរញ្ញប្បទានពីគម្រោងគ្រប់គ្រងធនធាន និងជីវភាពរស់នៅ NRML ដែលមានការគាំទ្រមូលនិធិរួមគ្នាដោយ Danida និង DfID (នៅក្នុង៦៦ស្រុក ខណ្ឌនៃ១០ខេត្ត ក្រុង) ពីគម្រោងការអភិវឌ្ឍន៍បែបប្រជាធិបតេយ្យ តាមរយៈអភិបាលកិច្ចមូលដ្ឋាន ដែលគាំទ្រមូលនិធិដោយសហគមន៍អឺរ៉ុប និងកម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ EC-UNDP DDLG (នៅក្នុង៤៤ ស្រុក ខណ្ឌនៃ១០ខេត្ត ក្រុង) និងពីគម្រោងគាំទ្រការអភិវឌ្ឍន៍បែបប្រជាធិបតេយ្យតាមរយៈវិមជ្ឈការ និងវិសហមជ្ឈការ PSDD (នៅក្នុង២៨ស្រុក ខណ្ឌនៃ ១៤ខេត្ត ក្រុង)។ សរុបមានស្រុក ខណ្ឌចំនួន ១៣៨ ដែលទទួលបាននូវការគាំទ្រ ស្មើនឹង៧៥%នៃចំនួនស្រុក ខណ្ឌសរុប១៨៥ ដែលមានទូទាំងប្រទេស ។ ផ្អែកលើលទ្ធផលនៃការវាយតម្លៃនៃការអនុវត្តកម្មវិធីសាកល្បងឆ្នាំ២០០៦ និងសេចក្តីណែនាំកែសម្រួល ដែលបានរៀបចំដោយក្រសួងមហាផ្ទៃនៅពាក់កណ្តាលឆ្នាំ ២០០៦ ដោយមានការគាំទ្របច្ចេកទេសដោយPLG កម្មវិធីសាកល្បងឆ្នាំ២០០៧ នឹងបន្តធ្វើការសាកល្បងនូវយុទ្ធសាស្ត្រថ្មីនានា សម្រាប់ការរៀបចំកម្មវិធីផែ្នកសេវាកម្ម និងវិនិយោគ ដោយមានការចូលរួមនៅក្នុងស្រុក ខណ្ឌ ក្របខ័ណ្ឌគណនេយ្យភាពថ្មីៗសម្រាប់ការផ្គត់ផ្គង់សេវាកម្ម

មូលដ្ឋាន ការធ្វើសហប្រតិបត្តិការរវាងអន្តរឃុំ សង្កាត់ និងកំណត់បន្ថែម និងពង្រឹងតួនាទីអនាគតរបស់ស្រុក ខណ្ឌ នៅក្នុងចក្ខុវិស័យរួមរបស់រាជរដ្ឋាភិបាលលើកការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ។

មូលនិធិទាំងអស់ដែលទទួលបានពីគម្រោងទាំងបីខាងលើ ត្រូវបានរៀបចំកម្មវិធី ដោយអនុវត្តតាម ដំណើរការរួមមួយដែលមានចែងនៅក្នុងសេចក្តីណែនាំ និងពាក់ព័ន្ធក្នុងការពិនិត្យមើលឡើងវិញនូវសកម្មភាពជា អាទិភាពទាំងឡាយ ដែលបានកំណត់ដោយក្រុមប្រឹក្សាឃុំសង្កាត់ ភាគច្រើននៅក្នុងស្រុកខណ្ឌ ដែលនឹងផ្តល់ ផលប្រយោជន៍ដល់ប្រជាជនភាគច្រើន ការវិភាគអាទិភាពថ្នាក់ស្រុកខណ្ឌ ការកំណត់ការគម្រោងសេវាក និងគម្រោងវិនិយោគ ដែលមានអាទិភាពខ្ពស់ជាងគេ និងដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្តតាមបែបប្រជា ធិបតេយ្យដោយឃុំ សង្កាត់ នីមួយៗមានមួយសំឡេង និងស្រុកខណ្ឌមានមួយសំឡេង ដើម្បីធានាថា សំឡេងរបស់ តំណាងរដ្ឋាភិបាលមូលដ្ឋាន ដែលកើតឡើងតាមរយៈការបោះឆ្នោតគឺមានសំឡេងភាគច្រើនជានិច្ច ។

នៅក្នុងគម្រោងការអភិវឌ្ឍន៍បែបប្រជាធិបតេយ្យ ដែលគាំទ្រដោយ EC-UNDP បានផ្តោតការយកចិត្តទុកដាក់ជាសំខាន់ទៅលើការសហការរវាងអន្តរឃុំ សង្កាត់ ចំណែកឯគម្រោង NRML និងគម្រោង PSDD វិញគឺមានគោលបំណងធំទូលាយជាងដូច ដែលបានកំណត់ដោយ គ.ជ.វ.វ។ ក្នុងគម្រោងទាំងពីរនេះ មានការ វិភាជន៍មូលនិធិ ដោយអនុវត្តតាមរូបមន្តរួម ដោយបែងចែកថវិកា៥%ជា ថវិកាសម្រាប់សកម្មភាពពង្រឹង សមត្ថភាពនៅថ្នាក់ស្រុក ខណ្ឌ និង៥%ទៀត សម្រាប់ចំណាយរដ្ឋបាលទូទៅ ។ ចំណែកមូលនិធិចំនួន ៩០% នៃ មូលនិធិសរុបដែលបានបែងចែកសម្រាប់ការវិនិយោគគឺត្រូវប្រើប្រាស់យ៉ាងតិច៣០% សម្រាប់គាំទ្រគម្រោង សេវាកម្ម និងមិនឱ្យលើសពី៧០% សម្រាប់គាំទ្រគម្រោងហេដ្ឋារចនាសម្ព័ន្ធ។ លើសពីនេះទៀត ត្រូវមាន ការគោរព តាមលក្ខណៈវិនិច្ឆ័យរបស់គម្រោងគ្រប់គ្រងធនធានធម្មជាតិ និងជីវភាពរស់នៅបន្ថែមទៀត ។

សម្រាប់គម្រោង NRML និងគម្រោង PSDD មូលនិធិទាំងអស់នឹងផ្តល់ឱ្យស្រុក ខណ្ឌតាមរយៈ កិច្ចសន្យា រវាងគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត ក្រុង (គ.អ.ជ.ខ) និងគណៈកម្មាធិការអភិវឌ្ឍន៍ស្រុក ខណ្ឌ (គ.អ.ស)។ នៅក្រោម គ.អ.ស មានការបង្កើតជាគណៈអចិន្ត្រៃយ៍មួយ ដែលមានសមាជិកជាមន្ត្រីនៅ ថ្នាក់ស្រុក ខណ្ឌ និងមានភារកិច្ចទទួលខុសត្រូវក្នុងការអនុវត្តការងារប្រចាំថ្ងៃតំណាងឱ្យ គ.អ.ស។ ចំពោះការអនុវត្តគម្រោង ឬសកម្មភាពដែលគាំទ្រដោយមូលនិធិរបស់កម្មវិធីពង្រឹងតួនាទីថ្នាក់ស្រុក ខណ្ឌ នឹងត្រូវទទួល ដោយទីភ្នាក់ងារជំនាញសមស្រប និងមានសមត្ថភាពគ្រប់គ្រាន់ក្នុងការអនុវត្តគម្រោង ឬសកម្មភាពទាំងនោះ ជាមួយនឹងការផ្តល់អាទិភាពឱ្យដល់ឃុំ សង្កាត់ ការិយាល័យជំនាញថ្នាក់ស្រុក ខណ្ឌ អង្គការមិនមែន រដ្ឋាភិបាល និងអង្គការសហគមន៍មូលដ្ឋាននានា ដែលមាននៅក្នុងស្រុក ខណ្ឌ ។ នៅក្នុងករណីដែលទីភ្នាក់ងារមូលដ្ឋាន ទាំងនេះមិនមានសមត្ថភាពគ្រប់គ្រាន់ ស្រុក

ខណ្ឌអាចស្នើសុំឱ្យគ.ប្រខេត្ត ក្រុង ដើម្បីជួយកំណត់ភ្នាក់ងារអនុវត្តនៅ ថ្នាក់ខេត្ត ក្រុង ។ ចំពោះការងារសាងសង់ភាគច្រើននឹងត្រូវអនុវត្តដោយវិស័យឯកជន ។

នៅក្នុងឆ្នាំ២០០៧ ស្រុក ខណ្ឌដែលជាតំបន់គោលដៅរបស់គម្រោង NRML និងគម្រោង DDLG ទទួលបានមូលនិធិសរុបចំនួន ៣០.០០០ ដុល្លារក្នុងមួយស្រុក ខណ្ឌ ។ ចំណែកស្រុក ខណ្ឌគាំទ្រដោយគម្រោង PSDD ការវិភាជន៍ដំបូងគឺបានគ្រោងចំនួន ២៥.០០០ ដុល្លារក្នុងមួយស្រុក ខណ្ឌ ប៉ុន្តែបច្ចុប្បន្នត្រូវបានបន្ថយចំនួន៥០% មកនៅត្រឹមតែ១២.៥០០ ដុល្លារក្នុងមួយស្រុក ខណ្ឌវិញ ដោយមានការកាត់បន្ថយចំនួនមូលនិធិសរុប ។ បន្ទាប់ពីមានការពិភាក្សាជាមួយក្រសួងមហាផ្ទៃ ក្រសួងបានឯកភាពរក្សាចំនួនស្រុក ខណ្ឌ គោលដៅដែលបានគ្រោងពីដំបូងឱ្យនៅដដែល ដើម្បីធានាយន្តការ ដំណើរការ និងមុខងារទាំងឡាយអាចអនុវត្តបានពេញលេញ ទោះជាមូលនិធិសេវាកម្ម និងវិនិយោគត្រូវបានកាត់បន្ថយក៏ដោយ ។

ការវិភាជន៍ទាំងអស់ និងតំបន់គ្របដណ្តប់របស់គម្រោងទាំងបី ដែលគាំទ្រកម្មវិធីសាកល្បងពង្រឹង តួនាទីថ្នាក់ស្រុក ខណ្ឌ មានបង្ហាញនៅក្នុងតារាងទី២៧ខាងក្រោម ស្តីពីការវិភាជន៍មូលនិធិឱ្យស្រុក ខណ្ឌសម្រាប់ ឆ្នាំ២០០៧ ។

**តារាងទី២៧ : ការវិភាជន៍ឱ្យកម្មវិធីសាកល្បងពង្រឹងតួនាទីថ្នាក់ស្រុក ខណ្ឌឆ្នាំ២០០៧**

| លរ | ខេត្ត ក្រុង | ស្រុក ខណ្ឌ | Danida/UK | | EC/UNDP | | UNDP/UK/SIDA | | សរុបរួម | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | NRML | | DDLG | | PSDD | | ស្រុក ខណ្ឌ | | |
| | | ចំនួន | ចំនួន | ថវិកា | ចំនួន | ថវិកា | ចំនួន | ថវិកា | ចំនួន | % | ថវិកា |
| 01 | បន្ទាយមានជ័យ | 8 | | | | | 2 | 25,000 | 2 | 25% | **25,000** |
| 02 | បាត់ដំបង | 13 | | | | | 2 | 25,000 | 2 | 15% | **25,000** |
| 03 | កំពង់ចាម | 16 | 13 | 390,000 | 6 | 180,000 | | | 19 | 119% | **570,000** |
| 04 | កំពង់ឆ្នាំង | 8 | | | 5 | 150,000 | 2 | 25,000 | 7 | 88% | **175,000** |
| 05 | កំពង់ស្ពឺ | 8 | 7 | 210,000 | | | | | 7 | 88% | **210,000** |
| 06 | កំពង់ធំ | 8 | | | | | 2 | 25,000 | 2 | 25% | **25,000** |
| 07 | កំពត | 8 | | | | | 2 | 25,000 | 2 | 25% | **25,000** |
| 08 | កណ្តាល | 11 | | | 6 | 180,000 | 2 | 25,000 | 8 | 73% | **205,000** |
| 09 | កោះកុង | 8 | 6 | 180,000 | 3 | 90,000 | | | 9 | 113% | **270,000** |
| 10 | ក្រចេះ | 5 | 5 | 150,000 | | | | | 5 | 100% | **150,000** |
| 11 | មណ្ឌលគិរី | 5 | 5 | 150,000 | | | | | 5 | 100% | **150,000** |
| 12 | ភ្នំពេញ | 7 | | | 3 | 90,000 | 2 | 25,000 | 5 | 71% | **115,000** |
| 13 | ព្រះវិហារ | 7 | | | | | 2 | 25,000 | 2 | 29% | **25,000** |
| 14 | ព្រៃវែង | 12 | | | 6 | 180,000 | 2 | 25,000 | 8 | 67% | **205,000** |
| 15 | ពោធិសាត់ | 6 | 6 | 180,000 | | | | | 6 | 100% | **180,000** |
| 16 | រតនគិរី | 9 | 9 | 270,000 | 3 | 90,000 | | | 12 | 133% | **360,000** |
| 17 | សៀមរាប | 12 | 10 | 300,000 | | | | | 10 | 83% | **300,000** |
| 18 | ក្រុងព្រះសីហនុ | 3 | 3 | 90,000 | 3 | 90,000 | | | 6 | 100% | **180,000** |
| 19 | ស្ទឹងត្រែង | 5 | | | | | 2 | 25,000 | 2 | 40% | **25,000** |
| 20 | ស្វាយរៀង | 7 | | | 4 | 120,000 | 2 | 25,000 | 6 | 86% | **145,000** |
| 21 | តាកែវ | 10 | | | 5 | 150,000 | 2 | 25,000 | 7 | 70% | **175,000** |
| 22 | ឧត្តរមានជ័យ | 5 | | | | | 2 | 25,000 | 2 | 40% | **25,000** |
| 23 | ក្រុងកែប | 2 | 2 | 60,000 | | | | | 2 | 100% | **60,000** |
| 24 | ក្រុងប៉ៃលិន | 2 | | | | | 2 | 25,000 | 2 | 100% | **25,000** |
| **សរុបរួម** | | **185** | **66** | **$1,980,000** | **44** | **$1,320,000** | **28** | **$350,000** | **138** | **75%** | **$3,650,000** |

## ៨.៤ វិនិយោគខេត្ត ក្រុង

គោលបំណងនៃផែនការសកម្មភាព និងថវិការបស់គ.ជ.វ.វឆ្នាំ២០០៧ គឺជាការរៀបចំតារាងថវិកានានា និងការវិភាគ ចំណែកវិនិយោគថ្នាក់ខេត្ត ក្រុងជាការបញ្ចូលគ្នារវាងធនធានអភិវឌ្ឍន៍ទាំងឡាយ ដែលបាន គ្រោងតាមរយៈមូលនិធិវិនិយោគខេត្ត ក្រុង ជាមួយនឹងធនធានអភិវឌ្ឍន៍ទាំងអស់ ដែលបានរៀបចំនៅក្រោម កម្មវិធីនានានៃការធ្វើវិសហមជ្ឈការតាមវិស័យ ។ បើពិនិត្យពីទស្សនវិស័យផ្នែកគោលនយោបាយឃើញថា ចរិត នៃការផ្តល់មូលនិធិទាំងនេះ មានការខុសគ្នាជាយុទ្ធសាស្ត្រសំខាន់ៗជាច្រើនដូចជា មូលនិធិវិនយោគខេត្ត ក្រុង តំណាងឱ្យថវិកាជាជំនួយឥតសំណងមួយកញ្ចប់ដែលផ្តល់ឱ្យខេត្ត ក្រុង ហើយបន្ទាប់មកត្រូវបានវិភាជន៍ និងគ្រោង ដោយអាជ្ញាធរថ្នាក់ខេត្ត ក្រុងសម្រាប់គាំទ្រសេវាកម្ម និងការវិនិយោគជាអាទិភាពទាំងឡាយ ដែលមានទាំងនៅ ក្នុងយុទ្ធសាស្ត្រជាតិសម្រាប់ការត់បន្ថយភាពក្រីក្រ និងផែនការវិនិយោគឃុំ សង្កាត់ ។ ដូច្នេះ មូលនិធិវិនិយោគ ខេត្ត ក្រុងកំពុងធ្វើឱ្យមានការរីកចំរើនប្រសើរឡើងនូវប្រព័ន្ធគ្រប់គ្រង និងនីតិវិធីរៀបចំកម្មវិធីនានា ដែលអាច យកទៅអនុវត្តក្នុងការវិភាជន៍ថវិកាជាកញ្ចប់នាពេលអនាគត ក្នុងការគាំទ្រអាទិភាពអភិវឌ្ឍន៍ទាំងឡាយ ដែល បានកំណត់ តាមរយៈដំណើរការកសាងផែនការសមាហរណកម្ម ។ កម្មវិធីធ្វើវិសហមជ្ឈការតាមវិស័យ ពាក់ព័ន្ធ យ៉ាងជិតស្និទ្ធទៅនឹងការវិភាជន៍ថវិកាទៅឱ្យវិស័យគោលដៅ និងជាមូលដ្ឋានក្នុងការរៀបចំកម្មវិធីដែលគាំទ្រដោយ ដៃគូអភិវឌ្ឍន៍ជាក់លាក់មួយចំនួន ដែលបានចរចារជាមួយនឹងក្រសួងទាំងនោះ ។ ដូច្នេះ ធនធានទាំងអស់នេះកំពុងធ្វើ ការអភិវឌ្ឍន៍នូវប្រព័ន្ធ នីតិវិធី និងមេរៀនជាច្រើន ដែលអាចអនុវត្តនាពេលអនាគត ក្នុងការផ្តល់ថវិការបស់ ក្រសួងតាមបែបវិសហមជ្ឈការទៅឱ្យថ្នាក់ខេត្ត ក្រុង ។ ទោះបីចរិកនៃមូលនិធិទាំងពីរមានភាពខុសគ្នាក៏ដោយ ក៏មធ្យោបាយនៃការផ្តល់មូលនិធិទាំងពីរត្រូវបានធ្វើឡើងតាមរយៈការកសាងផែនការ ការផ្តល់ហិរញ្ញប្បទាន និង ការអនុវត្ត ដែលខេត្ត ក្រុងជាអ្នកទទួលខុសត្រូវ និងស្ថិតនៅក្រោមការគ្រប់គ្រងរបស់អភិបាលខេត្ត ក្រុង ដែលជា អ្នកចុះហត្ថលេខាលើកិច្ចសន្យាទាំងអស់ជាមួយនឹងមន្ទីរជំនាញថ្នាក់ខេត្ត ក្រុង និងវិស័យឯកជននានា ។ម្យ៉ាងទៀត នៅក្នុងករណីទាំងពីរខាងលើ ចំណុចសំខាន់គឺគណនេយ្យភាពខ្សែទទឹងនៅថ្នាក់ខេត្ត ក្រុងត្រូវបានពង្រឹង ។ កន្លងមក បទពិសោធន៍ដ៏សំខាន់ដែលបានបង្កើតនៅថ្នាក់ជាតិ ក្នុងការគ្រប់គ្រងយន្តការផ្តល់មូលនិធិទាំងពីរនេះ ត្រូវបានចាត់ទុកថាមានការពាក់ព័ន្ធយ៉ាងខ្លាំងទៅនឹងការរៀបចំថវិកា ដែលមានលក្ខណៈសមាហរណកម្មមួយនៅ ថ្នាក់ខេត្ត ក្រុង ដូចបានរៀបរាប់ខាងលើនៅក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលសម្រាប់កំណែទម្រង់ វិមជ្ឈការ និងវិសហមជ្ឈការ ។

ដូចមានបង្ហាញនៅក្នុងតារាងទី២៨ ខាងក្រោម នៅក្នុងឆ្នាំ២០០៧ មានថវិកាសរុបចំនួន ១១,៥ លាន ដុល្លារ ដែល បានគ្រោងសម្រាប់ការវិនិយោគនៅថ្នាក់ខេត្ត ក្រុង ដែលក្នុងនោះមានថវិកាចំនួន ៤,៧ លានដុល្លារ ត្រូវបានផ្តល់ ជាមូលនិធិវិនិយោគខេត្ត ក្រុង និង ៦,៧៨លានដុល្លារជាមូលនិធិសម្រាប់កម្មវិធីវិសហមជ្ឈការ របស់វិស័យនានា ។ ក្នុងចំនួនសរុបទាំងនេះ ជាមធ្យមខេត្ត ក្រុងនីមួយៗទទួលបានមូលនិធិចំនួន ៥០៥.០០០ ដុល្លារ ហើយក្នុង ចំណោម

ខេត្ត ក្រុងទាំងអស់មានខេត្តព្រៃវែង ដែលទទួលបានមូលនិធិខ្ពស់ជាងគេចំនួន១,៨ លាន ដុល្លារ និងខេត្តកំពង់ឆ្នាំង ទទួលបានមូលនិធិតិចជាងគេចំនួនតែ៧១.000 ដុល្លារប៉ុណ្ណោះ ។

| តារាងទី២៨ : ធនធានវិនិយោគខេត្ត ក្រុងឆ្នាំ២00៧ | | | | | | |
|---|---|---|---|---|---|---|
| ដៃគូអភិវឌ្ឍន៍ (ម្ចាស់ជំនួយ) | វិនិយោគខេត្ត ក្រុង PIF | | កម្មវិធី DSP | | សរុប | |
| | ចំនួនថវិកា | % | ចំនួនថវិកា | % | ចំនួនថវិកា | % |
| PSDD | 1,800,000 | 38% | | | 1,800,000 | 16% |
| UNICEF | 1,441,030 | 31% | | | 1,441,030 | 13% |
| EC-UNDP/EFMP | 1,022,000 | 22% | | | 1,022,000 | 9% |
| Danida-UK/NRML | 400,000 | 9% | 679,710 | 10% | 1,079,710 | 9% |
| Canada/FSIP | 41,900 | 1% | | | 41,900 | 0% |
| IFAD | | | 4,453,991 | 66% | 4,453,991 | 39% |
| Canada | | | 1,044,786 | 15% | 1,044,786 | 9% |
| រាជរដ្ឋាភិបាលកម្ពុជា | | | 602,044 | 9% | 602,044 | 5% |
| **សរុបរួម** | **$4,704,930** | **100%** | **$6,780,531** | **100%** | **$11,485,461** | **100%** |

## ៨.៤.១ មូលនិធិវិនិយោគខេត្ត ក្រុង (PIF)

ផ្អែកលើវដ្តនៃការរៀបចំថវិកា និងកម្មវិធី ភាគច្រើននៃមូលនិធិវិនិយោគខេត្ត ក្រុងឆ្នាំ២00៧ ត្រូវបានវិភាជន៍ទៅឱ្យខេត្ត ក្រុងទាំង២៤ នៅខែតុលា ឆ្នាំ២00៦។ មូលនិធិនេះរួមមាន១,៨ លានដុល្លាររបស់គម្រោង PSDD ត្រូវបានវិភាជន៍ក្នុងទម្រង់ជាកញ្ចប់ថវិកា ដែលជាជំនួយឥតសំណងទៅឱ្យ២៤ ខេត្ត ក្រុង មូលនិធិចំនួន/លានដុល្លារជាធនធានរបស់ UNICEF ត្រូវបានវិភាជន៍ឱ្យវិស័យសង្គមកិច្ចនានានៅក្នុងខេត្ត ក្រុងចំនួន៦ មូលនិធិចំនួន៨៣៥.000 ដុល្លារជាធនធានរបស់ EC/EFMP ត្រូវបានវិភាជន៍ឱ្យស្រុកចំនួន៤ ក្នុងខេត្តបាត់ដំបង មូលនិធិចំនួន៤00.000 ដុល្លាររបស់គម្រោង NRML ត្រូវបានវិភាជន៍ឱ្យវិស័យនានា ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាននៅក្នុង១0 ខេត្ត ក្រុង និងមូលនិធិចំនួន ៤២.000 ដុល្លារគាំទ្រដោយគម្រោងសន្តិសុខស្បៀងនិងអាហារូបត្ថម្ភរបស់ប្រទេសកាណាដា នៅក្នុងខេត្តតាកែវ ។ ផ្អែកលើសេចក្តីណែនាំកម្មវិធីដែលបានឯកភាព និងដំណើរការពិគ្រោះយោបល់ ដែលពាក់ព័ន្ធនឹងអន្តរកម្មរវាងអាជ្ញាធរខេត្ត ក្រុង មន្ទីរជំនាញ និងក្រុមប្រឹក្សាឃុំ សង្កាត់ តាមរយៈសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុក ខណ្ឌ មូលនិធិទាំងអស់នេះនឹងត្រូវបែងចែកឱ្យសកម្មភាពជាក់លាក់ទាំងឡាយ ដែលមានលក្ខណៈសមស្របជាមួយនឹងយុទ្ធសាស្ត្រវិស័យរបស់ជាតិ និងអាទិភាពមូលដ្ឋាននានា ។

## ៨.៤.២ កម្មវិធីវិសហមជ្ឈការវិស័យ (DSP)

មូលនិធិនៃកម្មវិធីវិសហមជ្ឈការវិស័យត្រូវបានវិនិយោគតាមរយៈកម្មវិធីរយៈពេលវែង ដែលមានការរៀបចំផែនការជាមុនដោយដៃគូអភិវឌ្ឍន៍ និងអាជ្ញាធរជាតិមួយ ដែលពាក់ព័ន្ធនឹងការកំណត់វិស័យ។ ការរៀបចំគម្រោងធនធានទាំងអស់នេះ មានការពាក់ព័ន្ធកាន់តែប្រសើរឡើងរវាងអាជ្ញាធរខេត្ត ក្រុង មន្ទីរជំនាញ និងក្រុម

ប្រឹក្សាឃុំ សង្កាត់ ក៏ដូចជាមួយសកម្មភាពវិនិយោគទាំងឡាយដែលបានប្រកាសនៅក្នុងសិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុក ខណ្ឌ។ នៅក្នុងឆ្នាំ២០០៧ មានកម្មវិធីប្រភេទនេះចំនួន៥ ដែលកំពុងអនុវត្តនៅក្នុងក្របខ័ណ្ឌផែនការសកម្មភាព និងថវិការបស់ គ.ជ.វ.វ ដែលរួមមានកម្មវិធីចំនួន៣ទទួលថវិកាកម្ចីរបស់ IFAD អនុវត្តនៅក្នុងខេត្តចំនួន៧ ដែលបញ្ចូលទាំងថវិកាបដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជា គម្រោង ADMAC គាំទ្រដោយប្រទេសកាណាដា អនុវត្តនៅក្នុងខេត្តចំនួន៣ និងគម្រោងគ្រប់គ្រង NRML ពាក់ព័ន្ធនឹងផ្នែកគ្រប់គ្រងដីធ្លីអនុវត្តនៅក្នុងខេត្តក្រុងចំនួន១០។ គម្រោងទាំងអស់នេះ មានផែនការសកម្មភាពនិងថវិកា ដែលបានរៀបចំ ផ្អែកលើ កិច្ចព្រមព្រៀងជាក់លាក់នានា ដែលបានចុះហត្ថលេខាជាមួយអាជ្ញាធរថ្នាក់ជាតិ។ ដូចមានបង្ហាញនៅ ក្នុងតារាងទី២៩ខាងលើ ថវិកាវិនិយោគសរុបចំនួន៦,៨ លានដុល្លារ បានគ្រោងនៅក្នុងឆ្នាំ២០០៧ សំរាប់២០ ខេត្ត ក្រុង ។

តារាងទី២៩ ស្តីពីការវិភាជន៍វិនិយោគខេត្ត ក្រុងតាមវិស័យ/ អនុវិស័យ ដែលមាននៅក្នុងទំព័របន្ទាប់នេះ បង្ហាញអំពីវិនិយោគខេត្ត ក្រុងដែលបានបែងចែកលំអិតតាមវិស័យ និងអនុវស័យគឺឆ្លុះបញ្ចាំងពីធនធានសរុប ដែលបានវិភាជន៍ ភាគរយ ចំនួនខេត្ត ក្រុងទទួលាករវិភាជន៍ ការវិនិយោគជាមធ្យម និងការវិភាជន៍សម្រាប់ ខេត្ត ក្រុងនីមួយៗ ដែលបែងចែកតាមវិស័យ/ អនុវិស័យ ។ ដូចបានបង្ហាញនៅក្នុងតារាងនេះ ការវិយោគទាំងអស់ សម្រាប់ការអភិវឌ្ឍន៍វិស័យកសិកម្ម មានជិតពាក់កណ្តាលនៃធនធានសរុប ហើយផ្នែកធនធានទឹក/ ធារាសាស្ត្រ និងផ្នែកអនាម័យ/ផ្គត់ផ្គង់ទឹកជនបទមានចំនួន ២០% ។ គិតជាមធ្យម វិស័យ/អនុវស័យទទួលបានការវិភាជន៍ ក្នុងខេត្តក្រុង នីមួយៗមានចំនួន ១០ ។

តារាងទី២៩នេះ ក៏បានឆ្លុះបញ្ចាំងផងដែរអំពីការវិភាជន៍ទាំងឡាយ សម្រាប់វិស័យនៅក្នុងខេត្ត ក្រុង ទាំងអស់ដែលការ វិភាជន៍នេះមានការប្រែប្រួលអាស្រ័យជាសំខាន់លើចំនួនប្រជាជនសរុបក្នុងខេត្ត ក្រុងនីមួយៗ ហើយខេត្តក្រុងដែលទទួលបានតិចជាងគេមានដូចជា ក្រុងកែប និងក្រុងប៉ៃលិនក៏ដូចជាការវិនិយោគសម្រាប់ វិស័យគោលដៅនៅក្នុងខេត្តគោលដៅ ដែលទទួលការគាំទ្រដោយគម្រោងIFAD និងគម្រោង UNICEF។ ដូចបានធ្វើការកត់សម្គាល់ខាងលើ ខេត្តដែលទទួលបានមូលនិធិវិនិយោគខេត្ត ក្រុងតិចជាងគេនៅក្នុងឆ្នាំ២០០៧ គឺខេត្តកំពង់ឆ្នាំងមានមូលនិធិចំនួន ៧១.000ដុល្លារ ប៉ុន្តែកត្តាសំខាន់ដែលខេត្តទទួលបានមូលនិធិតិចជាងគេនេះ គឺដោយការកំណត់តំបន់គោលដៅរបស់គម្រោងនីមួយៗ ជាជាងការបែងចែកធនធានឱ្យបានស្មើៗ ដោយផ្អែកលើ រូបមន្តរួមមួយ ។

| តារាងទី២៩ : ការវិភាជន៍វិនិយោគថ្នាក់ខេត្ត ក្រុងឆ្នាំ២០០៧ តាមវិស័យ/អនុវិស័យ | | | | | | | |
|---|---|---|---|---|---|---|---|
| **វិស័យ/ អនុវិស័យ** | **ថវិកាសរុប** | % | **ចំនួនខេត្ត/ក្រុង** | % | **មធ្យមក្នុងខេត្ត/ក្រុង** | **គម្លាត** | |
| | | | | | | **ពី** | **ទៅ** |
| កសិកម្ម | 5,351,167 | **47%** | 24 | **100%** | 222,965 | 6,020 | 1,472,304 |
| ទីផ្សារ និងពាណិជ្ជកម្ម | 1,500 | **0%** | 1 | **4%** | 1,500 | 1,500 | 1,500 |
| ធម្មការ និងសាសនា | 17,110 | **0%** | 5 | **21%** | 3,422 | 1,500 | 4,880 |
| អភិវឌ្ឍន៏សហគមន៏ | 97,560 | **1%** | 2 | **8%** | 48,780 | 47,200 | 50,360 |
| វប្បធម៌ | 46,371 | **0%** | 9 | **38%** | 5,152 | 1,040 | 14,400 |
| អប់រំ | 691,046 | **6%** | 16 | **67%** | 43,190 | 2,537 | 353,009 |
| បរិស្ថាន | 128,420 | **1%** | 20 | **83%** | 6,421 | 1,905 | 20,900 |
| រដ្ឋបាលព្រៃឈើ | 45,340 | **0%** | 8 | **33%** | 5,668 | 3,605 | 10,700 |
| សុខាភិបាល | 140,811 | **1%** | 12 | **50%** | 11,734 | 1,545 | 27,800 |
| ព័តិមាន（PSDD/PIF） | 28,903 | **0%** | 8 | **33%** | 3,613 | 1,591 | 5,170 |
| គ្រប់គ្រងដីធ្លី | 716,980 | **6%** | 12 | **50%** | 59,748 | 1,625 | 107,359 |
| អង្គភាពកសាងផែនការសកម្មភាពមីន | 72,754 | **1%** | 5 | **21%** | 14,551 | 6,975 | 23,731 |
| ការកសាងផែនការខេត្ត ក្រុង | 239,704 | **2%** | 24 | **100%** | 9,988 | 4,325 | 21,875 |
| ការងារសាធារណ: | 32,000 | **0%** | 2 | **8%** | 16,000 | 32,000 | 32,000 |
| ហេដ្ឋារចនាសម្ព័ន្ធ និងផ្លូវដឹកជញ្ជូនជនបទ | 598,198 | **5%** | 17 | **71%** | 35,188 | 1,083 | 327,014 |
| អនាម័យ/ទឹកជនបទ | 1,255,721 | **11%** | 12 | **50%** | 104,643 | 959 | 262,136 |
| ការងារសង្គមកិច្ច | 52,279 | **0%** | 12 | **50%** | 4,357 | 2,644 | 6,000 |
| ទេសចរណ៏ | 20,306 | **0%** | 6 | **25%** | 3,384 | 1,364 | 7,500 |
| ធនធានទឹក | 1,147,153 | **10%** | 20 | **83%** | 57,358 | 1,910 | 715,785 |
| កិច្ចការនារី | 576,975 | **5%** | 24 | **100%** | 24,041 | 4,475 | 93,770 |
| បណ្តុះបណ្តាលមុខវិជ្ជាជីវៈ/ ការងារ | 20,164 | **0%** | 6 | **25%** | 3,361 | 1,974 | 8,050 |
| អធិការកិច្ច/ ទំនាក់ទំនងសភា | 2,600 | **0%** | 1 | **4%** | 2,600 | 1,100 | 1,100 |
| **សរុបរួម** | **$11,283,061** | **100%** | | | | | |

ចំណុចគួរធ្វើការកត់សម្គាល់ជាចុងក្រោយគឺថា ធនធានទាំងអស់នេះ គ្រាន់តែជាផ្នែកមួយនៃការវិនិយោគទាំងឡាយដែលមាននៅក្នុងខេត្ត ក្រុងនីមួយៗ។ ពាក់ព័ន្ធនឹងចំណុចនេះ មានការវិភាគមួយកំពុងត្រូវបានធ្វើឡើង អំពីលទ្ធផល នៃដំណើរការសមាហរណកម្មផែនការថ្នាក់ស្រុក ខណ្ឌ ដែលនឹងផ្តល់ព័តិមានបន្ថែម និងជួយពង្រឹងក្របខ័ណ្ឌ នៃការកសាងផែនការវិនិយោគថ្នាក់ខេត្ត ក្រុង ដែលគាំទ្រដោយក្រសួងស្ថាប័ន និងដៃគូអភិវឌ្ឍន៏នានា ហើយនិងអាចជួយឱ្យក្តាប់នូវទិន្នន័យច្បាស់លាស់មួយអំពីសកម្មភាពវិនិយោគទាំងឡាយនាពេលអនាគត ។

## ៨.៥ ការគាំទ្រកម្មវិធីថ្នាក់ខេត្ត ក្រុង

### ៨.៥.១ មុខងារ និងរចនាសម្ព័ន្ធថ្នាក់ខេត្ត ក្រុង

ថវិកាគាំទ្រកម្មវិធីថ្នាក់ខេត្ត ក្រុងផ្តល់នូវធនធាននានា ដែលត្រូវការដោយរដ្ឋបាលខេត្ត ក្រុងក្នុងការ បំពេញភារកិច្ចរបស់ពួកគេនៅក្នុងកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល។ ពាក់ព័ន្ធនឹងការងារវិមជ្ឈការ អភិបាលខេត្ត ក្រុងទទួលបាននូវការធ្វើប្រតិភូកម្មភារកិច្ចពីគ.ជ.វ.វ សម្រាប់ការ គ្រប់គ្រងសេវាកម្មទាំងឡាយ ដែលគាំទ្រដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ក៏ដូចជាការគ្រប់គ្រង និងត្រួតពិនិត្យតាមដាន ក្នុងនាមរដ្ឋាភិបាល

ថ្នាក់ជាតិ។ ពាក់ព័ន្ធនឹងការងារវិសហមជ្ឈការវិញ កម្រិតនៃធនធានហិរញ្ញប្បទាន ដែលបានវិភាជន៍ឱ្យ រដ្ឋបាលខេត្តក្រុង ដោយគ.ជ.វ.វ និងកម្មវិធីរបស់រដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ផ្សេងទៀត ទាមទារនូវ ប្រព័ន្ធ និងរចនាសម្ព័ន្ធគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពមួយ ក៏ដូចជាធនធានថវិកាបន្ថែម។ ពិនិត្យមើល ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ខេត្ត ក្រុងនីមួយៗ ដែលបានអនុម័តដោយ គ.អ.ជ.ខ និងស្ថិតក្រោម ការគ្រប់គ្រង របស់អភិបាលខេត្ត ក្រុង គ.ប្រ នៃគ.អ.ជ.ខ ត្រូវបានបង្កើតឡើងនៅគ្រប់ខេត្ត ក្រុងទាំងអស់ ដើម្បីមានលទ្ធភាពក្នុងការបំពេញមុខងារប្រតិបត្តិ និងគាំទ្រនានា ដែលត្រូវការចាំបាច់សម្រាប់គ្រប់គ្រងការងារកំណែទម្រង់ប្រកបដោយប្រសិទ្ធភាព តាមរយៈការសម្របសម្រួលខ្សែទទឹង ។

មុនពេលការចាប់ផ្តើមកម្មវិធីបន្ទាប់ នៃការងារកំណែទម្រង់នៅថ្នាក់ក្រោមជាតិ និងមុនពេលដែល ច្បាប់គ្រប់គ្រងរដ្ឋបាល ខេត្តក្រុង ស្រុកខណ្ឌ ត្រូវបានអនុម័ត គ.ជ.វ.វ បានពន្យាពេលអាណត្តិរបស់គ.អ.ជ.ខ និងគណៈកម្មាធិការប្រតិបត្តិនៃគ.អ.ជ.ខ ដើម្បីធានាភាពបន្តនៃការអនុវត្តកម្មវិធីនៅក្នុងឆ្នាំ២០០៧។ ក៏ប៉ុន្តែរាជរដ្ឋាភិបាលនៅតែ បន្តកិច្ចការដ៏សំខាន់ក្នុងការរៀបចំឱ្យមានការឯកភាព និងអនុម័តច្បាប់គ្រប់គ្រងខេត្ត ក្រុង និងក្របខ័ណ្ឌ គតិយុត្តិនានាដែលនឹងធ្វើឱ្យមានលក្ខណៈស្របច្បាប់នូវប្រព័ន្ធគ្រប់គ្រងថ្នាក់ខេត្ត ក្រុង ដែលរួមបញ្ចូលនូវមុខងារ និងអំណាចទាំងអស់ផ្តល់ឱ្យខេត្ត ក្រុង នៅក្នុងការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ។ ដូច្នេះ មុខងារ និងរចនាសម្ព័ន្ធថ្នាក់ខេត្ត ក្រុងដែលមានសង្ខេបខាងក្រោមអាចជួយឱ្យការងារកំណែទម្រង់អនុវត្តទៅបាន និង កំពុងធ្វើការកសាងនូវសមត្ថភាពរយៈពេលវែងនៅគ្រប់លំដាប់ថ្នាក់ ហើយនៅក្នុងពេលជាមួយគ្នានេះដែរ ការងារ កំណែទម្រង់ ក៏កំពុងធ្វើការអភិវឌ្ឍន៍នូវបទពិសោធន៍ដ៏មានតម្លៃ និងបទមេរៀនគោលនយោបាយសម្រាប់ការ ពិនិត្យមើលឡើងវិញការធ្វើឱ្យប្រសើរឡើង និងបន្ទាប់មកបញ្ចូលទៅក្នុងលិខិតបទដ្ឋាន និងច្បាប់ទាំងឡាយ នាពេលអនាគត ។

**គណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត ក្រុង (គ.អ.ជ.ខ/គ.អ.ក)**: គណៈកម្មាធិការនេះ ស្ថិតនៅក្រោមការដឹកនាំរបស់អភិបាលខេត្ត ក្រុង និងមានសមាជិកជាប្រធានមន្ទីរជំនាញជុំវិញវិញខេត្ត ក្រុង និងអភិបាលស្រុកខណ្ឌទាំងអស់។ គ.អ.ជ.ខ/គ.អ.ក តំណាងឱ្យអភិបាលកិច្ចដ៏ចំបង និងវេទិកាអភិវឌ្ឍន៍នៅថ្នាក់ក្រោមជាតិសម្រាប់ផ្សព្វផ្សាយគោលនយោបាយ និងការសម្របសម្រួលទូទៅនៃការងារអភិវឌ្ឍន៍ និងការកសាងផែនការ ។

**គណៈកម្មាធិការប្រតិបត្តិនៃ គ.អ.ជ.ខ (គ.ប្រ)**: គណៈកម្មាធិការនេះស្ថិតនៅក្រោមការគ្រប់គ្រងរបស់អភិបាលខេត្ត ក្រុង និងមានសមាជិកពី ៦ ទៅ ៨នាក់ ដែលជាប្រធានមន្ទីរសំខាន់មួយចំនួន ។ គ.ប្រ មានភារកិច្ចទទួលខុសត្រូវក្នុងការសម្របសម្រួលការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ ដែលបានអនុលោមភាពដោយគ.អ.ជ.ខ និងអនុម័តដោយគ.ជ.វ.វ អាជ្ញាធរថ្នាក់ជាតិនានា និង/ឬក៏ដៃគូអភិវឌ្ឍន៍នានា ក៏ដូចជាលិខិតបទដ្ឋានទាំងឡាយដែលបានអនុម័តដោយគ.ជ.វ.វ នៅក្នុងការគាំទ្រដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

**អង្គភាពរដ្ឋបាលមូលដ្ឋាន** (LAU)៖ អង្គភាពនេះដូចជាការិយាល័យនៅក្នុងសាលាខេត្ត ក្រុង ហើយមានតួនាទីសំខាន់ក្នុងការផ្តល់សេវាកម្មនៃការកសាងសមត្ថភាព និងការសម្របសម្រួលដល់ក្រុមប្រឹក្សាឃុំ សង្កាត់ តាមរយៈជាពិសេស ក្រុមសម្របសម្រួលស្រុក ខណ្ឌ និងខេត្ត ក្រុងដែលបានបណ្តុះបណ្តាល និងទទួលខុសត្រូវក្នុងការត្រួតពិនិត្យ វាយតម្លៃ និងប្រព័ន្ធធ្វើរបាយការណ៍។ លើសពីនេះទៀត អង្គភាព រដ្ឋបាលមូលដ្ឋាន មានភារកិច្ចផ្តល់នូវសេវាកម្មជាក់លាក់សម្រាប់គម្រោងមួយចំនួន ដែលពាក់ព័ន្ធនឹងការបញ្ជ្រាប ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាននៅថ្នាក់មូលដ្ឋាន（NRML និងTSSL）ការបញ្ជ្រាបបញ្ហាអភិវឌ្ឍន៍សង្គម（UNICEF និង UNFPA）ការពង្រឹងកិច្ចសហប្រតិបត្តិការរវាងឃុំ សង្កាត់ និងឃុំសង្កាត់（EC/DDLG）និងការពង្រឹងតួនាទីថ្នាក់ស្រុក ខណ្ឌនៃកម្មវិធីសាកល្បងស្រុក ខណ្ឌ（PSDD និងNRML）។

**ផ្នែកគ្រប់គ្រងកិច្ចសន្យា** (CAU)៖ ផ្នែកនេះស្ថិតនៅក្រោមការគ្រប់គ្រងដោយផ្ទាល់របស់មន្ទីរផែនការ ខេត្ត ក្រុង ហើយទទួលខុសត្រូវក្នុងការគ្រប់គ្រងកិច្ចសន្យាទាំងអស់ ដែលបានចុះហត្ថលេខាដោយអភិបាលខេត្ត ក្រុង ដែលជា ប្រធាន គ.ប្រ និងធ្វើការត្រួតពិនិត្យ វាយតម្លៃ និងប្រព័ន្ធរៀបចំរបាយការណ៍នៅថ្នាក់ខេត្ត ក្រុង ដែលពាក់ព័ន្ធ នឹងកិច្ចសន្យារបស់មន្ទីរជំនាញទាំងអស់ ។

**ផ្នែកគ្រប់គ្រងហិរញ្ញវត្ថុ**(FU)៖ ផ្នែកនេះស្ថិតនៅក្រោមការគ្រប់គ្រងដោយផ្ទាល់របស់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត ក្រុង ហើយផ្នែកនេះបែងចែកបន្តជាពីរផ្នែកទៀតគឺ ផ្នែករតនាគារខេត្ត ក្រុងដែលទទួលខុសត្រូវ ក្នុងការទទួល ទូទាត់ កត់ត្រាគណនេយ្យ និងធ្វើរបាយការណ៍ មូលនិធិឃុំសង្កាត់ ដោយសហការជាមួយ ក្រុមប្រឹក្សាឃុំ សង្កាត់។ ផ្នែកទីពីរគឺផ្នែកហិរញ្ញវត្ថុខេត្ត ក្រុង ដែលមានតួនាទីក្នុងការទទួល ទូទាត់ កត់ត្រាគណនេយ្យ និងធ្វើរបាយការណ៍ លើធនធានហិរញ្ញវត្ថុទាំងឡាយ ដែលបានផ្ទេរទៅក្នុងគណនីរបស់ខេត្ត ក្រុង ផ្អែកតាមផែនការសកម្មភាព និងថវិកាដែលបានអនុម័ត និងកិច្ចសន្យាដែលត្រូវអនុវត្ត ។

**ផ្នែកគាំទ្របច្ចេកទេស**(TSU)៖ ផ្នែកនេះស្ថិតនៅក្រោមការគ្រប់គ្រងដោយផ្ទាល់របស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត ក្រុង ហើយមានភារកិច្ចសំខាន់ក្នុងការផ្តល់សេវាកម្មបច្ចេកទេសឱ្យដល់ក្រុមប្រឹក្សាឃុំ សង្កាត់លើ ការងាររៀបចំគម្រោងប្លង់បច្ចេកទេសរបស់គម្រោង ការសិក្សាលទ្ធភាពគម្រោង និងការរៀបចំកិច្ចសន្យា ត្រួតពិនិត្យការអនុវត្តការងាររបស់អ្នកទទួលការ អនុវត្តការធ្វើសវនកម្មបច្ចេកទេសលើគម្រោងឃុំសង្កាត់ ដែលបានជ្រើសរើស មួយចំនួន និងផ្តល់ការគាំទ្របច្ចេកទេសលើគម្រោងហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានផ្សេងទៀត ដែលគាំទ្រមូលនិធិ វិនិយោគខេត្ត ក្រុង និងមូលនិធិនៃកម្មវិធីពង្រឹងតួនាទីស្រុក ខណ្ឌ ។

### ៨.៥.៣ ថវិកាគាំទ្រកម្មវិធីខេត្ត ក្រុង និងការវិភាជន៍

នៅក្នុងឆ្នាំ២០០៧ ថវិកាសរុបចំនួន ៤,៣៦លានដុល្លារ ត្រូវបានវិភាជន៍សម្រាប់ការគាំទ្រកម្មវិធីថ្នាក់ខេត្តក្រុង ដែលក្នុងនោះរួមមានថវិកាចំនួន ៣,៩លានដុល្លារ សម្រាប់គាំទ្រសេវាកម្ម និងមុខងារគ្រប់គ្រងនានា ដែលអនុវត្ត ដោយគណៈកម្មាធិការប្រតិបត្តិ ដែលដឹកនាំដោយអភិបាលខេត្តក្រុង ដូចដែលបានរៀបរាប់ខាងលើ និង ថវិកាចំនួន ៤៦០.០០០ដុល្លារ សម្រាប់គាំទ្រកិច្ចប្រតិបត្តិការនានារបស់ក្រុមទីប្រឹក្សាគម្រោង PSDDនៅក្នុង២៤ ខេត្តក្រុង ។

ថវិកាចំនួន ៣,៩ លានដុល្លារសម្រាប់សេវាកម្មថ្នាក់ខេត្ត ក្រុង និងការគ្រប់គ្រងនានា ដែលបានបែងចែក ទៅឱ្យខេត្ត ក្រុងទាំង ២៤ តាមរយៈរូបមន្ត និងថ្លៃរដ្ឋបាលស្តង់ដារ ។ ផ្នែកសំខាន់ៗនៅក្នុងការចំណាយរួមមាន ប្រាក់លើកទឹកចិត្តក្នុងការអនុវត្តការងារ សម្រាប់បុគ្គលិករបស់គ.ប្រ ដែលធ្វើការពេញម៉ោង តាមរយៈកិច្ចសន្យា ប្រចាំឆ្នាំរបស់បុគ្គលម្នាក់ៗ និងផែនការសកម្មភាពរបស់ពួកគេ ចំណាយសម្រាប់វគ្គបណ្តុះបណ្តាលផ្តល់ឱ្យក្រុម ប្រឹក្សាឃុំ សង្កាត់ មន្ត្រីថ្នាក់ស្រុក ខណ្ឌ ឧបករណ៍ដឹកជញ្ជូន និងការិយាល័យ សម្ភារៈផ្គត់ផ្គង់ការិយាល័យ និងចំណាយប្រតិបត្តិការ និងការថែរក្សា។ ជាមធ្យម ខេត្ត ក្រុងនីមួយៗទទួលបានថវិកាប្រភេទនេះចំនួន ១៦០.០០០ ដុល្លារ ឬស្មើនឹង៧% នៃធនធានសរុប ដែលបានផ្ទេរទៅឱ្យថ្នាក់ក្រោមជាតិ។ ថវិកាប្រតិបត្តិការ សម្រាប់គម្រោង PSDD មានចំនួន៤៦០.០០០ ដុល្លារ ដែលគ្រប់គ្រងផ្ទាល់ដោយរដ្ឋបាលខេត្តក្រុង។ ចំពោះថវិកា សម្រាប់ឧបករណ៍/សម្ភារៈការិយាល័យ និងការធ្វើដំណើរ និងចំណាយរដ្ឋបាលសម្រាប់ទីប្រឹក្សាថ្នាក់ខេត្ត ក្រុង ជាមធ្យម ខេត្ត ក្រុងចំនួន១៣៩ នាក់ ខេត្ត ក្រុងនីមួយៗទទួលបានចំនួន ១៩.៥០០ ដុល្លារ ។

តារាងទី៣០ ស្តីពីការផ្តល់ហិរញ្ញប្បទានសម្រាប់គាំទ្រកម្មវិធីថ្នាក់ខេត្ត ក្រុងឆ្នាំ២០០៧ ដែលមានរៀបរាប់ នៅក្នុងទំព័រខាងក្រោមនេះ ឆ្លុះបញ្ចាំងអំពីប្រភពនៃការផ្តល់ហិរញ្ញប្បទាននានា សម្រាប់ការគាំទ្រកម្មវិធីថ្នាក់ ខេត្ត ក្រុងឆ្នាំ២០០៧។ ដូចដែលបានបង្ហាញនៅក្នុងតារាងនេះ ធនធានរបស់គាំទ្រដោយគម្រោង PSDD មានចំនួន ៦៩%នៃធនធានសរុប ចំណែកធនធានរបស់IFAD និងUNICEF និងEC រួមបញ្ចូលគ្នាមានចំនួន ១៨%។ បដិភាគរបស់រាជរដ្ឋាភិបាល ដែលមាននៅក្នុងតារាង ចាត់ទុកជាមូលនិធិដៃគូមានតែនៅក្នុងគម្រោងគាំទ្រដោយ IFAD និងមិនរួមបញ្ចូលនៅក្នុងការគាទ្រនៅក្នុងផ្នែកដទៃទៀតឡើយដូចជា ប្រាក់បៀវត្សន៍របស់មន្ត្រីរាជការ និងចំណាយសម្រាប់ការិយាល័យធ្វើការជាដើម ។

| តារាងទី៣០ : ការផ្តល់ហិរញ្ញប្បទានគាំទ្រកម្មវិធីថ្នាក់ខេត្ត ក្រុង | | |
|---|---|---|
| **ដៃគូអភិវឌ្ឍន៍ (ម្ចាស់ជំនួយ)** | **ចំនួនថវិកា** | **%** |
| **RGC** | **38,353** | **1%** |
| **PLG** | **3,336,434** | **69%** |
| IFAD/CBRD | 212,981 | 4% |
| IFAD/RPRP | 93,185 | 2% |
| IFAD/RULIP | 4,500 | 0% |
| **សរុប IFAD** | **310,666** | **6%** |
| **UNICEF** | **295,560** | **6%** |
| **Germany** | **250,000** | **5%** |
| **EC-UNDP/DDLG** | 193,581 | 4% |
| **EC-UNDP/EFMP** | 55,650 | 1% |
| **សរុប EC-UNDP** | **249,231** | **5%** |
| **WB/RILG** | **150,000** | **3%** |
| **ADB/TSSL** | **110,000** | **2%** |
| **CANADA** | **27,474** | **1%** |
| **UNFPA** | **25,841** | **1%** |
| **GRET** | **9,000** | **0%** |
| **សរុបរួម** | **$4,802,559** | **100%** |

ធនធានទាំងអស់របស់គម្រោង PSDD ត្រូវបានគ្រោងដោយ គ.ជ.វ.វ សម្រាប់ខេត្ត ក្រុងទាំង២៤ ដោយផ្អែកលើរូបមន្ត ចំនួនបុគ្គលិក និងថ្លៃឯកតាជាស្តង់ដារ ចំណែកឯមូលនិធិ ដែលបានមកពី IFAD, UNICEF និង EC/UNDP មានមួយភាគតូចបានជួយគាំទ្រដល់ថ្លៃគាំទ្រកម្មវិធីដែលស្ថិតនៅក្នុងតំបន់គោលដៅរបស់គេ ។ ចំពោះមូលនិធិចូលរួម ដែលបានមកពីដៃគូអភិវឌ្ឍន៍ផ្សេងទៀតគឺបានបន្ថែមទៅលើចំណាយស្នូល និងជាពិសេសសម្រាប់គាំទ្រសកម្មភាពទាំងឡាយ ដែលមានលក្ខណៈសមស្របទៅនឹងគោលបំណងនានារបស់គម្រោងគេ ។ តារាងទី៣១ ខាងក្រោមបង្ហាញពីថវិកាសរុប ដែលបានបែងចែកតាមផ្នែករបស់គ.ប្រ នៅក្នុងឆ្នាំ២០០៧ ហើយចំនួនថវិកានេះភាគច្រើនដូចគ្នាទៅនឹងថវិកាឆ្នាំ២០០៦ ។ ដូចបានធ្វើកំណត់សម្គាល់នៅក្នុងតារាងនេះ មានថវិកាសរុបចំនួន៦២៥.០០០ ដុល្លារសម្រាប់គាំទ្រកម្មវិធីថ្នាក់ខេត្ត ក្រុង ដែលមួយចំនួនអាចស្ថិតនៅក្រៅការគ្រប់គ្រងរបស់គ.ប្រ (៥១០.០០០ ដុល្លារសម្រាប់អង្គភាពគាំទ្រកម្មវិធី និងការទូទាត់ផ្ទាល់) ឬក៏ជាថវិកាតំណាងឱ្យមូលនិធិសម្រាប់គ.ប្រ ប្រើប្រាស់ប៉ុន្តែមិនទាន់បានគ្រោងសម្រាប់ចំណាយនៅឡើយ (១១៥.០០០ ដុល្លារ) ។

| តារាងទី៣១ : ថវិកាតាមផ្នែករបស់គ.ប្រ ឆ្នាំ២០០៧ | | |
|---|---|---|
| **ផ្នែកគ.ប្រ** | **2007** | |
| | **ចំនួនថវិកា** | **%** |
| អង្គភាពរដ្ឋបាលមូលដ្ឋាន | 1,725,052 | 36% |
| ផ្នែកគ្រប់គ្រងកិច្ចសន្យា និងរដ្ឋបាល | 1,186,603 | 25% |
| ផ្នែកហិរញ្ញវត្ថុ | 387,165 | 8% |
| ផ្នែកគាំទ្របច្ចេកទេស | 413,911 | 9% |
| ប្រតិបត្តិការគម្រោង PSDD | 463,103 | 10% |
| **សរុប** | **$4,175,836** | **100%** |
| ថវិកាគាំទ្រកម្មវិធី/និងមិនទាន់គ្រោងចំណាយ | $626,724 | 13% |
| **សរុបទាំងអស់** | **$4,802,559** | **100%** |

តារាងទី៣២ ខាងក្រោមជាតារាងស្ដីពីការវិភាគ និងបុគ្គលិករបស់គ.ប្រ ឆ្នាំ២០០៧ ឆ្លុះបញ្ចាំងពីបុគ្គលិក សរុបរបស់គ.ប្រ នៅក្នុងខេត្តក្រុងទាំង២៤ និងផ្ដល់នូវសូចនាករបន្ទុកការងារមួយចំនួនរបស់បុគ្គលិកទាំងនោះ តាមផ្នែកនីមួយៗ ។ ព័ត៌មានបន្ថែមស្ដីពីបុគ្គលិកតាមផ្នែកមានរៀបរាប់ខាងក្រោម :

| តារាងទី៣២ : បុគ្គលិកគ.ប្រឆ្នាំ២០០៧ និងការវិភាគ | | | |
|---|---|---|---|
| **ផ្នែកគ.ប្រ** | **មកពីមន្ទីរ/អង្គភាព** | **ចំនួនបុគ្គលិក** | **សូចនាករបន្ទុកការងារ** |
| រដ្ឋបាលមូលដ្ឋាន | សាលាខេត្ត ក្រុង | 1,012 | បុគ្គលិកការិយាល័យ៣នាក់/ខេត្ត ក្រុង : អ្នកសម្របសម្រួល០១នាក់ទទួល២ ឃុំ សង្កាត់ |
| គ្រប់គ្រងកិច្ចសន្យា និងរដ្ឋបាល | មន្ទីរផែនការ | 205 | បុគ្គលិកគ្រប់គ្រងកិច្ចសន្យា០១នាក់ទទួលកិច្ចសន្យាថ្នាក់ខេត្ត ក្រុចំនួន៣ និងថវិកាចំនួន ៩១.០០០ ដុល្លារ |
| ហិរញ្ញវត្ថុ | មន្ទីរហិរញ្ញវត្ថុ/ រតនាគារ | 273 | បុគ្គលិកហិរញ្ញវត្ថុ០១ នាក់ទទួលថវិកាចំនួន ១៩០.០០០ ដុល្លារ |
| គាំទ្របច្ចេកទេស | មន្ទីរអភិវឌ្ឍន៍ជនបទ | 251 | បុគ្គលិកគាំទ្របច្ចេកទេស០១នាក់ទទួលកិច្ចសន្យាឃុំ សង្កាត់ចំនួន១២ និងថវិកាចំនួន ៨១.០០០ ដុល្លារ |
| សមាជិកអចិន្ត្រៃយ៍ | | 24 | ជាមធ្យមថវិកាចំនួន ១,៩ លានដុល្លារ និងបុគ្គលិក៧៤ នាក់ក្នុងខេត្ត ក្រុងនីមួយៗ |
| សវនករផ្ទៃក្នុង | | 24 | ជាមធ្យមថវិកាចំនួន ១,៩ លានដុល្លារ និងកិច្ចសន្យាចំនួន ១៨០ ក្នុងខេត្ត ក្រុងនីមួយៗ |
| **សរុប** | | **1,789** | |

**អង្គភាពរដ្ឋបាលមូលដ្ឋាន:** នៅក្នុងឆ្នាំ២០០៤ អង្គភាពរដ្ឋបាលមូលដ្ឋានបានបង្កើតឡើងជាផ្លូវការ ជាអង្គភាពទី៥ នៅក្នុង សាលាខេត្ត ក្រុង មានអាណត្តិស្ថិតនៅក្រោមការគ្រប់គ្រងរបស់អភិបាលខេត្ត ក្រុង និងមានភារកិច្ចក្នុងការផ្ដល់ការអភិវឌ្ឍន៍សមត្ថភាព ការសម្របសម្រួល ការត្រួតពិនិត្យ និងការធ្វើរបាយការណ៍សម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់ទាំង ១.៦២១ ។ នៅក្នុងឆ្នាំ២០០៧ បុគ្គលិករបស់អង្គភាពរដ្ឋបាលមូលដ្ឋាននៅក្នុងខេត្ត ក្រុងទាំង២៤ មានចំនួន ១.០១២ នាក់ គឺជាមធ្យមមានបុគ្គលិកចំនួន ៤២ នាក់ក្នុងខេត្ត ក្រុងនីមួយៗ ។ នៅក្នុងចំនួនសរុបនេះ មានបុគ្គលិកចំនួន ៨៦ នាក់ធ្វើការនៅសាលាខេត្ត ក្រុង (ជាមធ្យម ៣-៤នាក់ក្នុងខេត្ត ក្រុងនីមួយៗ) បុគ្គលិកចំនួន២៣៨ នាក់ជាមន្ត្រីសម្របសម្រួលថ្នាក់ខេត្ត ក្រុង (ជាមធ្យម ១០ នាក់ក្នុងខេត្ត ក្រុងនីមួយៗ) ដែលគាំទ្រ

ដល់ថ្នាក់ស្រុក ខណ្ឌ សម្របសម្រួលសកម្មភាពបណ្តុះបណ្តាល និងនៅក្នុងពាក់កណ្តាលនៃចំនួនខេត្ត ក្រុងសរុប មន្ត្រីសម្របសម្រួលទាំងនេះមានភារកិច្ចគាំទ្រការបញ្ជ្រាបការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន និងបញ្ហាស្ត្រី និងកុមារ និងមានបុគ្គលិកចំនួន៦៨៨ នាក់បំរើការជាមន្ត្រីសម្របសម្រួលស្រុក ខណ្ឌ (ជាមធ្យម២៨ នាក់ក្នុង ខេត្ត ក្រុងនីមួយៗ) ដែលធ្វើការសម្របសម្រួលដោយផ្ទាល់ជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ រៀបចំវគ្គបណ្តុះបណ្តាលនានា និងនៅក្នុងពាក់កណ្តាលនៃចំនួនខេត្ត ក្រុងសរុបនៃមន្ត្រីទាំងនេះ មានភារកិច្ចគាំទ្រការបញ្ជ្រាបការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន និងបញ្ហាស្ត្រី និងកុមារ ។ ជាមធ្យម មន្ត្រីសម្របសម្រួលស្រុក ខណ្ឌមួយនាក់គាំទ្រក្រុមប្រឹក្សាឃុំ សង្កាត់ចំនួន ២ឃុំ សង្កាត់ មន្ត្រីសម្របសម្រួលខេត្ត ក្រុងមួយនាក់គាំទ្រមន្ត្រីសម្របសម្រួលស្រុក ខណ្ឌចំនួន ៣ នាក់ និងមន្ត្រីអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត ក្រុងចំនួន ៣ នាក់រួមទាំងប្រធានអង្គភាព ជាមន្ត្រីធ្វើការនៅក្នុងសាលាខេត្ត ក្រុង ។ នៅក្នុងឆ្នាំ២០០៧ បុគ្គលិកអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត ក្រុងមានការកើនឡើងចំនួន ៧០ នាក់ បើប្រៀបធៀបនឹងឆ្នាំ២០០៦ ។ មូលហេតុសំខាន់នៃការកើនឡើងនេះ ដោយសារមានការកើនឡើងនូវចំនួនដៃគូអភិវឌ្ឍន៍ និងធនធានដែលបានផ្តល់ឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ ។ ពិនិត្យជារួម ពាក់កណ្តាលនៃចំនួនបុគ្គលិកសរុបរបស់អង្គភាពរដ្ឋបាលមូលដ្ឋានជា មន្ត្រីរាជការស៊ីវិលក្របខ័ណ្ឌក្រសួងមហាផ្ទៃ និងមន្ត្រីផ្សេងទៀតមកពីមន្ទីរជំនាញជុំវិញខេត្ត ក្រុង ។ ក្នុងចំណោមមន្ត្រីអង្គភាពរដ្ឋបាលមូលដ្ឋានទាំងអស់មាន ១៥% ជាស្ត្រី ។

**ផ្នែកគ្រប់គ្រងកិច្ចសន្យា និងរដ្ឋបាល:** ក្នុងផ្នែកនេះមានបុគ្គលិកសរុបទាំងអស់ចំនួន ២០៥នាក់ គឺមានការកើនឡើង ចំនួន ២០ នាក់ បើប្រៀបធៀបទៅនឹងឆ្នាំ២០០៦ ហើយជាមធ្យមមានបុគ្គលិកចំនួន៨ នាក់ក្នុងខេត្ត ក្រុងនីមួយៗ។ ក្នុងចំនួនបុគ្គលិកសរុបរបស់ផ្នែកនេះ មានបុគ្គលិកចំនួន ១២៦ នាក់ទទួលខុសត្រូវលើការងារគ្រប់គ្រងកិច្ចសន្យា និងរដ្ឋបាល (ជាមធ្យម ៥ នាក់ក្នុងខេត្ត ក្រុងនីមួយៗ) និងបុគ្គលិកចំនួន ៧៩នាក់ទទួលខុសត្រូវលើការងារត្រួតពិនិត្យ និងវាយតំលៃកម្មវិធី (ជាមធ្យម៣ នាក់ក្នុងខេត្ត ក្រុងនីមួយៗ)។ ផ្នែកគ្រប់គ្រងកិច្ចសន្យា និងរដ្ឋបាលស្ថិតនៅ ក្រោមការគ្រប់គ្រងរបស់អភិបាលខេត្ត ក្រុង និងមានភារកិច្ចសំខាន់ក្នុងការគ្រប់គ្រងកិច្ចសន្យាថ្នាក់ខេត្ត ក្រុង ត្រួតពិនិត្យ វាយតំលៃ និងរៀបចំរបាយការណ៏អំពីការរីកចំរើននៃការអនុវត្តកិច្ចសន្យា និងកម្មវិធី និងផ្តល់សេវាកម្មរដ្ឋបាលនានាសម្រាប់គ.ប ។ ជាមធ្យមបុគ្គលិកផ្នែកគ្រប់គ្រងកិច្ចសន្យា និងរដ្ឋបាលមួយនាក់ទទួលខុសត្រូវលើកិច្ចសន្យាថ្នាក់ខេត្ត ក្រុងចំនួន ៣ កិច្ចសន្យា និងថវិកាវិភាជន៍របស់ខេត្ត ក្រុងចំនួន ៩១.០០០ ដុល្លារ ។ បុគ្គលិកបំរើការងារក្នុងផ្នែកនេះប្រហែល ៦០% មកពីក្របខ័ណ្ឌក្រសួងផែនការ និងមួយចំនួនទៀតមកពីមន្ទីរជំនាញជុំវិញខេត្ត ក្រុងផ្សេងទៀត ។ ក្នុងចំនួនបុគ្គលិកសរុបរបស់ផ្នែកនេះមានស្ត្រីចំនួន ២៥% ។

**ផ្នែកហិរញ្ញវត្ថុ:** នៅក្នុងខេត្ត ក្រុងទាំង២៤ បុគ្គលិកបំរើការងារក្នុងផ្នែកហិរញ្ញវត្ថុមានចំនួន២៧៣ នាក់ គឺមានការកើនឡើងចំនួន៨ នាក់បើប្រៀបធៀបនឹងឆ្នាំ២០០៦។ ផ្នែកហិរញ្ញវត្ថុមានភារកិច្ចសំខាន់ពីរគឺ ១) ទទួលខុសត្រូវសេវាកម្មគ្រប់គ្រងហិរញ្ញវត្ថុ និងការកសាងសមត្ថភាពសម្រាប់គ្រប់គ្រងធនធានទាំងឡាយ ដែលបានផ្ទេរ ទៅឱ្យខេត្ត

ក្រុងក្នុងគណនីដែលបានបើកនៅក្នុងធនាគារពាណិជ្ជកម្ម ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់អភិបាល ខេត្ត ក្រុង និងសម្រាប់ការវិនិយោគខេត្ត ក្រុង និងគាំទ្រកម្មវិធី។ ចំណែកភារកិច្ចទី ២) របស់ផ្នែកហិរញ្ញវត្ថុគឺ ការធ្វើគណនេយ្យ ការអនុម័តការទូទាត់ ការកសាងសមត្ថភាព និងាករធ្វើរបាយការណ៍សម្រាប់ធនធានមូលនិធិឃុំ សង្កាត់ ដែលបានផ្ទេរទៅក្នុងគណនីឃុំ សង្កាត់តាមរយៈរតនាគារជាតិ ។ ក្នុងចំនួនបុគ្គលិកសរុបរបស់ផ្នែកនេះមាន បុគ្គលិកចំនួន១០៥ នាក់ទទួលខុសត្រូវគ្រប់គ្រងហិរញ្ញវត្ថុនៃថវិកា ដែលបានវិភាជន៍ឱ្យខេត្តក្រុង និងបុគ្គលិកចំនួន ១៦៨នាក់ បំរើការងារនៅក្នុងរតនាគារខេត្ត ក្រុងដែលពាក់ព័ន្ធនឹងគណនី និងធនធានទាំងឡាយរបស់ឃុំ សង្កាត់។ ជារួម ៩០% នៃ បុគ្គលិកផ្នែកហិរញ្ញវត្ថុមានក្របខ័ណ្ឌក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយក្នុងនោះមាន បុគ្គលិក២៨% ជាស្ត្រី។ នៅក្នុងឆ្នាំ ២០០៧ ជាមធ្យមបុគ្គលិកផ្នែកហិរញ្ញវត្ថុម្នាក់ទទួលគ្រប់គ្រងមូលនិធិចំនួន ១៩០.០០០ដុល្លារ ដែលក្នុងនោះ ១៤៥.០០០ ដុល្លារជាមូលនិធិឃុំ សង្កាត់ដែលទទួលខុសត្រូវដោយគណនេយ្យករឃុំ សង្កាត់ម្នាក់ៗ និង គណនេយ្យករ ដែលជាបុគ្គលិកមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ម្នាក់ៗទទួលខុសត្រូវថវិកាចំនួន២៦៥.០០០ ដុល្លារ ។

**ផ្នែកគាំទ្របច្ចេកទេស:** ផ្នែកនេះមានបុគ្គលិកសរុបទូទាំងប្រទេសចំនួន ២៥៨ នាក់ក្នុងឆ្នាំ ២០០៦ និងដូច គ្នានៅក្នុងឆ្នាំ២០០៥។ ភារកិច្ចសំខាន់របស់ផ្នែកនេះគឺ ផ្តល់សេវាកម្មបច្ចេកទេសដល់ក្រុមប្រឹក្សាឃុំសង្កាត់ លើការ រៀបចំគម្រោងការបច្ចេកទេសរបស់គម្រោង ការងារលទ្ធកម្ម ការអនុវត្ត ការពិនិត្យបញ្ជាក់ និងការថែរក្សា ការកសាងសមត្ថភាព ការត្រួតពិនិត្យ និងការរៀបចំរបាយការណ៍ស្តីពី កិច្ចសន្យាវិនិយោគឃុំ សង្កាត់។ ជាមធ្យម មន្ត្រី គាំទ្របច្ចេកទេសម្នាក់ទទួលគាំទ្រកិច្ចសន្យាគម្រោងឃុំ សង្កាត់ចំនួន១២ កិច្ចសន្យា ដែលមានតម្លៃជាទឹកប្រាក់ ចំនួន ៨១.០០០ដុល្លារ។ ពិនិត្យជារួម ៧០%នៃមន្ត្រីគាំទ្របច្ចេកទេសសរុបមានក្របខ័ណ្ឌក្រសួងអភិវឌ្ឍន៍ជនបទ និងមានស្ត្រីតែ ៦% ប៉ុណ្ណោះនៃចំនួនសរុប ដោយសារនៅក្នុងប្រទេសកម្ពុជាមិនសូវមានវិស្វករជាស្ត្រី ។

**សមាជិកអចិន្ត្រៃយ៍ និងសវនករផ្ទៃក្នុង:** ក្នុងខេត្ត ក្រុងនីមួយៗ សមាជិកអចិន្ត្រៃយ៍នៃគ.ប្រភាគច្រើនគឺជា មន្ត្រីចាស់ទុំ ដែលមានប្រវត្តិ និងបទពិសោធន៍ការងារយូរឆ្នាំ និងតែងតាំងដោយអភិបាលខេត្ត ក្រុង ដើម្បីជួយការងារគ្រប់គ្រង និង សម្របសម្រួលមុខងាររបស់គ.ប្រ។ នៅក្នុងខេត្ត ក្រុងទាំង២៤ មានសមាជិអចិន្ត្រៃយ៍ម្នាក់ជាស្ត្រី។ ចំណែកឯ សវនករផ្ទៃក្នុងជាមន្ត្រីថ្នាក់ខេត្តក្រុង ដែលបានតែងតាំងដើម្បីត្រួតពិនិត្យ ស៊ើបអង្កេត និងធ្វើរបាយការណ៍ជូន អភិបាលខេត្ត ក្រុងអំពីបញ្ហានានាទាក់ទងនឹងគណនេយ្យភាព។ ចាប់តាំងពីពាក់កណ្តាលឆ្នាំ២០០៥ មកម្ល៉េះ សវនករ ផ្ទៃក្នុងបំពេញការងារជាលេខានៃក្រុមការងារគណនេយ្យភាពថ្នាក់ខេត្ត ក្រុង។ ក្នុងចំណោមសវនករផ្ទៃក្នុងសរុប២៤ នាក់ដែលមានក្នុងខេត្ត ក្រុងទាំង ២៤ មាន៤ នាក់ជាស្ត្រី ។

## ៨.៦ សេវាកម្មក្រសួងនានា

ក្រសួងនានាមានតួនាទីយ៉ាងសំខាន់ ក្នុងការឈានព្រមគ្នាជមួយនឹងដំណើការកែទំរង់ នៃរាជរដ្ឋាភិបាល ជាពិសេសលើការ រៀបចំលំអិតបន្ថែមក្របខ័ណ្ឌគតិយុត្តិវិមជ្ឈការ រៀបចំនិងត្រួតពិនិត្យ កម្មវិធីបណ្តុះបណ្តាលជាតិសម្រាប់ពង្រឹងសមត្ថភាពមន្ត្រីគ្រប់ថ្នាក់ ត្រួតពិនិត្យវាយតំលៃ និងតំរង់ទិសដល់ការអនុវត្តរបស់ថ្នាក់ក្រោមជាតិ គ្រប់គ្រងការអនុវត្តគំរោងពាក់ពន្ធ័នានា ក្រោមក្របខ័ណ្ឌវិមជ្ឈការនិងវិសហមជ្ឈការ ព្រមទាំងបង្កើតនិងសាកល្បងការអនុវត្តយុទ្ធសាស្រ្តថ្មីៗក្នុងក្របខ័ណ្ឌវិមជ្ឈការ និងវិសហមជ្ឈការ។ ក្នុងឆ្នាំ២០០៧ មូលនិធិ សរុបមានចំនួន ៣.២លានដុល្លា សំរាប់គាំទ្រដល់ក្រសួង/ស្ថាប័នថ្នាក់ជាតិ ដូចមាន នៅក្នុងតារាងទី៣៣ ខាងក្រោម។ មូលនិធិ ២.២លាន ឬ៦៨% នៃថវិកាសរុបនេះត្រូវបាន វិភាជន៏ដល់អង្គភាពគាំទ្រគម្រោងពាក់ពន្ធ័នានាតាមក្រសួង និង១លានដុល្លា ឬ៣២% ត្រូវបានវិភាជន៏ដល់ក្រសួងមួយចំនួន ផ្សេងទៀតផ្អែកលើលក្ខណៈវិនិច្ឆ័យ និងអាទិភាពដាក់ចុះដោយ គណៈកម្មាធិការជាតិដឹកនាំការងារកំណែ ទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ។

| តារាងទី៣៣: ម្ចាស់អំណោយសេវាកម្មក្រសួង | | |
|---|---|---|
| **ម្ចាស់អំណោយ** | **ចំនួន** | **%** |
| ADB/CCDP2 | 585,000 | 18 |
| ADB/TSSL | 395,000 | 12 |
| **សរុប ADB** | 980,000 | 30 |
| EC/UNDP:DDLG | 694,613 | 22 |
| PSDD | 500,000 | 16 |
| IFAD/CBRD | 132,818 | 4 |
| IFAD/RPRP | 98,030 | 3 |
| IFAD/DRLIP | 245,487 | 8 |
| **សរុប IFAD** | 476,335 | 15 |
| UNICEF | 461,591 | 14 |
| CANADA | 32,464 | 1 |
| UNFPA | 74,160 | 2 |
| **សរុបរួម** | 3,219,163 | 100 |

គម្រោង CCDP2 និង TSSL ដែលធ្វើហិរញ្ញប្បទានដោយធនាគារអភិវឌ្ឍន៏អាស៊ី ត្រូវបានរៀបចំ ដើម្បីគាំទ្រដល់អង្គភាពគាំទ្រគម្រោងពីរ ក្នុងក្រសួងមហាផ្ទៃដែលទទួលបន្ទុកប្រតិបត្តិគម្រោង។ ហិរញ្ញប្បទាន ដល់គម្រោង CCDP2 មានសកម្មភាពដូចជាការតាមដាននិងត្រួតពិនិត្យ ការសាងសង់ការិយាល័យឃុំសង្កាត់ ចុះកិច្ចសន្យាអំពីយុទ្ធនាការពតិមានជាតិ ផ្គត់ផ្គង់សម្ភារៈសម្រាប់ប្រព័ន្ធចុះឈ្មោះជនស៊ីវិលដោយកុំព្យូទ័រ និងគាំទ្រដល់ផែនការបណ្តុះបណ្តាលរបស់ គ.ជ.វ.វ ២០០៧។ ហិរញ្ញប្បទានដល់គម្រោង TSSL រួមមានការផ្គត់ផ្គង់សំភារៈ បរិក្ខានិងយានយន្ត ការតាមដាន ត្រួតពិនិត្យនិងសម្របសម្រួលគំរោង TSSL។

ហិរញ្ញប្បទានដោយគម្រោង EC/UNDP DDLG ត្រូវបានរៀបចំដើម្បីគាំទ្រដល់អង្គភាពគាំទ្រ គម្រោង នៅក្រសួងមហាផ្ទៃដែលទទួលបន្ទុកប្រតិបត្តិគម្រោង រួមមានការងារលទ្ធកម្មសម្ភារៈបរិក្ខារនិងយានយន្ត សកម្មភាពបណ្តុះបណ្តាលនានា និងគាំទ្រដល់សមាគមក្រុមប្រឹក្សាឃុំសង្កាត់នៅថ្នាក់ជាតិនិងខេត្ត ត្រួតពិនិត្យ និងតំរង់ទិសការអនុវត្តន៍គម្រោង និងការសម្របសម្រួលនៅថ្នាក់ជាតិ។

IFAD និងរដ្ឋាភិបាលកាណាដាធ្វើ ហិរញ្ញប្បទានគាំទ្រដល់អង្គភាពគាំទ្រកម្មវិធីដែលបានបង្កើតឡើងនៅ ក្រសួងកសិកម្មរុក្ខាប្រម៉ាញ់និងនេសាទដែលទទួលបន្ទុកប្រតិបត្តិគំរោងRPRP និងRULIP ក៏ដូចជាគម្រោង ADMAC ដែលផ្តល់មូលនិធិដោយប្រទេសកាណាដា។ IFAD ក៏ធ្វើហិរញ្ញប្បទានដល់អង្គភាពគាំទ្រគម្រោង នៅក្រសួងអភិវឌ្ឍន៍ ជនបទដែលប្រតិបត្តិគម្រោង CBRD ។

ដោយឡែក PSDD និង UNICEF បានវិភាជន៍ប្រចាំឆ្នាំដល់ក្រសួង/ស្ថាប័នចំនួន១២ តាមរយៈការពិគ្រោះយោបល់និងសម្រេចចិត្តជាមួយក្រុមការងារផែនការនិងថវិកា គ.ជ.វ.វ នៅខែតុលា ឆ្នាំ២០០៦ ដែលបន្ទាប់មកសាមីក្រសួងបានរៀបចំចេញជាផែនការការងារ និងថវិកា។ ការវិភាជន៍ធ្វើឡើង ដោយផ្អែកលើតួនាទី និងមុខងារដែលអនុវត្តន៍ដោយក្រសួងក្នុងការងារកំណែទម្រង់ កាលានុវត្តភាពការបំពេញការងារកន្លងមក និងតម្លៃប៉ាន់ស្មានរបស់សកម្មភាពនានា។

ដូចក្នុងឆ្នាំ២០០៦ដែរ យូនីសេហ្វបានវិភាជន៍ថវិកាឆ្នាំ២០០៧ដល់ក្រសួងមហាផ្ទៃ ក្រសួងផែនការ និងក្រសួងកិច្ចការនារី សំរាប់សកម្មភាពពាក់ព័ន្ធការពង្រឹងកិច្ចអភិវឌ្ឍន៍សង្គមក្រោមក្របខ័ណ្ឌគតិយុត្តិវិមជ្ឈការ និងវិភាជន៍ដល់ក្រសួងអភិវឌ្ឍន៍ជនបទ សំរាប់សកម្មភាពពាក់ព័ន្ធការងារទឹកស្អាត និងអនាម័យនៅជនបទ ព្រមទាំងយុទ្ធនាការអាសេនិច។

នៅចុងក្រោយ UNFPA បានវិភាជន៍មូលនិធិដល់ក្រសួងមហាផ្ទៃ/នាយកដ្ឋានរដ្ឋបាលមូលដ្ឋានសំរាប់ការតាមដាននិងត្រួតពិនិត្យការបណ្តុះបណ្តាលពាក់ព័ន្ធការអន្តរាគមន៍ដល់ថ្នាក់ក្រោមជាតិរបស់ UNFPA ក្នុងតំបន់ដែលមានសកម្មភាពប្រជាសាស្ត្រ។

**តារាងទី៣៤: សេវាកម្មគាំទ្រក្រសួងឆ្នាំ២០០៧** ឆ្លុះបញ្ចាំងពីការវិភាជន៍ថវិកា និងសង្ខេបសកម្មភាពគន្លឹះ៧ សំរាប់អនុវត្តឆ្នាំ២០០៧ ដោយអង្គភាពថ្នាក់ជាតិចំនួន១៤ ដែលជាក្រសួង/ស្ថាប័នវិស័យ និងជាក្រសួង ស្ថាប័នសមាជិក គ.ជ.វ.វ ។

| តារាង៣៤: សង្ខេបសេវាគាំទ្រថ្នាក់ក្រសួង សម្រាប់ឆ្នាំ២០០៧ | | | |
|---|---|---|---|
| **ល.រ** | **ក្រសួង/ស្ថាប័ន** | **សកម្មភាពសង្ខេប** | **ថវិកាឆ្នាំ២០០៧** |
| 1 | នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន នៃ ក្រសួងមហាផ្ទៃ | 1.1 EC-UNDP/DDLG: ផ្នែកគាំទ្រគម្រោងផ្តល់ការគាំទ្រដល់សមាគមន៍ ក្រុមប្រឹក្សាឃុំសង្កាត់ថ្នាក់ជាតិ និងថ្នាក់ខេត្តក្រុងលើកិច្ចសហប្រតិបត្តិការ អន្តរឃុំសង្កាត់ តាក់តែងគោលនយោបាយ តាមដាននិងត្រួតពិនិត្យ ។ | $694,613 |
| | | 1.2 ADB/TSSL: ផ្នែកគាំទ្រគម្រោង ផ្តល់ការគាំទ្រដល់ប្រតិបត្តិការនៃមូលនិធិលើកស្ទួយជីវភាពរស់នៅ ថ្នាក់ឃុំសង្កាត់ លទ្ធកម្មសម្ភារ: ការបណ្តុះបណ្តាលនិងត្រួតពិនិត្យលើរចនាសម្ព័ន្ធគ្រប់គ្រងថ្នាក់ក្រោមជាតិ និងការត្រួតពិនិត្យ គម្រោង ។ | $585,000 |
| | | 1.3 ADB/CCDP: ផ្នែកគាំទ្រគម្រោង ផ្តល់ការគាំទ្រដល់ការតាមដានត្រួតពិនិត្យការសាងសង់សាលា ឃុំសង្កាត់ បញ្ចូលទិន្នន័យអត្រានុកូលដ្ឋានក្នុងប្រព័ន្ធកុំព្យូទ័រ លទ្ធកម្មសម្ភារ: យុទ្ធនាការផ្សព្វផ្សាយតាមរយៈសារព័ត៌មាន និងបណ្តុះបណ្តាល ។ | $395,000 |
| | | 1.4. PSDD: គាំទ្រការពង្រឹងសមត្ថភាពក្រុមប្រឹក្សាឃុំសង្កាត់ ការអនុវត្តមូលនិធិឃុំសង្កាត់ ប្រព័ន្ធទិន្នន័យផ្សេងៗ នៅថ្នាក់ជាតិ គណនេយ្យភាព និងការតាមដានត្រួតពិនិត្យ ។ | $166,500 |
| | | 1.5. IFAD/RPRP:គាំទ្រការអនុវត្តមូលនិធិអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធថ្នាក់ឃុំសង្កាត់និងការតាមដានត្រួតពិនិត្យ ។ | $74,160 |
| | | 1.6. UNICEF/Seth Koma: គាំទ្រដល់ការបញ្ជ្រាបបញ្ហារបស់ស្ត្រីនិងកុមារនៅថ្នាក់ឃុំសង្កាត់ ។ | $45,000 |
| | | **សរុប** | **$1,960,273** |
| 2 | ហិរញ្ញវត្ថុនិងធនាគារ | 2.1. PSDD: គាំទ្រដល់ការពិនិត្យនិងពង្រឹងការអនុវត្តមូលនិធិឃុំសង្កាត់ សម្របសម្រួលការគ្រប់គ្រងមូលនិធិទាំងឡាយដែលគាំទ្រដល់ឃុំសង្កាត់ ការបណ្តុះបណ្តាលក្រុមប្រឹក្សាឃុំសង្កាត់ ការបណ្តុះបណ្តាលដល់រតនាគារខេត្តក្រុង និងការត្រួតពិនិត្យ ដែលធ្វើឡើងដោយថ្នាក់ជាតិ ។ | $50,000 |
| | | 2.2. IFAD: គណនេយ្យ/របាយការណ៍របស់គម្រោងថ្នាក់ជាតិ សម្រាប់កម្ចីពី IFAD ។ | $17,064 |
| | | **សរុប** | **$67,064** |
| 3 | ផែនការ | 3.1. PSDD: គាំទ្រដល់ប្រព័ន្ធព័ត៌មានជាតិ (ប្រព័ន្ធទិន្នន័យឃុំសង្កាត់) ការពិនិត្យឡើងវិញលើគោលការណ៍ណែនាំអំពីដំណើរការកសាងផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគឃុំសង្កាត់ និងសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុកខណ្ឌ ផ្តល់ការបណ្តុះបណ្តាលដល់មន្ទីរផែនការខេត្តក្រុង ព្រមទាំងការតាមដានត្រួតពិនិត្យពីថ្នាក់ជាតិ ។ | $60,000 |

| តារាង៣៤: សង្ខេបសេវាគាំទ្រថ្នាក់ក្រសួង សម្រាប់ឆ្នាំ២០០៧ | | | |
|---|---|---|---|
| **ល.រ** | **ក្រសួង/ស្ថាប័ន** | **សកម្មភាពសង្ខេប** | **ថវិកាឆ្នាំ២០០៧** |
| | | 3.2. UNICEF/Seth Koma: គាំទ្រដល់ប្រព័ន្ធទិន្នន័យឃុំសង្កាត់ ដោយផ្តោតជាពិសេសលើបញ្ហានានាពាក់ព័ន្ធនឹង ស្ត្រីនិងកុមារ ។ | $25,000 |
| | | **សរុប** | **$85,000** |
| 4 | អភិវឌ្ឍន៍ជនបទ | 4.1. UNICEF/Seth Koma: គាំទ្រដល់ការតាក់តែងគោលការណ៍ណែនាំនិងគោលនយោបាយអនាម័យ និង ទឹកស្អាត និងការអង្កេតជាតិអាសេនិកនៅក្នុងទឹក ព្រមទាំងអន្តរាគមន៍ដើម្បីកាត់បន្ថយជាតិអាសេនិកនេះ ។ | $361,591 |
| | | 4.2. IFAD/CBRD: ផ្នែកគាំទ្រគម្រោងផ្តល់ការគាំទ្រដល់ការគ្រប់គ្រង ការសម្របសម្រួល និងការតាមដានត្រួតពិនិត្យគម្រោង ។ | $92,290 |
| | | 4.3. PSDD: គាំទ្រដល់ការបញ្ជ្រាបយេនឌ័រនៅថ្នាក់ខេត្តក្រុងនិងឃុំសង្កាត់ ការរៀបចំគម្រោងប្លង់ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាននិងការថែទាំ ការពិនិត្យឡើងវិញនិងវាយតម្លៃហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន សវនកម្ម បច្ចេកទេស និងការតាមដានត្រួតពិនិត្យដោយថ្នាក់ជាតិ ។ | $55,000 |
| | | **សរុប** | **$508,881** |
| 5 | កិច្ចការនារី | 5.1. PSDD: គាំទ្រដល់ការបញ្ជ្រាបយេនឌ័រនៅថ្នាក់ខេត្តក្រុងនិងឃុំសង្កាត់ ការបណ្តុះបណ្តាលនិងសម្របសម្រួលដល់ការអនុវត្តក្របខ័ណ្ឌតាមដានត្រួតពិនិត្យការងារយេនឌ័រ និងការតាមដានត្រួតពិនិត្យដោយថ្នាក់ជាតិ ។ | $55,000 |
| | | 5.2. UNICEF/Seth Koma: ពង្រឹងការអភិវឌ្ឍន៍សង្គមនៅមូលដ្ឋាន ។ | $30,000 |
| | | 5.3. IFAD/RPRP: ការបញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្ម ។ | $12,090 |
| | | **សរុប** | **$97,090** |
| 6 | ក្រុមប្រឹក្សា កំណែទម្រង់ | 6.1. PSDD: ចងក្រងបទពិសោធន៍ផ្នែកគោលនយោបាយអំពីការផ្តល់សេវាកម្មសាធារណៈ កិច្ចសន្យា និងយន្តការលើកទឹកចិត្តផ្នែកទៅតាមស្នាដៃនៅថ្នាក់ខេត្តក្រុង ។ | **$20,000** |
| 7 | មុខងារសាធារណៈ | 7.1. PSDD: ពិនិត្យឡើងវិញនិងរៀបចំសេចក្តីព្រាងយន្តការមុខងារសាធារណៈនៅថ្នាក់ក្រោមជាតិ ។ | **$10,000** |

| តារាង៣៤: សង្ខេបសេវាគាំទ្រថ្នាក់ក្រសួង សម្រាប់ឆ្នាំ២០០៧ | | | |
|---|---|---|---|
| **ល.រ** | **ក្រសួង/ស្ថាប័ន** | **សកម្មភាពសង្ខេប** | **ថវិកាឆ្នាំ២០០៧** |
| | **ថវិកាសរុបប្រចាំឆ្នាំសម្រាប់ក្រសួងនិងស្ថាប័នសមាជិករបស់គ.ជ.វ.វ** | | **$2,748,308** |
| 8 | កសិកម្ម | 8.1. IFAD/RULIP: គាំទ្រដល់អង្គភាពគ្រប់គ្រងគម្រោងនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាសម្ភារៈ ចំណាយចាប់ផ្តើមគម្រោង ការបណ្តុះបណ្តាល ការសម្របសម្រួល ការរៀបចំផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំ និងការតាមដានត្រួតពិនិត្យ ។ | $245,487 |
| | | 8.2. IFAD/RPRP: គាំទ្រដល់អង្គភាពគាំទ្រគម្រោងនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លើការងារតាមដានត្រួតពិនិត្យ ការសម្របសម្រួល របាយការណ៍ និងការរៀបចំផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំ ។ | $109,404 |
| | | 8.3. Canada/ADMAC: គាំទ្រដល់អង្គភាពគ្រប់គ្រងគម្រោងនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លើការងារការសម្របសម្រួល តាមដានត្រួតពិនិត្យ របាយការណ៍ និងឥណទានសម្រាប់វិស័យកសិកម្ម ។ | $27,464 |
| | | 8.4. PSDD: ពិនិត្យឡើងវិញលើប្រព័ន្ធផែនការកសិកម្មថ្នាក់ខេត្តក្រុងតាមបែបវិសហមជ្ឈការ អនុវត្តសាកល្បង និងកែសម្រួលតួនាទីរបស់ក្រុមប្រឹក្សាឃុំសង្កាត់ក្នុងវិស័យកសិកម្ម សមាគមន៍កសិករ និងការតាមដានត្រួតពិនិត្យពីថ្នាក់ជាតិ ។ | $20,000 |
| | | **សរុប** | **$402,355** |
| 9 | ធនធានទឹក | 9.1. PSDD: រៀបចំគំនូសប្លង់ហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច ពង្រឹងក្រុមអ្នកប្រើប្រាស់ទឹកនិងការតាមដានត្រួតពិនិត្យ ។ | $20,000 |
| 10 | សង្គមកិច្ច | 10.1. PSDD: អនុវត្តគោលការណ៍ថ្មីសម្រាប់សកម្មភាពសង្គមនៅថ្នាក់ឃុំសង្កាត់ នៅក្នុងខេត្តក្រុងគោលដៅ ។ | $20,000 |
| 11 | បរិស្ថាន | 11.1. PSDD: ពង្រឹងសមត្ថភាពគ្រូឧទ្ទេសថ្នាក់ជាតិ បង្កើតគោលការណ៍ណែនាំសម្រាប់ការគ្រប់គ្រងធនធានធមជាតិនិងបរិស្ថាន និងការចូលរួមរបស់សហគមន៍និងក្រុមប្រឹក្សាឃុំសង្កាត់ក្នុងតំបន់ការពារ ព្រមទាំងការបណ្តុះបណ្តាលនិងការតាមដានត្រួតពិនិត្យ ។ | $20,000 |
| 12 | គ្រប់គ្រងដីធ្លី | 12.1. PSDD: ពង្រឹងសមត្ថភាពគណៈកម្មាធិការប្រើប្រាស់និងបែងចែកដីធ្លីខេត្ត | $3,500 |
| 13 | អាជ្ញាធរកម្ពុជាទទួល | 13.1. Canada/ADMAC: ការគ្រប់គ្រងគម្រោងនៅថ្នាក់ជាតិ ផ្តល់ការគាំទ្រនិងតាមដានត្រួតពិនិត្យការងារ របស់ | $5,000 |

| តារាង៣៤: សង្ខេបសេវាគាំទ្រថ្នាក់ក្រសួង សម្រាប់ឆ្នាំ២០០៧ | | | |
|---|---|---|---|
| **ល.រ** | **ក្រសួង/ស្ថាប័ន** | **សកម្មភាពសង្ខេប** | **ថវិកាឆ្នាំ២០០៧** |
| | បន្ទុកបោះសំអាតមីន | MAPU ក្នុងខេត្តទាំង៥។ | |
| | | **ថវិកាសរុបប្រចាំឆ្នាំសម្រាប់ក្រសួងនិងស្ថាប័នជំនាញ** | **$470,855** |
| | | **សរុបរួម** | **$3,219,163** |

## ៨.៧ ការគាំទ្រកម្មវិធីជាតិៈ លេខាធិការដ្ឋាន គ.ជ.វ.វ និងក្រុមគាំទ្រកម្មវិធី

ក្រុមគាំទ្រកម្មវិធី ដែលស្ថិតនៅក្រោម គ.ជ.វ.វ ត្រូវបានបង្កើតឡើងនៅខែមករាឆ្នាំ២០០៧ នៅក្រសួងមហាផ្ទៃ ដែលមានអណត្តិដូចតទៅៈ ១) ត្រួតពិនិត្យការអនុវត្តន៍ផែនការការងារនិងថវិកាប្រចាំឆ្នាំរបស់គ.ជ.វ.វ និង ២) ជាភ្នាក់ងារប្រតិបត្តិសំរាប់គម្រោងនានា ដែលចុះអនុសារណៈជាមួយ គ.ជ.វ.វ។ គិតរហូតមកដល់ខែកុម្ភៈ ឆ្នាំ២០០៧ គម្រោងដែលស្ថិតនៅក្រោមការទទួលខុសត្រូវ និងប្រតិបត្តិផ្ទាល់របស់ក្រុមគាំទ្រកម្មវិធី គ.ជ.វ.វ មាន PSDD (UNDP/DfID/Sida), ធនាគារពិភពលោក RILG និង Danida/DfID NRML សមាសភាគវិមជ្ឈការនិងវិសហមជ្ឈការ ដែលរួមបញ្ចូលគ្នាមានថវិកាសរុបចំនួន ២១លានដុល្លា ក្នុងឆ្នាំ២០០៧ ឬជិត៦០% នៃជំនួយពីខាងក្រៅរបស់ផែនការការងារ និងថវិកាប្រចាំឆ្នាំ គ.ជ.វ.វ។ ដោយភាគច្រើននៃការគាំទ្រកម្មវិធីថ្នាក់ក្រោមជាតិ និងជំនួយបច្ចេកទេសស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រុមគាំទ្រកម្មវិធី ជាហេតុនាំឱ្យទំនាក់ទំនងកាន់តែជិតស្និទ្ធជាមួយម្ចាស់អំណោយគម្រោងផ្សេងៗ ក្រោមក្របខ័ណ្ឌផែនការការងារនិងថវិកាប្រចាំឆ្នាំ គ.ជ.វ.វ ពោលអាស្រ័យទៅលើការគាំទ្រ ដោយផ្ទាល់ឬដោយប្រយោល។

ដូចបង្ហាញក្នុងដ្យាក្រាមខាងក្រោម ក្រុមគាំទ្រកម្មវិធីគ.ជ.វ.វ បានបង្កើតអង្គភាពបួន ក្រោមការគ្រប់គ្រងផ្ទាល់របស់ខ្លួនដែលមានឈ្មោះថាៈ អង្គភាពហិរញ្ញវត្ថុ អង្គភាពទំនាក់ទំនងគម្រោង/គ្រប់គ្រងកិច្ចសន្យា អង្គភាពតាមដានវាយតម្លៃនិងពតិមាន និងអង្គភាពរដ្ឋបាល។ ក្នុងគោលបំណងសម្របសម្រួលនិងប្រតិបត្តិកម្មវិធី ផែនការការងារ និងថវិកាប្រចាំឆ្នាំគ.ជ.វ.វ ក្រុមគាំទ្រកម្មវិធីបានរក្សាទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយ អភិបាល ខេត្តក្រុង គ.អ.ជ.ខ/ក និង គ.ប្រ ទាំង២៤ខេត្ត/ក្រុង។

**ក្រុមគាំទ្រ កម្មវិធីនៃ គជវវ**

ថ្នាក់គ្រប់គ្រង

ផ្នែក ហិរញ្ញវត្ថុ

ផ្នែក
គ្រប់គ្រងកិច្ចសន្យា និង
សម្របសម្រួល
គម្រោង

ផ្នែក
ត្រួតពិនិត្យវាយតំលៃ
និងពតិមាន

ផ្នែក
កិច្ចការរដ្ឋបាល

អភិបាលខេត្ត

គណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត ក្រុង

គណៈកម្មាធិការប្រតិបត្តិ

ក្រុមគាំទ្រកម្មវិធីនៃលេខាធិការដ្ឋាន គ.ជ.វ.វ ត្រូវបានបំពាក់បុគ្គលិក និងចាប់ផ្តើមប្រតិបត្តិការពីដើមខែកុម្ភៈ ហើយសារពើភ័ណ្ឌចាំបាច់នានា ក៏ត្រូវបានផ្ទេរមកពី គ.ជ.ន.ស ចប់សព្វគ្រប់នៅពាក់កណ្តាលខែកុម្ភៈឆ្នាំ២០០៧។ ក្នុងខែកុម្ភៈនេះ ផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំ នៃក្រសួង ស្ថាប័នពាក់ពន្ធ័ទាំង១២ និងខេត្តក្រុងទាំង២៤ ត្រូវបានរៀបចំរួចរាល់ និងរំពឹងចាប់ផ្តើមអនុវត្តពេញលេញនៅចុងខែមីនា។ ក្រោមអណត្តិការងារនៃ គ.ជ.វ.វ ក្រុមគាំទ្រកម្មវិធី មិនអនុវត្តសកម្មភាព ដែលត្រូវបានកំណត់រួចហើយក្នុងអណត្តិការងារនៃក្រសួងនានាទេ ប៉ុន្តែ ដើរតួជាអ្នកបង្កលក្ខណៈឱ្យមាន វេទិកាពិភាក្សាអន្តរក្រសួង និងផ្តល់កិច្ចសម្របសម្រួលការងារពាក់ព័ន្ធនឹង ហិរញ្ញប្បទានពីខាងក្រៅ សកម្មភាពអភិបាលកិច្ចនិងអភិវឌ្ឍន៏ និងគាំពារភាពជាដៃគូ នៅក្នុងរដ្ឋាភិបាល និងរវាង រដ្ឋាភិបាល និងម្ចាស់ជំនួយនានា ជាពិសេសការចូលរួមចំណែក ក្នុងកិច្ចពិភាក្សានានា ដើម្បីតម្រង់ទិស អនាគត ក្នុងបរិបទកំណែទម្រង់អភិបាលកិច្ច។ តារាង៣៥ ខាងក្រោមផ្តល់ពតិមានពីធនធានក្រុមគាំទ្រកម្មវិធី គ.ជ.វ.វ ឆ្នាំ២០០៧។ ដូចបានបង្ហាញក្នុងតារាង នេះ PSDD តំណាងឱ្យស្ទើរតែពាក់កណ្តាលនៃម្ចាស់ធនធានសរុប និងជិតពាក់កណ្តាលទៀតធនធានពីធនាគារពិភពលោក និងដានីដា។ បដិភាគពីរាជរដ្ឋាភិបាល តំណាងឱ្យមូលនិធិ ជាដៃគូ ក្រោមគម្រោង WB/RILG និង IFAD/RPRP។

**តារាងទី៣៥: ប្រភពធនធានក្រុមគាំទ្រកម្មវិធី គជវវ ២០០៧**

| ប្រភពទុន | ចំនួន | % |
|---|---|---|
| **PSDD** | 781,935 | 42% |
| **WB/RILG** | 563,724 | 30% |
| **DANIDA/NRML** | 340,178 | 18% |
| **IFAD/RPRP** | 121,970 | 7% |
| **រាជរដ្ឋាភិបាលកម្ពុជា** | 58,457 | 3% |
| **សរុប** | **$1,866,264** | **100%** |

ធនធានវិភាជន៏ដល់ក្រុមគាំទ្រកម្មវិធី គ.ជ.វ.វ ត្រូវបានរៀបចំនៅចុងឆ្នាំ២០០៦ និង **តារាង៣៧: ថវិកាក្រុមគាំទ្រកម្មវិធី គ.ជ.វ.វ** ខាងក្រោមឆ្លុះបញ្ចាំងតាមខ្ទង់ថវិកា។ ដូចបញ្ជាក់ក្នុងតារាង ប្រហែលពាក់កណ្តាល នៃធនធានសរុបត្រូវបានគ្រោងសម្រាប់ការតពិគ្រោះយោបល់និងការសិក្សា ដែលនឹងត្រូវជ្រើសរើសដោយ ក្រុមគាំទ្រកម្មវិធីពាក់ព័ន្ធនឹងការបង្កើតគោលនយោបាយ ការរៀបចំកម្មវិធីជាតិ ការតាមដានវាយតំលៃ ការគ្រប់គ្រង ប្រព័ន្ធពតិមាន ការបង្កើតប្រព័ន្ធនានា ការវាយតំលៃនានា ការពិនិត្យនិងសិក្សាបច្ចេកទេសនានា។ ផែនការ ក្រុមពិគ្រោះយោបល់រួមត្រូវបានឆ្លុះបញ្ចាំងក្នុង **ឧបសម្ព័ន្ធ ៣: ផែនការពិគ្រោះយោបល់របស់ក្រុមគាំទ្រ កម្មវិធី។** ធនធានសរុបសម្រាប់ប្រតិបត្តិការរបស់ក្រុមគាំទ្រកម្មវិធី ដែលមិនរាប់បញ្ចូលការពិគ្រោះយោបល់និង សវនកម្ម មានចំនួន៨៥២.០០០ដុល្លា ដែលក្នុងនោះ៧០%ហិរញ្ញប្បទានដោយ PSDD។

### តារាងទី៣៦: ថវិការក្រុមគាំទ្រកម្មវិធី គជវវ ២០០៧

| ខ្ទង់ថវិកា | PSDD | WB | RPRP | DANIDA | RGC* | សរុប |
|---|---|---|---|---|---|---|
| ចំណាយបេសកកម្មផ្លូវការ | 68,430 | | 4,000 | | | **72,430** |
| សវនកម្មអនុកិច្ចសន្យានានា | 40,000 | 20,000 | | 20,000 | | **80,000** |
| សេវាពិគ្រោះយោបល់ | 135,000 | 367,000 | 94,930 | 300,000 | 36,374 | **933,304** |
| ទស្សនកិច្ចសិក្សា វគ្គបណ្តុះបណ្តាល សិក្ខាសាលា | 30,000 | 35,000 | 11,100 | | | **76,100** |
| លទ្ធកម្មក្នុងស្រុក | 30,000 | 141,724 | | | 20,383 | **192,107** |
| ប្រាក់ខែមន្ត្រី បុគ្គលិក | 327,580 | | 7,440 | | | **335,020** |
| ចំណាយប្រតិបត្តិការ | 150,925 | | 4,500 | 20,178 | 1,700 | **177,303** |
| **សរុបរួម** | **781,935** | **563,724** | **121,970** | **340,178** | **58,457** | **1,866,264** |

* ថវិកាបដិភាគសំរាប់គម្រោង WB/RILG ( $56,757) និង IFAD/RPRP ( $2,375)

## ៨.៨ សហប្រតិបត្តិការបច្ចេកទេសពីខាងក្រៅ

ធនធានសរុបចំនួន៦,៩លានដុល្លារ ត្រូវបានកៀងគរក្រោមរូបភាពសហប្រតិបត្តិការបច្ចេកទេសពីខាងក្រៅ ដែលត្រូវអនុវត្តក្នុងក្របខ័ណ្ឌផែនការសកម្មភាពនិងថវិកាឆ្នាំ២០០៧ របស់ គ.ជ.វ.វ។ ក្នុងចំនួនថវិកាសរុបនេះ ថវិកាចំនួន២លានដុល្លារនឹងត្រូវប្រើសម្រាប់ចំណាយលើទីប្រឹក្សាអន្តរជាតិ ៣.៣លានដុល្លារសម្រាប់ទីប្រឹក្សាជាតិ និងថវិកាចំនួន១.៥លានដុល្លារ សម្រាប់សេវាប្រឹក្សាបច្ចេកទេស ដែលនឹងត្រូវផ្តោតទៅលើទិដ្ឋភាពផ្សេងៗនៃបញ្ហាពាក់ព័ន្ធនឹងអភិបាលកិច្ច និងការអភិវឌ្ឍន៍។ ក្នុងចំនួនថវិកាដែលត្រូវចំណាយលើសេវាទីប្រឹក្សានេះ ថវិកាប្រមាណជា៤០% ឬស្មើនឹង២.២លានដុល្លារ នឹងត្រូវប្រើសម្រាប់គាំទ្រកម្មវិធីរួម ដែលមាននៅក្នុងផែនការសកម្មភាព និងថវិកាឆ្នាំ២០០៧របស់ គ.ជ.វ.វ ហើយថវិកាប្រមាណជា៦០%ទៀត ឬស្មើនឹង៣.៣លានដុល្លារ នឹងត្រូវប្រើសម្រាប់ការគាំទ្របច្ចេកទេសដល់គម្រោងជាក់លាក់មួយចំនួន។ ដូចគ្នានេះដែរ ក្នុងចំនួនសរុបនៃថវិកាសម្រាប់សេវាប្រឹក្សាបច្ចេកទេស ថវិកាប្រមាណជា៥០% ឬស្មើនឹង៧០០,០០០ដុល្លារ នឹងត្រូវប្រើ សម្រាប់ការគាំទ្រផ្នែកបច្ចេកទេសដើម្បីរៀបចំឯកសារជាក់លាក់មួយចំនួន ពាក់ព័ន្ធទៅនឹងកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ ហើយថវិកាប្រមាណជា៥០%ទៀត ត្រូវបានបែងចែកសម្រាប់គាំទ្រដល់សេវាប្រឹក្សាបច្ចេកទេស របស់គម្រោងជាក់លាក់នីមួយៗ។ នៅថ្នាក់ក្រោមជាតិ ថវិកាសរុបចំនួន១.៦លានដុល្លារ គឺស្មើត្រឹមតែ៣.៥% នៃថវិកាសរុបឆ្នាំ២០០៧ ដែលត្រូវផ្ទេរទៅថ្នាក់ក្រោមជាតិ ត្រូវបានបែងចែកសម្រាប់ សហប្រតិបត្តិការបច្ចេកទេសគាំទ្ររដ្ឋបាលខេត្តក្រុងលើការគ្រប់គ្រងនិងការអនុវត្តផែនការសកម្មភាពនិងថវិកាឆ្នាំ២០០៧របស់ គ.ជ.វ.វ។ **តារាងទី៣៧ ស្តីពីសហប្រតិបត្តិការបច្ចេកទេស** នឹងបង្ហាញលំអិតពីប្រភពនៃ មូលនិធិទៅតាមម្ចាស់ជំនួយនីមួយៗ។

| តារាង៣៧ : សហប្រតិបត្តិការបច្ចេកទេសខាងក្រៅ ទៅតាមម្ចាស់ជំនួយនីមួយៗ | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ម្ចាស់ជំនួយ | អន្តរជាតិ | | ជាតិ | | សេវាប្រឹក្សាបច្ចេកទេស | | សរុប | |
| | ចំនួន | % | ចំនួន | % | ចំនួន | % | ចំនួន | % |
| **គម្រោង PSDD** | **628,414** | **32%** | **1,940,122** | **56%** | **260,000** | **18%** | **2,828,536** | **41%** |
| គម្រោង ADB-TSSL | 758,000 | 38% | 965,000 | 28% | | | 1,723,000 | 25% |
| គម្រោង ADB-CCDP2 | | | | | 300,000 | 20% | 300,000 | 4% |
| **សរុបរងសម្រាប់ ADB** | **758,000** | **38%** | **965,000** | **28%** | **300,000** | **20%** | **2,023,000** | **29%** |
| គម្រោង EC-UNDP/DDLG | 300,000 | 15% | 132,197 | 4% | 80,697 | 5% | 512,894 | 7% |
| គម្រោង EC-UNDP/EFMP | | | 59,000 | 2% | | | 59,000 | 1% |
| **សរុបរងសម្រាប់ EC-UNDP** | **300,000** | **15%** | **191,197** | **6%** | **80,697** | 5% | **571,894** | **8%** |
| **ធនាគារពិភពលោក** | | | | | **367,000** | 25% | **367,000** | 5% |
| **អាល្លឺម៉ង់ /GTZ** | **200,000** | **10%** | **150,000** | | | | **350,000** | 5% |
| **ដាណឺម៉ាក** | | | **0** | 0% | **320,000** | 22% | **320,000** | 5% |
| **យូនីសេហ្វ** | **100,000** | **5%** | **200,000** | 6% | | | **300,000** | 4% |
| **គម្រោង IFAD/RPRP** | | | | | **94,930** | 6% | **94,930** | 1% |
| **គម្រោង Canada/ADMAC** | | | | | **50,351** | 3% | **50,351** | 1% |
| **សរុប** | **$1,986,414** | **100%** | **$3,446,319** | **100%** | **$1,472,978** | **100%** | **$6,905,711** | **100%** |

**តារាងទី៣៨ ស្តីពីជំនួយការបច្ចេកទេសតាមប្រភេទនីមួយៗ** បង្ហាញពីទិន្នន័យរួមនៃជំនួយការបច្ចេកទេស សម្រាប់ឆ្នាំ២០០៧ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងសម្រាប់សេវាប្រឹក្សាបច្ចេកទេសនានាផងដែរ។ សន្ទតិថា ភាគច្រើននៃសេវាប្រឹក្សាបច្ចេកទេសជាសេវាអន្តរជាតិ ៥០%នៃជំនួយការបច្ចេកទេសសរុប គឺសម្រាប់ទីប្រឹក្សា និងអ្នកពិគ្រោះយោបល់អន្តរជាតិ ហើយ៥០%ទៀត សម្រាប់បុគ្គលិកជាតិ ដែលមានកិច្ចសន្យាជាមួយគម្រោងរបស់ម្ចាស់ជំនួយនីមួយៗ។

គ.ជ.វ.វ ជឿជាក់ថា ដោយមានកិច្ចខិតខំប្រឹងប្រែងរួមគ្នាដើម្បីធ្វើឱ្យមានសង្គតិភាព នូវរាល់ការគាំទ្រពីខាងក្រៅដល់កំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ តាមរយៈការអនុវត្តកម្មវិធីជាគោល ភាគច្រើននៃចំណាយលើជំនួយការបច្ចេកទេសនឹងអាចត្រូវបានកាត់បន្ថយ។ ការសិក្សាស្រាវជ្រាវអំពីតម្រូវការជំនួយបច្ចេកទេស ដែលជាផ្នែកមួយនៃការរៀបចំកម្មវិធីជាតិគាំទ្រវិមជ្ឈការនិងវិសហមជ្ឈការ នឹងត្រូវធ្វើឡើងក្នុង ភាពជាដៃគូជាមួយម្ចាស់ជំនួយនានារបស់ គ.ជ.វ.វ ក្នុងឆ្នាំ២០០៧។

| តារាង៣៨ : ជំនួយការបច្ចេកទេសតាមប្រភេទនីមួយៗ | | |
|---|---|---|
| **ប្រភេទ** | **ចំនួន** | **%** |
| **ថ្នាក់ខេត្តក្រុង** | **2,526,748** | **37%** |
| អន្តរជាតិ | 404,000 | 6% |
| ជាតិ | 2,122,748 | 31% |
| **ថ្នាក់ជាតិ** | **2,839,611** | **41%** |
| អន្តរជាតិ | 1,582,414 | 23% |
| ជាតិ | 1,257,197 | 18% |
| **សេវាប្រឹក្សាបច្ចេកទេស** | **1,539,352** | **22%** |
| **សរុប** | **$6,905,711** | **100%** |

ខាងក្រោមនេះ គឺជាការពិពិណនាសង្ខេបនូវរាល់សហប្រតិបត្តិការបច្ចេកទេសដែលដៃគូអភិវឌ្ឍន៍ផ្តល់ឱ្យ :

**គម្រោង PSDD**: ក្រោមគម្រោង PSDD សហប្រតិបត្តិការបច្ចេកទេសរួមរបស់គម្រោងត្រូវបានផ្តល់ទៅឱ្យរដ្ឋបាលខេត្តក្រុង និងក្រុមគាំទ្រកម្មវិធីនៃ គ.ជ.វ.វ តាមរយៈទីប្រឹក្សា ដែលកម្មវិធីអភិវឌ្ឍន៍អង្គការ សហប្រជាជាតិបានជ្រើសរើសក្រោមកិច្ចសហការជាមួយក្រុមគាំទ្រកម្មវិធីនៃ គ.ជ.វ.វ។ កិច្ចសហប្រតិបត្តិការបច្ចេកទេសរួមគ្នារបស់គម្រោង PSDD មានតួនាទីគាំទ្រការអនុវត្តរាល់គម្រោងរបស់ដៃគូម្ចាស់ជំនួយក្រោមក្របខ័ណ្ឌនៃផែនការសកម្មភាពនិងថវិកាប្រចាំរបស់ គ.ជ.វ.វ។ នៅថ្នាក់ខេត្តក្រុង គម្រោង PSDD មានបុគ្គលិកចន្លោះពី៤ទៅ៦នាក់។ បុគ្គលិកទាំងនេះមានតួនាទីផ្តល់ការគាំទ្រដល់អភិបាលខេត្តក្រុង ផ្នែកគ្រប់គ្រងទាំង៤របស់គណៈកម្មាធិការប្រតិបត្តិ និងមន្ទីរជំនាញជុំវិញខេត្តក្រុងដែលមានអនុកិច្ចសន្យាជាមួយគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្តក្រុង លើការគ្រប់គ្រងនិងអនុវត្តធនធានទាំងឡាយដែលម្ចាស់ជំនួយទាំង១២បាន ផ្ទេរទៅឱ្យគណៈកម្មាធិការប្រតិបត្តិនៃគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្តក្រុង។ ដោយឡែកនៅថ្នាក់ជាតិ គម្រោង PSDD ផ្តល់ការគាំទ្រដល់ក្រុមគាំទ្រកម្មវិធីនៃ គ.ជ.វ.វ លើការងារសម្របសម្រួលទូទៅ និងការអនុវត្តផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំ។ ជាងនេះទៅទៀត គម្រោង PSDD ក៏ត្រូវការគាំទ្រដល់នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន (DoLA) នៃក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងផែនការ និង ក្រសួងកសិកម្ម ស្របទៅតាមអាណត្តិរបស់ក្រសួងនីមួយៗ ក្រោមក្របខ័ណ្ឌវិមជ្ឈការនិងវិសហមជ្ឈការ។ ថវិកាចំនួន១២០,០០០ដុល្លារត្រូវបានវិភាជទៅឱ្យ គ.ជ.វ.វ ក្នុងខ្ទង់ថវិការបស់ក្រុមគាំទ្រកម្មវិធីនៃ គ.ជ.វ.វ សម្រាប់សេវាប្រឹក្សាបច្ចេកទេសដើម្បីរៀបចំកម្មវិធីជាតិថ្មី។

**គម្រោង ADB**: ជំនួយការបច្ចេកទេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ត្រូវបានផ្តល់ជា ទីប្រឹក្សារយៈពេលខ្លី និងរយៈពេលវែង ដែលបានជ្រើសរើសជាលក្ខណៈបុគ្គល ឬជាក្រុមហ៊ុនពិគ្រោះយោបល់ សម្រាប់គាំទ្រការអនុវត្ត

គម្រោងចំនួន២ ដែលធនាគារសហការ ជាមួយក្រសួងមហាផ្ទៃ។ ជំនួយការបច្ចេកទេសរបស់គម្រោង CCDP2 គឺផ្តោតលើ ការគ្រប់គ្រងរួមផ្នែកវិស្វកម្ម និងការតាមដានត្រួតពិនិត្យសេវាកម្មនានា ពាក់ព័ន្ធនឹងការសាងសង់សាលាឃុំ សង្កាត់។ ជាងនេះទៅទៀត ជំនួយការបច្ចេកទេសរបស់គម្រោង CCDP2 ក៏ផ្តោតផងដែរលើការរៀបចំ និង ការបណ្តុះបណ្តាលនានា សម្រាប់បញ្ចូលទិន្នន័យអត្រានុកូលដ្ឋានក្នុងប្រព័ន្ធកុំព្យូទ័រ ការរៀបចំនិងការវាយតម្លៃយុទ្ធនាការផ្សព្វផ្សាយព័ត៌មាន និងការកសាងសមត្ថភាពដល់មន្ត្រីនៃនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន នៅថ្នាក់ជាតិ និងនៅថ្នាក់ខេត្តក្រុង។ ដោយឡែកជំនួយការបច្ចេកទេសរបស់គម្រោង TSSL នឹងផ្តោតលើការគ្រប់គ្រងគម្រោង រៀបចំគម្រោងវិស័យនិងវិស័យរង ពាក់ព័ន្ធនឹងសកម្មភាពគ្រប់គ្រងធនធានធម្មជាតិនិងបរិស្ថាន ព្រមទាំងការកសាងសមត្ថភាពលើការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន និងការលើកស្ទួយជីវភាព រស់នៅ។

**EC-UNDP:** ជំនួយការបច្ចេកទេសរបស់គម្រោង EC-UNDP/DDLG ដែល UNDP បានជ្រើសរើសនឹងផ្តោត ជាពិសេសលើការគ្រប់គ្រងគម្រោង ការអភិវឌ្ឍបន្ថែមនូវយុទ្ធសាស្ត្រនិងយន្តការនានា សម្រាប់ពង្រឹងកិច្ចសហប្រតិបត្តិការអន្តរឃុំសង្កាត់ គាំទ្រដល់សមាគមទីក្រុមប្រឹក្សាឃុំសង្កាត់ថ្នាក់ជាតិ និងថ្នាក់ខេត្ត ព្រមទាំងផ្តល់ការ គាំទ្រផ្នែកគោលនយោបាយដល់ គ.ជ.វ.វ។

**World Bank/RILG**: ជំនួយការបច្ចេកទេសរបស់គម្រោង RILG ក្នុងឆ្នាំ២០០៧ រួមមាន សេវាប្រឹក្សាបច្ចេកទេស សម្រាប់រៀបចំផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំ២០០៧ របស់គម្រោង RILG ដូចដែលមាននៅក្នុងឧបសម្ព័ន្ធ៣ អំពីផែនការសេវាប្រឹក្សាបច្ចេកទេសរបស់ក្រុមគាំទ្រកម្មវិធីនៃ គ.ជ.វ.វ។

**ប្រទេសអាល្លឺម៉ង់/GTZ**: ជំនួយបច្ចេកទេសពីរដ្ឋាភិបាល អាល្លឺម៉ង់ តាមរយៈអង្គការ GTZ រួមមានទីប្រឹក្សាជាតិ និង អន្តរជាតិ ដែលកំពុងធ្វើការនៅក្នុងគម្រោង អភិវឌ្ឍន៏ជនបទ ក្នុងខេត្តកំពត និងកំពង់ធំ គាំទ្រដល់គម្រោង IFAD/CBRD គ្រប់គ្រងប្រតិបត្តិការដោយក្រសួង អភិវឌ្ឍន៏ជនបទ។ គួរកត់សំគាល់ថា ងអ្គការ GTZ ក៏មានផ្តល់កិច្ចគាំទ្របច្ចេកទេសផ្ទាល់ ដល់ គជវវ ផងដែរ តាមរយៈគម្រោងមួយផ្សេងទៀតឈ្មោះ កំណែទម្រង់រដ្ឋបាលនិងវិមជ្ឈការ (ARD)។ ពត៌មានលំអិត អំពីគម្រោងនេះ មិនអាចរកបានទេ ក្នុងពេលរៀបចំឯកសារផែនការនេះ។

**Danida-UK/NRML**: ជំនួយបច្ចេកទេសពីគម្រោង Danida-UK/NRML ក្នុងសមាសភាគវិមជ្ឈការ និងវិសហមជ្ឈការ នឹងត្រូវផ្តល់ជាសេវាពិគ្រោះយោបល់ក្នុងដំណើរការរៀបចំផែនការសកម្មភាពនិងថវិការ២០០៧ នៃគម្រោងគ្រប់គ្រងធនធាន ធម្មជាតិនិងជីវភាពរស់នៅ។ ពត៌មាននេះ មានបង្ហាញនៅក្នុងឧបសម្ពន្ធ័ទី៣ ស្តីពីផែនការ សេវាពិគ្រោះយោបល់ នៃក្រុមគាំទ្រកម្មវិធី គជវវ។

**UNICEF/សិទ្ធិកុមារ**: អង្គការយូនីសេហ្វ ផ្តល់កិច្ចគាំទ្របច្ចេកទេស នៅក្នុងខេត្តគោលដៅចំនួន៦ តាមរយៈគម្រោងសិទ្ធិកុមារ ដោយផ្តល់ការគាំទ្រជាអាទិចំពោះមន្ទីរនានា ដែលផ្តល់សេវាពាក់ព័ន្ធស្ត្រី និងកុមារ។ យូនីសេហ្វក៏មានផ្តល់សេវាគាំទ្របច្ចេកទេសផងដែរ ដល់ក្រសួងចំនួន៤នៅថ្នាក់ជាតិ ដែលជាដៃគូអនុវត្តគម្រោង សិទ្ធិកុមារ។

**IFAD/RPRP:** ជំនួយបច្ចេកទេសរបស់ IFAD ក្នុងឆ្នាំ២០០៧ នឹងផ្តល់ជា សេវាអង្កេតស្រាវជ្រាវមួយ ស្តីពីធនធានទឹក ក្រោមដី នៅខេត្តព្រៃវែង និង ស្វាយរៀង ដែលនឹងគ្រប់គ្រងផ្ទាល់ដោយ ក្រុមគាំទ្រកម្មវិធី គជវវ។

**កាណាដា/ADMAC:** ជំនួយបច្ចេកទេសរបស កាណាដា នឹងត្រូវផ្តល់តាមរយៈសេវាពិគ្រោះយោបល់ សម្រាប់គាំទ្រដល់ក្រុមគាំទ្រកម្មវិធីនៃក្រសួងកសិកម្ម និងផ្តោតជាអាទិលើការពង្រឹង ការរៀបចំនិងកិច្ចប្រតិបត្តិការនៃសមាសភាគឥណទានកសិកម្ម ក្រោមគំរោង ADMAC។

## ៩. ផែនការសកម្មភាព និងថវិកាសម្រាប់ឆ្នាំ ២០០៧ របស់ គ.ជ.វ.វ

ប្រតិទិនប្រចាំឆ្នាំនិង ផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំ២០០៧ របស់ គជវវ ត្រូវបានភ្ជាប់មក ជាឧបសម្ព័ន្ធទី១ និងឧបសម្ព័ន្ធទី២។ ចំពោះប្រតិទិនការងារប្រចាំឆ្នាំ២០០៧ បានបង្ហាញសកម្មភាព និងព្រឹត្តការណ៍សំខាន់ៗ និងពេលវេលាដែលនឹងត្រូវអនុវត្តនៅថ្នាក់ឃុំ ស្រុក ខេត្តនិង ថ្នាក់ជាតិ ដោយស្របតាម ប្រព័ន្ធផែនការ កម្មវិធី ប្រព័ន្ធហិរញ្ញវត្ថុ និងវដ្តនៃការអនុវត្តគម្រោង ព្រមទាំងឆ្លុះបញ្ចាំងទៅនឹងក្របខណ្ឌច្បាប់ លើវិមជ្ឈការ ផែនការពង្រឹង សមត្ថភាពរបស់ គជវវ ឆ្នាំ២០០៧ និងវដ្តកម្មវិធីប្រចាំឆ្នាំ។

ទាក់ទងទៅនឹងធនធានដែលពិពណ៌នានៅក្នុង **តារាងទី៣៩: សង្ខេបកិច្ចព្រមព្រៀងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០០៧** ដែលមាននៅទំព័រខាងក្រោមនេះ បានបង្ហាញនូវទំហំផែនការសកម្មភាពនិងថវិកា នីមួយៗដែលបានបង្កើត និងអនុម័តដោយភ្នាក់ងារទទួលខុសត្រូវ ក្នុងការគ្រប់គ្រងនិងប្រើប្រាស់ធនធានដោយ ស្ថិតនៅក្រោមក្របខណ្ឌផែនការសកម្មភាពនិងថវិការបស់ គជវវ ឆ្នាំ២០០៧។ ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំទាំង១៥ របស់ម្ចាស់ជំនួយនីមួយៗ ត្រូវបានបង្កើតឡើង និងចុះហត្ថលេខារវាងម្ចាស់ជំនួយនិង ស្ថាប័នអនុវត្តនៃរដ្ឋាភិបាល។ យោងទៅលើកិច្ចព្រមព្រៀងជាមួយម្ចាស់ជំនួយទាំងនោះ មានផែនការសកម្មភាពនិងថវិកានៅថ្នាក់កណ្តាល គាំទ្រដល់ក្រសួងពាក់ព័ន្ធចំនួន២៥ និងផែនការសកម្មភាពនិងថវិកានៅថ្នាក់ខេត្តចំនួន៧៧ ដែលបានរៀបចំ និងចុះហត្ថលេខារវាងអភិបាលខេត្តជាប្រធាន គអជខ និង ស្ថាប័នទទួលខុសត្រូវនៅថ្នាក់កណ្តាល។ ដោយឡែក យោងលើផែនការសកម្មភាពនិងថវិកានៅថ្នាក់ខេត្ត មានអនុកិច្ចសន្យា សរុបទាំងអស់ចំនួន៥១៦ ដែលបានរៀបចំ ដោយមន្ទីរជំនាញ និងថ្នាក់ស្រុក ព្រមទាំងផ្នែករបស់គ.ប្រ/គអជខ ដែលអនុកិច្ចសន្យាទាំងនោះ ត្រូវបានអនុម័តដោយអភិបាលខេត្ត។ ចំពោះសកម្មភាព លទ្ធផលរំពឹងទុក និងគម្រោងថវិកា ដែលស្ថិតនៅក្នុងកិច្ចព្រមព្រៀង សរុបចំនួន៦៣៣នេះ ត្រូវបានរៀបចំលំអិតនិងច្បាស់លាស់ ដែលធានាឱ្យមាននូវគណនេយ្យភាព តម្លាភាព និងប្រសិទ្ធិភាព

ក្នុងដំណើរការប្រតិបត្តិគម្រោងនីមួយៗ ។ ចំណែកនៃផែនការសកម្មភាពនិងថវិកា ដែលរៀបចំដោយ ក្រសួង ខេត្ត ក្រុង និងមន្ទីរជំនាញ ត្រូវបានដាក់បញ្ចូលនៅក្នុង ប្រព័ន្ធទិន្នន័យកិច្ចសន្យារបស់ គ.ជ.វ.វ ដែលជា ប្រព័ន្ធទិន្នន័យ ធានាឱ្យមានសង្គតិភាព នៅក្នុងការរៀបចំទម្រង់កិច្ចសន្យា ឯកតាតាមខ្ទង់ថវិកា ប្រភេទ លទ្ធផល រំពឹងទុកការ តាមដានលើការរីកចម្រើននិង ការរៀបចំរបាយការណ៍ ។

ចំពោះផែនការសកម្មភាពនិងថវិការបស់ គ.ជ.វ.វ ឆ្នាំ២០០៧ ដែលលាតត្រដាងខាងក្រោមនេះ នឹងមិនមានបង្ហាញ ពតិមានលំអិត ដែលទាក់ទងទៅនឹងកិច្ចព្រមព្រៀងផែនការសកម្មភាព និងថវិកាដែលបានរៀបរាប់ ខាងលើនោះ ទេ។ ការរៀបចំកម្មវិធីរបស់ថ្នាក់ជាតិប្រចាំឆ្នាំ២០០៧ ដែលត្រូវបញ្ចូលតារាងតក្កភាព (Logframe) និង សូចនាករ នៃការតាមដាន នឹងត្រូវរៀបចំឡើងដោយផ្តោតលើគោលដៅចំបង ចំនួន ៣ ដូចខាងក្រោម:

១- ពង្រឹងប្រព័ន្ធ និងរចនាសម្ព័ន្ធស្ថាប័នរបស់រាជរដ្ឋាភិបាល នៅថ្នាក់ក្រោមជាតិ ។

២- ធ្វើឱ្យប្រសើរឡើងនូវ គុណភាព និងបរិមាណ នៃការផ្តល់សេវា និងការវិនិយោគ នៅថ្នាក់ក្រោមជាតិ ។

៣- ជំរុញការអនុវត្តក្របខ័ណ្ឌ នៃកម្មវិធី និងគោលនយោបាយ សម្រាប់គាំទ្រចំពោះការកាត់បន្ថយភាពក្រីក្រ និង អភិបាលកិច្ចនៅថ្នាក់ ក្រោមជាតិ ។

**តារាងលេខ៣៩: សង្ខេបកិច្ចព្រមព្រៀងនានានៅក្រោមផែនការសកម្មភាពនិងថវិកា គជវវ ២០០៧**

| ចំនួន | ឈ្មោះគំរោង | ចំនួនថវិកា | អនុមត័ដោយ | |
|---|---|---|---|---|
| | | | រាជរដ្ឋាភិបាលកម្ពុជា | ភាគីម្ចាស់ជំនួយ |
| **1. កិច្ចព្រមព្រៀងរវាង រាជរដ្ឋាភិបាល និងដៃគូម្ចាស់ជំនួយ** | | | | |
| 1 | PSDD | 10,400,000 | គជវវ | UNDP, UK, Sweden |
| 1 | CBRD | 1,137,218 | ក្រសួងហិរញ្ញវត្ថុ និងក្រសួងអភិវឌ្ឍន៍ | IFAD |
| 1 | RPRP | 3,975,852 | ក្រសួងហិរញ្ញវត្ថុ កសិកម្ម និង គជវវ | IFAD |
| 1 | RULIP | 1,192,157 | ក្រសួងហិរញ្ញវត្ថុ និងក្រសួងកសិកម្ម | IFAD, UNDP |
| 1 | RILG | 6,396,724 | ក្រសួងហិរញ្ញវត្ថុ និង គជវវ | World Bank |
| 1 | NRML/D&D | 4,720,184 | គជវវ | Denmark,UK |
| 1 | NRML/Land | 679,710 | ក្រសួងគ្រប់គ្រងដែនដី | Denmark,UK |
| 1 | CCDP2 | 2,710,000 | ក្រសួងមហាផ្ទៃ | ADB |
| 1 | TSSL | 2,845,012 | ក្រសួងមហាផ្ទៃ | ADB |
| 1 | DDLG | 2,888,983 | ក្រសួងមហាផ្ទៃ | EC, UNDP |
| 1 | EFMP | 1,136,650 | ក្រសួងមហាផ្ទៃ | EC,UNDP |
| 1 | សិទ្ធិកុមារ | 2,816,457 | ក្រសួងផែនការ | UNICEF |
| 1 | ADMAC | 1,196,975 | ក្រសួងកសិកម្ម និងអាជ្ញាធរដោះមីន | Canada |
| 1 | LAAR | 265,000 | ក្រសួងមហាផ្ទៃ | USAID |
| 1 | | 175,501 | ក្រសួងមហាផ្ទៃ | UNFPA |
| **15** | **សរុប** | **$42,536,423** | | |
| **2. កិច្ចព្រមព្រៀង ក្រសួងនានា នៅថ្នាក់ជាតិ** | | | | |

| ចំនួន | ឈ្មោះគំរោង | ចំនួនថវិកា | អាជ្ញាធរថ្នាក់ជាតិ | ក្រសួងដៃគូ |
|---|---|---|---|---|
| 12 | PSDD | 500,000 | គជវវ | ១២ ក្រសួង |
| 1 | CBRD | 98,030 | ក្រសួងហិរញ្ញវត្ថុ | ក្រសួងអភិវឌ្ឍន៍ជនបទ |
| 3 | RPRP | 132,818 | គជវវ | ក្រសួងកសិកម្ម កិច្ចការនារី និងហិរញ្ញវត្ថុ |
| 1 | RULIP | 245,487 | ក្រសួងហិរញ្ញវត្ថុ | ក្រសួងកសិកម្ម |
| 4 | សិទ្ធិកុមារ | 461,591 | UNICEF | ក្រសួងមហាផ្ទៃ ផែនការ កិច្ចការនារី អភិវឌ្ឍន៍ |
| 2 | ADMAC | 32,464 | ក្រសួងកសិកម្ម | ក្រសួងកសិកម្ម និងអាជ្ញាធរដោះមីន |
| 1 | CCDP2 | 585,000 | ក្រសួងកសិកម្ម | ក្រសួងមហាផ្ទៃ |
| 1 | TSSL | 395,000 | ក្រសួងកសិកម្ម | ក្រសួងមហាផ្ទៃ |
| **25** | **សរុប** | **$2,450,390** | | |
| **3. កិច្ចព្រមព្រៀង រវាងថ្នាក់ជាតិ-ថ្នាក់** | | | | |
| **ចំនួន** | **ឈ្មោះគំរោង** | **ចំនួនថវិកា** | **អាជ្ញាធរថ្នាក់ជាតិ** | **អាជ្ញាធរខេត្ត** |
| 24 | PSDD | 5,486,434 | គជវវ | គអជខ |
| 2 | CBRD | 1,039,188 | ក្រសួងអភិវឌ្ឍន៍ជនបទ | គអជខ |
| 2 | RPRP | 3,721,064 | គជវវ និងក្រសួងកសិកម្ម | គអជខ |
| 3 | RULIP | 946,670 | ក្រសួងកសិកម្ម | គអជខ |
| 10 | NRML/D&D | 4,380,006 | គជវវ | គអជខ |
| 10 | NRML/Land | 679,710 | ក្រសួងគ្រប់គ្រងដែនដី | គអជខ |
| 6 | Seth Koma | 2,054,866 | UNICEF | គអជខ |
| 5 | TSSL | 617,012 | ក្រសួងមហាផ្ទៃ | គអជខ |
| 10 | DDLG | 1,681,476 | ក្រសួងមហាផ្ទៃ | គអជខ |
| 1 | EFMP | 55,650 | UNDP | គអជខ |
| 3 | ADMAC | 893,601 | ក្រសួងកសិកម្ម | គអជខ |
| 1 | FSIP | 50,900 | CANADA | គអជខ |
| **77** | **សរុប** | **$21,606,577** | | |
| **4. កិច្ចព្រមព្រៀងរវាង គណៈកម្មាធិការប្រតិបត្តិ គអជខ — មន្ទីរជំនាញថ្នាក់ខេត្ត និងអាជ្ញាធរស្រុក** | | | | |
| **ចំនួន** | **ឈ្មោះគំរោង** | **ចំនួនថវិកា** | **អាជ្ញាធរខេត្ត** | **ភ្នាក់ងារអនុវត្តន៍** |
| 207 | PSDD | 1,800,000 | គអជខ | ១៩ មន្ទីរ |
| 96 | PSDD | 3,336,434 | គអជខ | ផ្នែកទាំង៤ នៃគប្រ ខេត្តក្រុងទាំង២៤ |
| 28 | PSDD | 350,000 | គអជខ | ២៨ ស្រុក |
| 46 | NRML | 400,000 | គអជខ | ១០ មន្ទីរ |
| 10 | NRML | 679,710 | គអជខ | មន្ទីរ គ្រប់គ្រងដែនដី |
| 66 | NRML | 1,980,000 | គអជខ | ៦៦ ស្រុក |
| 8 | RPRP | 2,778,799 | គអជខ | ៤ មន្ទីរ |
| 8 | CBRD | 1,039,188 | គអជខ | ៤ មន្ទីរ |
| 3 | RULIP | 1,039,188 | គអជខ | មន្ទីរ កសិកម្ម |
| 30 | សិទ្ធិកុមារ | 2,054,866 | គអជខ | ៥ មន្ទីរ |
| 9 | ADMAC | 1,063,260 | គអជខ | ៣ មន្ទីរ |
| 5 | FSIP | 50,900 | គអជខ | ៤ មន្ទីរ |
| **516** | **សរុប** | **$16,572,345** | | |

**គោលដៅទី១:** ***ពង្រឹងប្រព័ន្ធ និងរចនាសម្ព័ន្ធស្ថាប័នរបស់រាជរដ្ឋាភិបាល នៅថ្នាក់ក្រោមជាតិ***

**លទ្ធផល១.១:** ការបង្កើត និងការកែលម្អប្រព័ន្ធទាំងឡាយដែលពាក់ព័ន្ធទៅនឹងវិមជ្ឈការ និងវិសហមជ្ឈការ ។

**លទ្ធផល១.២:** ស្ថាបន័នៅថ្នាក់ជាតិនិងក្រោមជាតិត្រូវបានពង្រឹងក្នុងកំណែទម្រង់វិមជ្ឈការនិង វិសហមជ្ឈការ ។

**លទ្ធផល១.៣:** មន្ត្រីត្រូវបានបណ្តុះបណ្តាល និងលើកទឹកចិត្តដើម្បីអនុវត្តប្រព័ន្ធវិមជ្ឈការ និងវិសហមជ្ឈការ។

<u>គោលដៅទី២</u>: ***ធ្វើឱ្យប្រសើរឡើងនូវគុណភាពនិងបរិមាណ នៃការផ្តល់សេវានិងការវិនិយោគ នៅថ្នាក់ក្រោមជាតិ***

**លទ្ធផល២.១:** គុណភាព និងលទ្ធភាពប្រើប្រាស់នៃសេវាដែលបានផ្តល់តាមរយៈមូលនិធិឃុំសង្កាត់ និងប្រភពផ្សេងៗទៀតត្រូវបានពង្រឹង។

**លទ្ធផល២.២:** ប្រសិទ្ធិផលនិងលទ្ធភាពប្រើប្រាស់នៃសេវា ដែលផ្តល់ដោយថ្នាក់ខេត្ត និងអ្នកផ្គត់ផ្គង់ផ្សេងទៀតត្រូវបានពង្រឹង។

**លទ្ធផល២.៣:** ប្រសិទ្ធិភាព និងប្រសិទ្ធផលនៃសេវាគាំទ្ររបស់ថ្នាក់ជាតិត្រូវបានធ្វើឱ្យកាន់តែប្រសើរឡើង។

**លទ្ធផល២.៤:** បណ្តាញភាពជាដៃគូ ត្រូវបានពង្រឹង និងពង្រីក។

<u>គោលដៅទី៣</u>: ***ជំរុញការអនុវត្តក្របខ័ណ្ឌ នៃកម្មវិធី និងគោលនយោបាយ សម្រាប់គាំទ្រការកាត់បន្ថយភាពក្រីក្រ និង អភិបាលកិច្ចនៅថ្នាក់ ក្រោមជាតិ។***

**លទ្ធផល៣.១:** ការបង្កើតក្របខ័ណ្ឌគោលនយោបាយ សម្រាប់កំណែទម្រង់វិមជ្ឈការ និងវិសហជ្ឈការ ។

**លទ្ធផល៣.២:** ពិនិត្យនិងកែសម្រួលឡើងវិញ នូវគោលការណ៍ណែនាំពីដំណើរប្រតិបត្តិការនានា។

**លទ្ធផល៣.៣:** ជំរុញកិច្ចសហការវិស័យនានាសម្រាប់គាំទ្រដល់ដំណើរការកាត់បន្ថយភាពក្រីក្រ។

**លទ្ធផល៣.៤:** ពង្រឹងសេវាគាំទ្រពីថ្នាក់ជាតិចំពោះថ្នាក់ក្រោមជាតិ តាមរយៈការអភិវឌ្ឍន៍ស្ថានប័ន និងសមត្ថភាពរបស់ គ.ជ.វ.វ។